ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



រូបថត: ទូច ចាន់ផល កុមារដែលរស់រានមានជីវិតពីគុកទួលស្លែង

- ទម្លាយភាពស្ងប់ស្ងាត់
- សហគមន៍ចាមមូស្លីម : ទំនោរផ្លាស់ប្តូរមិនអាចចៀសផុត

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា
លេខ១១០ ខែកុម្ភៈ ឆ្នាំ២០០៩

# ស្វែងរកការពិត

លេខ១១០ ខែកុម្ភៈ ឆ្នាំ២០០៩

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ លោកនិយាយ : រឿងទម្លាយភាពស្ងប់ស្ងាត់ ....................................១

**ផ្នែកឯកសារ**

◆ សកម្មភាពក្បត់របស់ ឡេង វ៉ាង ....................................................២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ...............................៤

◆ ជា ជឿន អតីតប្រធានសហករណ៍ភ្នំសំពៅ....................................៦

◆ របាយការណ៍ស្ដីពីការបញ្ចាំងភាពយន្ដឯកសារ ....................................៨

◆ បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ទៅកាន់អង្គការសហប្រជាជាតិ..........១១

◆ ការបង្ហាញឲ្យឃើញពីភាពរន្ធត់ក្នុងរបប ប៉ុល ពត តាមរយៈ ...............១៣

◆ យ៉ែម ឃឹម អ្នកធ្វើខ្មោះសម័យខ្មែរក្រហម ....................................១៨

◆ ទំនាក់ទំនងភូមិភាគបូព៌ា ............................................................២០

**ផ្នែកច្បាប់**

◆ សវនាការរួមនិងអង្គជំនុំជម្រះវិសាមញ្ញ ......................................២៣

**វេទិកាពិភាក្សាសាធារណៈ**

◆ យុត្តិធម៌ត្រូវបានរំខាន ...........................................................៣៤

◆ រឿងទម្លាយភាពស្ងប់ស្ងាត់ ....................................................៣៦

◆ ការសិក្សាអប់រំពីអំពើប្រល័យពូជសាសន៍.........................................៣៨

◆ សហគមន៍ចាមមូស្លីមៈ ទំនោរផ្លាស់ប្ដូរមិនអាចចៀសផុត................៥៤

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការចងចាំ .............................................................................៥៧

◆ យោបល់ចំពោះសេចក្ដីស្នើរបស់សហព្រះរាជអាជ្ញា.....................៥៩



អ្នកភូមិអានទស្សនាវដ្ដីស្វែងរកការពិត



អ្នកភូមិអានទស្សនាវដ្ដីស្វែងរកការពិត

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** ជា ធីតា, ស៊ីវ សារីណា, កែវ ដាស៊ីល, ផេង ពង្សរ៉ាស៊ី, ម៉ារ៉ាន់ សេរ៉េល, ហួសស្គួន ចេម, ឌី ខាំបូលី, សូ ហ្វារីណា, ភី វ៉ាន់ដែន, ដែន អែនហៀល **អ្នកនិពន្ធនិងស្រាវជ្រាវ :** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែៈ** ជា ផល្លា, ទេស ម៉ារ៉ែម **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រៈ**ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ឆេង វេង

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ល្ខោននិយាយ : រឿងទម្លាយភាពស្ងប់ស្ងាត់

មានភាពស្ងប់ស្ងាត់នៅក្នុងប្រទេសកម្ពុជាជាយូរណាស់មក ហើយទាក់ទងនឹងរបបខ្មែរក្រហម ភាពស្ងប់ស្ងាត់ដែលបានបន្សល់ទុកជាច្រើនទសវត្សរ៍ ហើយស្ថិតនៅក្នុងចិត្តប្រកបដោយភាពភ័យខ្លាច ការឈឺចាប់ និងរឿងនយោបាយ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មានកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនដើម្បីបញ្ចប់ភាពស្ងប់ស្ងាត់នេះនៅក្នុងទម្រង់ ជាការស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ កម្មវិធីចុះផ្សព្វផ្សាយតាមមូលដ្ឋាន និងការបង្រៀននៅតាមវិទ្យាល័យទូទាំងព្រះរាជាណាចក្រកម្ពុជាពីអំពើប្រល័យពូជសាសន៍ ។ ខណៈពេលដែលយុទ្ធសាស្ត្រនីមួយៗមានសារៈសំខាន់សម្រាប់ដំណើរការធ្វើឲ្យប្រទេសកម្ពុជាប្រសើរឡើង វានៅតែត្រូវការយុទ្ធសាស្ត្រដែលផ្តោតទៅលើផ្នែកអារម្មណ៍ និងស្មារតីទាក់ទងនឹងការផ្សះផ្សានិងការជាសះស្បើយរបួសផ្លូវចិត្ត ។ នេះគឺជាឱកាសដែលសិល្បៈអាចធ្វើវិភាគទានដ៏មានសារៈសំខាន់បំផុត ។ ប្រជាជនកម្ពុជាមានសិល្បៈនៅក្នុងខ្លួន ហើយនេះគឺជាដំណើរជីវិតរបស់ប្រជាជនម្នាក់ ។ ខ្មែរក្រហមបានសម្លាប់អ្នកសិល្បៈជាច្រើន ប៉ុន្តែមិនអាចសម្លាប់ទេពកោសល្យសិល្បៈរបស់ប្រជាជនកម្ពុជា ។ សិល្បៈគឺជាដួងព្រលឹងរបស់ប្រជាជនកម្ពុជា ។




រឿង «ទម្លាយភាពស្ងប់ស្ងាត់» គឺជាការសម្តែងដ៏អស្ចារ្យបំផុតមួយតាំងពីរបបខ្មែរក្រហមបានដួលរលំនៅក្នុងឆ្នាំ១៩៧៩ ។ វាគឺជាការសម្តែងអំពីប្រជាជនកម្ពុជា ការឈឺចាប់ កំហឹង និងការលើកទឹកចិត្តឲ្យគិតពីអនាគត មិនថាក្នុងកាលៈទេសៈណាក៏ដោយ ។ ជនរងគ្រោះនៃរបបខ្មែរក្រហមគឺជាប្រជាជនដែលប៉ះទង្គិចផ្លូវចិត្ត រស់នៅក្នុងសង្គមមួយដែលបែកបាក់ ហើយគឺជាមនុស្សដែលវិញ្ញាណកំពុងតែហោះហើរ ។ ខ្ញុំបានរកឃើញវិញ្ញាណនោះរបស់យើងនៅក្នុងការសម្តែងដែលមានចំណងជើងថា «ទម្លាយភាពស្ងប់ស្ងាត់» ។ ការសម្តែងនេះមានសារៈសំខាន់ចំពោះប្រជាជនកម្ពុជាបានទស្សនា និងស្តាប់ ។ វានឹងជួយស្តារសេចក្តីថ្លៃថ្នូរនិងមនុស្សធម៌ ហើយធ្វើឲ្យសីលធម៌របស់យើងកាន់តែប្រសើរឡើង ។ វាក៏នឹងជួយឲ្យកូនចៅរបស់យើងដឹងពីប្រទេសយើងកាន់តែច្បាស់ ។ ខ្ញុំសង្ឃឹមថាការសម្តែងនៅពេលអនាគតនឹងដូចគ្នាទៅនឹងការសម្តែងនេះ គឺវានឹងមានតួនាទីសំខាន់ក្នុងការស្តារសង្គមកម្ពុជាសារឡើងវិញ ។

**ឆាំង យុ**

# សកម្មភាពក្បត់របស់ ឡេង វ៉ាង

ឡេង វ៉ាង អាយុ២១ឆ្នាំ ជនជាតិខ្មែរ មានស្រុកកំណើតនៅភូមិពោធិបាន ឃុំពោធិបាន ស្រុក១៨ តំបន់២៥ ។ នៅក្នុងចម្លើយសារភាព វ៉ាង រៀបរាប់ពីការទាក់ទងជាមួយកម្លាំងប្រឆាំងបដិវត្តន៍ មិនបានបំពេញភារកិច្ចសួរចម្លើយតាមបញ្ជារបស់បដិវត្តន៍ដោយបណ្តោយឲ្យខ្មាំងឆ្លើយសេរី និងពេលសួរចម្លើយ ដេកបណ្តើរ ដើរលេងបណ្តើរ និងពន្យារពេលយកឯកសារប្រគល់ទៅឲ្យថ្នាក់លើ ។ នៅមុនថ្ងៃចាប់ខ្លួន វ៉ាង មានតួនាទីមួយចំនួនដូចជាអនុក្រុម ប្រធានក្រុម ប្រធានពួក (នៅមន្ទីរស-២១) និងចុងក្រោយជាស្នងការកងវរយ (នៅអនុសេនាធំ១៣) ។

## ប្រវត្តិ ឡេង វ៉ាង

នៅខែ១ ឆ្នាំ១៩៧០ វ៉ាង រៀននៅវត្តពោធិបាន បានត្រឹមថ្នាក់ទី៨ក៏ឈប់រៀន មកជួយរកស៊ីឪពុកម្តាយ បន្ទាប់មកក៏ឲ្យបួលបួសជាសង្ឃនៅវត្តពោធិបានបានមួយវស្សា ។

នៅខែ៧ ឆ្នាំ១៩៧២ វ៉ាង បានទៅសុំប្រធានភូមិពោធិបាន ឈ្មោះ ឈុំ ដើម្បីចូលបម្រើបដិវត្តន៍ ។ ក្រោយពីឯកភាព ឈុំ ក៏បញ្ជូន វ៉ាង ទៅយោធាស្រុក១៨ តំបន់២៥ ដែលមានឈ្មោះ កត ជាគណៈយោធាស្រុក (បច្ចុប្បន្នក្បត់) ជាអ្នកគ្រប់គ្រង ។ បន្ទាប់មកអង្គការបញ្ចូល វ៉ាង ទៅក្នុងកងវរ១១៦ ភូមិភាគពិសេស ដែលមានស្នាក់ការនៅភូមិអង្គ ឃុំក្រាំងយ៉ូវ តំបន់២៥ ក្រោមការគ្រប់គ្រងរបស់ ពីន ជាស្នងការ ។

នៅខែ៨ ឆ្នាំ១៩៧៤ អង្គការចាត់តាំង វ៉ាង ឲ្យទៅរៀនបច្ចេកទេសរយៈពេល៤ខែនៅភូមិកំពង់ស្វាយ ឃុំព្រែកថ្មី ស្រុក១៨ តំបន់២៥ ដែលមានឈ្មោះ ម៉ាត់ (បច្ចុប្បន្នក្បត់), ស្រស់ និង យ៉ែម ជាអ្នកខទ្ទេសនាម ។

នៅខែ១ ឆ្នាំ១៩៧៥ អង្គការចាត់តាំង វ៉ាង ឲ្យចូលក្នុងអង្គភាពវរសេនាតូច១៨៣ ដែលតាំងសមរភូមិនៅព្រែកទម្លាប់ ទន្លេមេគុង មានឈ្មោះ ហ៊ី ជាស្នងការ វឿន និង វឿន ។ ក្រោយមកអង្គភាព១៨៣ ក៏ផ្លាស់លេខដាក់អង្គភាព៧០៨វិញ ដែលមាន ប៉េង ឡេង ជាប្រធានស្នងការ ហ៊ី និង ង៉ែត ។

នៅខែ១-២ ឆ្នាំ១៩៧៧ អង្គការបានដក វ៉ាង ឲ្យទៅបំពេញភារកិច្ចនៅអង្គភាព៤៥០ (នៅខាងលិចវត្តល័ង្កា) ។ បន្ទាប់ពីធ្វើការបាន៤ថ្ងៃ វ៉ាង ក៏ធ្លាក់ខ្លួនឈឺត្រូវមកសម្រាកព្យាបាលនៅមន្ទីរពេទ្យកងពល៧០៣រយៈពេលមួយខែកន្លះ ។

នៅថ្ងៃទី១៦ ខែ៥ ឆ្នាំ១៩៧៧ វេលាម៉ោង៤ល្ងាច ឆាយ បានប្រើនិរសារឲ្យមកហៅ វ៉ាង រួមជាមួយ វ៉េង, វិន និង ខន មកពី អង្គភាព១៨២ ទៅជួប រួចខទ្ទេសនាមឲ្យទៅកន្លែង ប៉េង ឡេង អង្គភាព១៨២ ។ នៅអង្គភាព ប៉េង ឡេង បានណែនាំ វឿន ពីវិធីសួរចម្លើយខ្មាំងចាប់តាំងពីឋានៈតូចដល់ធំ ដែលមាន យឿន នៅអង្គភាព៧០៨ ជាអ្នកទទួលខុសត្រូវ ។ បន្ទាប់មក យឿន បែងចែកភារកិច្ចឲ្យ វ៉ាង និង វ៉េង សួរចម្លើយ វរ ចំណែក វិន និង ផន សួរចម្លើយ ជា រយៈពេលមួយយប់នៅខាងលើផ្ទះថ្មខាងលិចវត្តល័ង្កា ។ ព្រឹកឡើង វ៉ាង បានយកឯកសារទៅប្រគល់ឲ្យ យឿន រួចបញ្ជូនបន្តទៅឲ្យ ប៉េង ។ បន្ទាប់ពីអានចប់ ប៉េង បានហៅ វ៉ាង មកប្រាប់ថា ឯកសារនេះធ្វើខុសទាំងអស់ ត្រូវធ្វើម្តងទៀត ។

នៅថ្ងៃទី១៧ ខែ៥ ឆ្នាំ១៩៧៧ ម៉ោង១២ថ្ងៃត្រង់ វ៉ាង ក៏ត្រឡប់មកកន្លែងសួរចម្លើយវិញ ។ ពេលនោះ យឿន មកសួរ វ៉ាង ថាងងុយដេកទេ? វ៉ាង ក៏តបទៅវិញថាងងុយដេកណាស់ បើធ្វើការនៅកងស្រួលជាង ព្រោះមានពេលសម្រាកគ្រប់គ្រាន់ ។ បន្ទាប់ពីស្តាប់ពាក្យសម្តីនេះ យឿន ក៏មិនបានស្តីបន្ទោសអ្វីដែរ ព្រមទាំងណែនាំឲ្យដេក ដើរលេងនៅពេលបំពេញការងារទៀតផង ។

នៅថ្ងៃទី១៩ ខែ៥ ឆ្នាំ១៩៧៧ យឿន បានចាត់ឲ្យ វ៉ាង សួរចម្លើយខ្មាំងម្នាក់ទៀតនៅលើផ្ទះថ្មមួយកន្លែងដោយបានណែនាំកុំសួរខ្មាំងច្រើនពេក ។ នៅយប់នោះ ប៉េង ឡេង ហៅ យឿន ទៅជួបនៅខាងក្រោម ។ មួយសន្ទុះក្រោយមក យឿន ត្រឡប់មកប្រាប់ វ៉ាង ឲ្យឈប់សួរខ្មាំងទៀត និងបានណែនាំជាបន្ទាប់ ។

## ខ្លឹមសារណែនាំ

យឿន បានអប់រំ វ៉ាង ថាធ្វើបដិវត្តន៍មានការលំបាក របបអាហារក៏មិនគ្រប់គ្រាន់ ហើយខិតខំបំពេញភារកិច្ចយូរហើយ ប៉ុន្តែ

មិនឃើញបានឡើងឋានៈអ្វីទេ នៅតែក្រុម និងពួកប៉ុណ្ណោះ ។ ចំណែកអ្នកចូលមកក្រោយៗបានឡើងតួនាទីធំៗដូចជាកងហាជាដើម ។ បន្ទាប់មក យឿន បានណែនាំ វ៉ាង ឲ្យស្គាល់កម្លាំងក្បត់រួមមាន ទឹម និង ជ្រីវ និងបានផ្តាំថាមិនត្រូវសួរពួក៣៨ខ្លាំងពេកទេ និងធ្វើយ៉ាងណាកុំឲ្យអង្គការយកឯកសារពួក៣៨នេះបាន ។ បើថ្នាក់លើទាមទាយកខ្លាំង គ្រាន់តែប្រាប់ថា ខ្មាំងមិនព្រមសារភាព ហើយវានិយាយតែពីរឿងខ្វះខាតប៉ុណ្ណោះ គឺត្រូវធ្វើយ៉ាងណាឲ្យឃឹតដំណើរការបដិវត្តន៍ ។

នៅថ្ងៃបន្ទាប់ យឿន បានប្រាប់ វ៉ាង ថា ឥឡូវអង្គការទុកចិត្ត និងបានប្រគល់ភារកិច្ចឲ្យធ្វើ ព្រោះ វិន, ផន ជាប់រវល់ ។ ប៉ុន្តែក៏ត្រូវស្តាប់តាមបញ្ជាខ្ញុំដែរ ហើយឲ្យតែ វ៉ាង ធ្វើបាន គោរពបានកសាងខ្លួនបានល្អនិងបេះលាក់ការណ៍ឲ្យបានជិតប្រាកដជាបានឡើងឋានៈធំ ដោយនៅពេលសួរចម្លើយ ប្រសិនបើខ្មាំងនិយាយយ៉ាងម៉េចទុកឱកាសឲ្យវានិយាយទៅ មិនបាច់សួរដេញដោលវាច្រើនទេ ប្រយ័ត្នខ្មាំងឆ្លើយដាក់កម្លាំងរបស់យើង ។ ដូច្នេះត្រូវសួរខ្មាំងបណ្តើរ ដេកបណ្តើរ ដើរលេងបណ្តើរ និងពន្យារពេលយកឯកសារទៅប្រគល់ឲ្យថ្នាក់លើ ។

នៅថ្ងៃ២០ ខែ៥ ឆ្នាំ១៩៧៧ វ៉ាង ដើរពីបន្ទប់សួរចម្លើយទៅកន្លែងស្នាក់នៅ ស្រាប់តែពេលនោះ វ៉េង មកប្រាប់ វ៉ាង ឲ្យទៅរៀបចំវ៉ាល់ឡទៅមន្ទីរ០៣ជាមួយ ជ្រីវ, ទឹម, ម្រេច (មកពីអង្គភាព៣១០) ។

នៅព្រឹកថ្ងៃទី២១ ខែ៥ ឆ្នាំ១៩៧៧ ពីន បានហៅ វ៉ាង មកណែនាំថាទៅនៅកន្លែងថ្មី មិនត្រូវអួតអាងពីអង្គភាពទេ ព្រោះអង្គការចាត់តាំងឲ្យទៅសួរចម្លើយខ្មាំងនៅមន្ទីរស-២១ គឺត្រូវខិតខំកសាងខ្លួន ពង្រឹងជំហរ ហើយប្រយ័ត្នខ្មាំងអូសទាញបាន ។ បន្ទាប់ពីណែនាំចប់ ហ៊ី ក៏មកទទួលយកទៅនៅមន្ទីរស-២១ ដែលមានឈ្មោះ ឌុច ជាអ្នកទទួលខុសត្រូវ ។ ដំបូង វ៉ាង ទទួលនាទីយុវជន ធ្វើការជាមួយក្រុម មុត និង ឈឿន ប៉ុន្តែមិនបានធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ទេ ។ មួយខែក្រោយមក អង្គការបែងចែកក្រុមសួរចម្លើយថ្មី ពេលនោះ វ៉ាង ក៏ទទួលតួនាទីជាមេពួក ដែលមាន ប៊ូ, មុត និង ឈឿន ជាអ្នកទទួលខុសត្រូវ ។

នៅខែ៧ ឆ្នាំ១៩៧៧ អង្គការក៏ដក វ៉ាង ទៅអង្គភាពអនុសេនាធំ១៣ មាននាទីជាស្នងការកងរយ ដែលមាន សុក ជាអ្នកទទួលខុសត្រូវ ។ រហូតមកដល់ខែ៨ ឆ្នាំ១៩៧៧ ក៏ត្រូវអង្គការចាប់ខ្លួន វ៉ាង មកមន្ទីរស-២១ រួមជាមួយកម្លាំងទាក់ទងមួយចំនួនទៀតដូចជា ទី១) យឿន នៅអង្គភាព៧០៤ ទី២) ទឹម នៅអង្គភាពមន្ទីរស-២១ អង្គការចាប់ខ្លួន ទី៣) ម្រេច នៅអង្គភាពស-២១ និងទី៤) ជ្រីវ នៅអង្គភាពស-២១ ។

## ចុងបញ្ចប់នៃចម្លើយសារភាព

វ៉ាង បានបញ្ជាក់ថា យឿន បានណែនាំឲ្យសួរខ្មាំងនៅលើផ្ទះថ្ម ហើយ វ៉ាង សួរចម្លើយបានរយៈពេលតែ៥ថ្ងៃប៉ុណ្ណោះ ។ នៅថ្ងៃទី២០ ខែ៥ ឆ្នាំ១៩៧៧ ម៉ោង៥ល្ងាច យឿន បានប្រាប់ វ៉ាង ថានៅទីនេះមាន ជ្រីវ, ទឹម, ម្រេច ប៉ុន្តែឈ្មោះដែលបានរាយការណ៍នេះមិនមានសកម្មភាពក្បត់ជាមួយគ្នាទេ ព្រោះ ទឹម និងម្រេច អង្គការចាត់តាំងឲ្យទៅបំពេញភារកិច្ចនៅអង្គភាព៣១០ ចំណែក ជ្រីវ ត្រូវទៅបំពេញភារកិច្ចចាប់ខ្មាំងនៅអង្គភាព ។ សកម្មភាពក្បត់ វ៉ាង ជាមួយនិង យឿន ជាអ្នកអនុវត្តន៍ផ្ទាល់ ។ **សោម ប៊ុនថន**

# សេចក្តីប្រកាសរកប្អូនប្រុស

នាងខ្ញុំឈ្មោះ នាក់ ហោង សព្វថ្ងៃរស់នៅភូមិភ្នំតូច ឃុំស្តេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកខ្ញុំឈ្មោះ សោម យេន (ស្លាប់) និងម្តាយឈ្មោះ អ៊ុន សឹម (ស្លាប់) ។ ខ្ញុំមានបងប្អូនពីរនាក់ គឺខ្ញុំនិងប្អូនប្រុសម្នាក់ទៀតឈ្មោះ នាក់ ធី (បាត់ខ្លួន) ។ ខ្ញុំសូមស្វែងរកប្អូនប្រុសឈ្មោះ នាក់ ធី ដែលបាត់ខ្លួនពេលធ្វើជានិរសារនៅព្រំដែនវៀតណាមនៅមុនឆ្នាំ១៩៧៥ ។ នៅពេលនោះ ធី ទើបតែមានអាយុប្រហែលជា១៨ឬ១៥ឆ្នាំប៉ុណ្ណោះ រួចបានចេញពីផ្ទះទៅធ្វើជានិរសារជាមួយមីងឈ្មោះ ពៅ ជាអ្នកនាំចូល ។ ក្រោយមកខ្ញុំក៏បាត់ដំណឹង ធី រហូត ។

ប្រសិនបើប្អូនបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាស្គាល់ ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៧ ៩២៩ ៩៦១ ឬមេភូមិភ្នំតូចឈ្មោះ មិន ឈុំ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ**

# ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ

របបកម្ពុជាប្រជាធិបតេយ្យតែងតែផ្តល់នូវឆន្ទៈមួយដ៏រឹងមាំដើម្បីរស់នៅក្នុងសុខសន្តិភាព និងរក្សាទំនាក់ទំនងជិតស្និទ្ធជាមិត្តភាពជាមួយប្រទេសជិតខាងទាំងអស់ ដោយឈរលើមូលដ្ឋាននៃភាពស្មើគ្នានិងគោរពគ្នាទៅវិញទៅមក ។

ដើម្បីបង្កើតលក្ខខណ្ឌអនុគ្រោះសម្រាប់ដោះស្រាយបញ្ហាឲ្យបានឆាប់រហ័សដែលបណ្តាលមកពីការរំលោភបំពាន និងការឈ្លានពានដែលប្រព្រឹត្តដោយសាធារណរដ្ឋសង្គមនិយមវៀតណាមប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ រាជរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យបានផ្ញើសេចក្តីអធិប្បាយខ្លីនេះទៅកាន់រាជរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមដើម្បីចាត់វិធានការជាបន្ទាន់ដូចខាងក្រោម ៖

១) ដើម្បីបញ្ឈប់ការវាយប្រហារនៃអំពើឈ្លានពាន លុកលុយនិងបញ្ចូលជាឧបសម្ព័ន្ធប្រឆាំងនឹងដែនដីនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើម្បីបញ្ឈប់នូវរាល់សកម្មភាពទាំងឡាយនៃការបង្កបញ្ហានិងការរំលោភបំពានដែលប្រឆាំងនឹងដែនគោក ដែនទឹក ដែនអាកាសនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើម្បីបញ្ឈប់ការបាញ់ប្រហារដោយកាំភ្លើងយន្ត ការវាយកម្ទេច ការទម្លាក់គ្រាប់បែក និងអនុវត្តការវាយលុកលើផ្លូវអាកាសប្រឆាំងនឹងដែនគោក និងដែនទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

២) ដើម្បីបញ្ឈប់ការបញ្ជូនភ្នាក់ងារស៊ើបការសម្ងាត់ទៅប្រមូលផ្តុំនៅក្នុងដែនគោក ដែនទឹក និងដែនកោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើម្បីបញ្ឈប់សកម្មភាពនៃការបំផ្លាញ និងការធ្វើអន្តរាគមន៍នៅក្នុងកិច្ចការផ្ទៃក្នុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើម្បីបញ្ឈប់ការប៉ុនប៉ងធ្វើរដ្ឋប្រហារ ឬទម្រង់នៃសកម្មភាពដទៃទៀតដែលមានគោលបំណងទម្លាក់រដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

៣) ដើម្បីបោះបង់យុទ្ធសាស្ត្រទាំងអស់ដែលមានគោលបំណងដាក់ប្រទេសកម្ពុជានៅក្រោមការគ្រប់គ្រងរបស់ប្រទេសវៀតណាមនៅក្នុង «សហព័ន្ធឥណ្ឌូចិន» តាមរយៈទ្រឹស្តី «បក្សមួយ ប្រទេសមួយ មនុស្សម្នាក់» នៅ «ឥណ្ឌូចិន» ដែលជាកម្មសិទ្ធិរបស់ប្រទេសវៀតណាម ។

៤) ដើម្បីគោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើម្បីគោរពសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការសម្រេចចិត្តលើជោគវាសនារបស់ខ្លួនដោយខ្លួនឯង ។

បើសិនជាសាធារណរដ្ឋសង្គមនិយមវៀតណាមអនុវត្តសកម្មភាពមួយច្បាស់លាស់ដោយអនុលោមតាមសេចក្តីអធិប្បាយទាំង៤ចំណុចនេះក្នុងរយៈពេល៧ខែ តាំងពីឥឡូវនេះរហូតដល់ចុងឆ្នាំ១៩៧៨ ដោយបញ្ឈប់ចាប់ពីពេលឥឡូវនេះនូវរាល់សកម្មភាពទាំងឡាយដែលទាក់ទងនឹងការរំលោភបំពាន ឬការឈ្លានពានដែលប្រឆាំងនឹងឯករាជ្យភាព អធិបតេយ្យភាពបូរណភាពដែនដី និងសុវត្ថិភាពនៃរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់មកបរិយាកាសមិត្តភាពនិងភាពទុកចិត្តនឹងត្រូវបានបង្កើតឡើងយ៉ាងច្បាស់ ។ នៅក្នុងបរិយាកាសនេះ ខាងកម្ពុជានិងខាងវៀតណាមនឹងជួបគ្នាដើម្បីស្វែងរកភាពត្រឹមត្រូវនិងដំណោះស្រាយចំពោះបញ្ហាផ្សេងៗ ។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានគិតនិងជឿជាក់ថានេះជាមធ្យោបាយតែមួយគត់ដែលអនុលោមទៅលើភាពស្មើគ្នានៃប្រជាជនវៀតណាមនិងកម្ពុជា និងអាចបង្កើតទំនាក់ទំនងមិត្តភាពរវាងប្រទេសវៀតណាមនិងប្រទេសកម្ពុជា រវាងប្រជាជនវៀតណាមនិងកម្ពុជា ហើយអាចអនុញ្ញាតឲ្យប្រទេសវៀតណាមនិងប្រទេសកម្ពុជារស់នៅក្នុងភាពជាអ្នកជិតខាងល្អ សន្តិភាពនិងភាពចុះចូលគ្នា ។ ហើយនេះជាមធ្យោបាយតែមួយប៉ុណ្ណោះ ដែលអនុលោមទៅតាមគោលការណ៍មិនចងសម្ព័ន្ធភាព និងផលប្រយោជន៍នៃប្រជាជនលើពិភពលោកនិងនាំទៅរកសន្តិភាពនៅក្នុងតំបន់ ។

ប៉ុន្តែបើសិនជាសាធារណរដ្ឋសង្គមនិយមវៀតណាមនៅតែ

ចបេសមានៈបន្តអនុវត្តនូវសកម្មភាពបង្កបញ្ហា ការរំលោភបំពាន ការឈ្លានពាននិងការបញ្ចូលជាខបសម្ព័ន្ធដើម្បីប្រឆាំងនឹងអធិបតេយ្យកម្ពុជាប្រជាធិបតេយ្យ អ៊ីចឹងពាក្យថា "ចរចា" ដែលបានឃោសនាដោយវៀតណាមគឺគ្មានន័យអ្វីទាំងអស់ ប៉ុន្តែវាគ្រាន់តែជាការបន្តបោកបញ្ឆោត និងទ្រង់ទ្រាយនៃការឈ្លានពាននិងការបញ្ចូលជាខបសម្ព័ន្ធរបស់សារធារណរដ្ឋសង្គមនិយមវៀតណាមដើម្បីប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងត្រូវបានប្រានចោលដោយប្រជាជននៅលើពិភពលោកដែលស្រឡាញ់ភាពយុត្តិធម៌ និងឯករាជ្យភាព ។

**ឯកសារ D៣០៥៦៥**

*ភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៨*

*ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ*

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលិកទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តនៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

"ការិយាល័យព័ត៌មានសាធារណៈ" មានផ្តល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ីរ៉ិ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ជា ជឿន អតីតប្រធានសហករណ៍ភ្នំសំពៅ

កម្ពុជាប្រជាធិបតេយ្យជារបបមួយដែលប្រជាជនខ្មែរនៅទូទាំងប្រទេសបានឆ្លងកាត់ ហើយក៏បានដឹងដែរថាជារបបដែលដឹកនាំដោយមេខ្មែរក្រហមដែលបានធ្វើទារុណកម្ម បង្ខិតបង្ខំឲ្យខ្មែរគ្រប់រូបធ្វើការហួសកម្លាំង ផ្តល់អាហារឲ្យហូបមិនគ្រប់គ្រាន់ជាមួយនឹងការកាប់សម្លាប់យ៉ាងរង្គាល ។ អំពើដ៏ឃោរឃៅនេះបានធ្វើឲ្យប្រជាជនទទួលរងការឈឺចាប់ ភ័យខ្លាច បាត់បង់បងប្អូន ឪពុកម្តាយជាទីស្រឡាញ់ និងបំផ្លាញស្ទើរតែទាំងស្រុងនូវខឿនសេដ្ឋកិច្ចនិងវប្បធម៌របស់ប្រទេសកម្ពុជា ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏មានកម្មាភិបាលខ្មែរក្រហមមានចិត្តសប្បុរសធម៌ជួយដោះស្រាយបញ្ហាប្រជាជនដែរ ។ ជា ជឿន អតីតប្រធានសហករណ៍ភ្នំសំពៅ ក្នុងខេត្តបាត់ដំបងបានជួយយកអសារប្រជាជនជាច្រើនដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងរបស់គាត់ ។

ក្រោយរដ្ឋប្រហារទម្លាក់សម្តេចនរោត្តមសីហនុ ឆ្នាំ១៩៧០ បានធ្វើឲ្យមន្ត្រីរាជការដែលមានមុខតំណែងក្នុងរដ្ឋាភិបាលរបស់ព្រះអង្គនិងបុគ្គលិកឯកជនមួយចំនួនលាឈប់ពីការងារ ។ ចំណែក ជឿន បានបោះបង់ការសិក្សាត្រឹមថ្នាក់ទី៧ ព្រោះតែមានចលនាបះបោរនៅទូទាំងប្រទេស ។ បន្ទាប់មក ជឿន ត្រូវបានរដ្ឋាភិបាល លន់ នល់ បញ្ជូនឲ្យទៅធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាភូមិរំបេក ឃុំព្រៃស្វាយ ស្រុកមោងឬស្សី ខេត្តបាត់ដំបង ។

ក្នុងអំឡុងពេលដែលកងទ័ពខ្មែរក្រហមឡើងកាន់អំណាចនៅខែមិថុនា ឆ្នាំ១៩៧៦ គ្រួសាររបស់ ជឿន ត្រូវបានជម្លៀសឲ្យទៅរស់នៅខេត្តបាត់ដំបង ។ ក្នុងពេលធ្វើដំណើរមកដល់ទីក្រុងភ្នំពេញនៅពេលយប់ ជឿន ត្រូវបានអង្គការឲ្យទៅមើលកុនទិនិងទស្សនាកន្លែងធ្វើការងារមួយចំនួនទៀតនៅទីក្រុងភ្នំពេញ ។ នៅព្រឹកថ្ងៃបន្ទាប់ ទើប ជឿន ត្រូវជិះរថភ្លើងបន្តទៅខេត្តបាត់ដំបង ។ ពេលទៅដល់នៅវេលាម៉ោង៩យប់ អង្គការបានបែងចែកប្រជាជនជា


ជា ជឿន

ក្រុមដោយមានប្រជាជនជម្លៀសចំនួន១០គ្រួសារក្នុងមួយឃុំ ដែលភាគច្រើនមកពីខេត្តកំពត តាកែវ និងកំពង់ស្ពឺ ។ ចំណែក ជឿន រួមជាមួយគ្រួសារនិងប្រជាជន៨គ្រួសារផ្សេងទៀតត្រូវបាន ញ៉ឹម ប្រធានភូមិភាគពាយ័ព្យបែងចែកឲ្យទៅរស់នៅភ្នំសំពៅ ។ នៅក្នុងភូមិ ជឿន ត្រូវអង្គការចាត់តាំងឲ្យធ្វើជាប្រធានសហករណ៍ ភ្នំសំពៅ ដែលមានតា អ៊ុំ ជាគណៈឃុំ និងអាចារ្យ គឹក ជាគណៈឃុំរង ដែលជាអ្នកមូលដ្ឋាន ។ ជឿន មានភារកិច្ចរៀបចំម្ហូបអាហារ និងសង់ផ្ទះចំនួន៦០ខ្នងសម្រាប់ប្រជាជនដែលទើបនឹងរៀបការថ្មី ។ ប្រជាជននៅក្នុងសហករណ៍ទាំងអស់ត្រូវធ្វើស្រែនិងមានរបបអាហារស្មើគ្នាក្រោមការចាត់ចែងរបស់អង្គការ ។ ប៉ុន្តែទោះជាប្រជាជនខំធ្វើការងារយ៉ាងណាក៏ដោយ ក៏នៅរដូវវស្សានៅតែខ្វះអាហារហូបដដែល ដោយអង្គការប្រាប់ថា ធ្វើស្រូវមិនបានផលទៅតាមការកំណត់របស់គោលការណ៍ថ្នាក់លើមួយហិកតា៣តោនទេ ។ ដោយសារពុំមានស្បៀងគ្រប់គ្រាន់ ជឿន បានចាត់តាំងឲ្យកងតា១ដាំបន្លែ ត្រឡាច ឃ្លោក ននោង ល្ពៅ ត្រសក់ ចំណែកកងប្រុស១ធ្វើស្ករត្នោតឲ្យបាន១០ទៅ១៥គីឡូក្រាម ក្នុងមួយថ្ងៃ ដើម្បីយកទៅជួយផ្គត់ផ្គង់រោងបាយសហករណ៍បន្ថែម ។

នៅដើមឆ្នាំ១៩៧៨ ជឿន បានប្រមូលកម្លាំងប្រជាជននៅក្នុងសហករណ៍ឲ្យលើកទំនប់ «កំពីងពួយ» ក្រោមផែនការកំណត់របស់ថ្នាក់លើ ។ នៅការដ្ឋាន ជឿន តែងតែមានចិត្តសប្បុរសចំពោះប្រជាជនដែលខ្វះខាត ។ ក្នុងឆ្នាំដដែល គាត់បានជួយផ្លាស់ប្តូរការងាររបស់មេឃុំម្នាក់ឈ្មោះតា រ៉ាក់ ដែលត្រូវថ្នាក់លើដកហូតតួនាទីជាមេឃុំឲ្យទៅចាំចម្ការក្រូចថ្លុងវិញ ។ ដោយការអាណិតអាសូរតា រ៉ាក់ ក៏ដូចជាប្រជាជនផ្សេងទៀត ជឿន តែងតែលួចយកអង្ករ ត្រីងៀត និងស្ករត្នោតទៅឲ្យអ្នករស់នៅក្នុងការដ្ឋាន ។ ការងារនៅទីនេះគឺតម្រូវប្រជាជនធ្វើការធ្ងន់ធ្ងរស្ទើរតែគ្មានពេលសម្រាក លើសពីនេះទៅទៀតហូបមិនគ្រប់គ្រាន់ដែលធ្វើឲ្យចាស់ៗក្នុងភូមិនាំគ្នាមកតវ៉ាប្រាប់ ជឿន អំពីបញ្ហានេះគ្រប់ៗគ្នា ។ បន្ទាប់ពីស្តាប់ពួ ជឿន បានបញ្ជាឲ្យចុងភៅដាំបាយឲ្យប្រជាជនហូបក្នុងមួយសប្តាហ៍ម្តង ថែមទាំងចែកក្រណាត់ដើម្បីកាត់ខោអាវបានស្លៀកពាក់គ្រប់គ្នាទៀតផង ។ នៅឆ្នាំដដែល ជឿន បានជួយស្ត្រីម្នាក់ដែលរត់ចេញមកពីតំបន់៤ដោយអនុញ្ញាតឲ្យមករស់នៅក្នុងសហករណ៍ ព្រមទាំងលួចផ្តល់អាហារឲ្យហូបជារៀងរាល់ថ្ងៃ បន្ទាប់មកទើបបញ្ជូនទៅរស់នៅជាមួយប្រជាជនក្នុងកងចល័តភ្នំសំពៅ ។ លើសពីនេះ ជឿន ក៏បានជួយធានាបុរសម្នាក់ឈ្មោះ ហឿន ជានិរសាររបស់តា អន អនុឃុំភ្នំសំពៅដែលត្រូវថ្នាក់លើចោទកាន់ថាក្បត់ ឲ្យរួចផុតពីការសម្លាប់ដែរ ។

នៅចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមវាយចូលមកដល់សហករណ៍ភ្នំសំពៅ ជឿន និងប្រជាជនបានរត់ភៀសខ្លួនទៅរស់នៅដំរីស្រះកែវជាប់ព្រំដែនថៃ ។ នៅពេលនោះ ជឿន បានផ្តល់អាហារដល់នារី ហឿន ដែលមានផ្ទៃពោះរហូតបានជួបជុំបងប្អូន ។ គាត់ក៏បានផ្តល់សម្លៀកបំពាក់ អង្ករទៅឲ្យក្មេងស្រី និងសង្គ្រោះក្មេងប្រុសមានជំងឺអាយុ១០ឆ្នាំម្នាក់ដែលត្រូវឪពុកម្តាយបោះបង់ចោលនៅក្នុងព្រៃ រួចបញ្ជូនទៅព្យាបាលនៅពេទ្យកាកបាទក្រហម ។

អំឡុងពេលដែលមានការវាយប្រយុទ្ធគ្នានៅតំបន់ពាយ័ព្យ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជឿន បានទៅរស់នៅក្នុងដំរីស្រះកែវមួយរយៈ ទើបវិលត្រឡប់មករស់មកនៅក្នុងសហករណ៍ចាស់របស់គាត់វិញ ។ សព្វថ្ងៃនេះ ជឿន មានតួនាទីជាទីប្រឹក្សាឃុំទ្រាំង ស្រុកកំរៀង ខេត្តបាត់ដំបង ។

**ឌា ធីតា**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀត ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ស៊ិន សុធីតា**

# របាយការណ៍ស្តីអំពីការបញ្ចាំងភាពយន្តឯកសារ និងការពិភាក្សា តាមមូលដ្ឋានក្នុងស្រុកស្ទោង ខេត្តកំពង់ធំ

ក្រុមស្រាវជ្រាវឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការប្រជុំនិងបញ្ចាំងភាពយន្តឯកសារនៅឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ។ គោលបំណងនៃការប្រជុំនោះ គឺដើម្បីជម្រាបដល់អ្នកភូមិអំពីដំណើរការវិវត្តរបស់សាលាក្តីខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាពិសេសដើម្បីផ្តល់ដំណឹងដល់ប្រជាជនអំពីការបើកសវនាការលើកដំបូងលើករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ ក្រុមយើងខ្ញុំបានសម្រេចជ្រើសរើសយកតំបន់នេះដោយសារហេតុផលពីរយ៉ាង ៖ ទីមួយ ឃុំនេះមានទីតាំងនៅក្នុងស្រុកស្ទោង ដែលជាស្រុកកំណើតរបស់ ឌុច ។ ទីពីរ ក្រុមយើងមិនដែលធ្លាប់អញ្ជើញប្រជាជនភូមិនេះដើម្បីទៅទស្សនាអង្គជំនុំជម្រះអង្គសាមញ្ញម្តងណាទេ ។ យើងមានបំណងចង់ឲ្យប្រជាជនចូលរួមពាក់ព័ន្ធក្នុងដំណើរការសាលាក្តីខ្មែរក្រហម ហើយនិងចូលរួមការសិក្សាអំពីមជ្ឈមណ្ឌលឯកសាររបស់យើង ។

បន្ទាប់ពីមកដល់ឃុំនេះភ្លាម ដំបូងក្រុមយើងខ្ញុំបានទៅជួបជាមួយមេឃុំឈ្មោះ មិន ជាត និងសមាជិកក្រុមប្រឹក្សាឃុំ ដើម្បីជម្រាបពួកគាត់អំពីសកម្មភាពគម្រោងរបស់យើង និងសុំជំនួយពីគាត់ក្នុងការទៅអញ្ជើញប្រជាពលរដ្ឋឲ្យចូលរួមប្រជុំជាមួយ ។ បន្ទាប់មក ថ្នាក់ដឹកនាំឃុំបានឲ្យដំបូន្មានថាឲ្យទៅបញ្ចាំងខ្សែភាពយន្តនៅវត្តហាប ដែលមានទីតាំងនៅជិតទីស្នាក់ការឃុំ និងសាលាបឋមសិក្សាមួយដែលផ្តល់ទីតាំងយ៉ាងងាយស្រួលដល់កិច្ចការបញ្ចាំងកុនរបស់ក្រុមយើង ។

នៅថ្ងៃបន្ទាប់ទី២៧ ខែមករា ក្រុមការងារបានមកដល់ភូមិនោះ ហើយបានរៀបចំកិច្ចប្រជុំជាមួយប្រជាជនក្នុងភូមិ ។ ដំបូងក្រុមយើងបានចែកឯកសារមួយចំនួនទៅអ្នកភូមិដូចជា ទស្សនាវដ្តីស្វែងរកការពិត ខិតបណ្ណរូបថតនៃការតាំងពិព័រណ៍ដែលមានចំណងជើងថា «ហ្គុនណារ៉ ថាននរកកម្ពុជាប្រជាធិបតេយ្យ» សេចក្តីប្រកាសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីអំពីការបើកសវនាការ ឌុច និងបញ្ជីសំណួរដើម្បីធ្វើការវាយតម្លៃអំពីដំណើរការតុលាការ ។ ប្រជាជនដែលបានចូលរួមមានដូចជាដូនជី ប្រធានភូមិ ក្មេងៗ និងសមាជិកក្រុមប្រឹក្សាឃុំ ។ ភាគច្រើននៃអ្នកចូលរួមទាំងនោះជាស្ត្រីមានវ័យចំណាស់ៗ ។ នៅខណៈពេលដែលសិស្សសាលាចេញលេង វាបានផ្តល់អំណោយផលដល់ពួកគេក្នុងការមកមើលការបញ្ចាំងភាពយន្តឯកសារនេះដែរ ។ ក្រុមយើងខ្ញុំប៉ាន់ប្រមាណថាប្រជាជនចូលរួមមានចំនួនពី ៦០ ទៅ៧០ នាក់ ។


អ្នកភូមិអានខិតបណ្ណថាននរកកម្ពុជាប្រជាធិបតេយ្យ និង ទស្សនាវដ្តីស្វែងរកការពិត

នៅដើមដំបូងនៃកិច្ចប្រជុំ ក្រុមយើងខ្ញុំបានធ្វើការណែនាំខ្លួននិងប្រាប់អំពីគោលបំណងរបស់យើងទៅកាន់អ្នកភូមិទាំងអស់ ។ ក្រោយមក យើងបាននិយាយរៀបរាប់អំពីខ្សែភាពយន្តដែលនឹងបញ្ចាំងមានចំណងជើងថា «ដំណើរឆ្ពោះទៅរកយុត្តិធម៌» ។ ខ្សែភាពយន្តនេះសំខាន់គឺបញ្ចាំងពីការពិភាក្សាអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងដំណើរការកាត់ទោស ។ ខ្សែភាពយន្តនេះមានរយៈពេល៣០នាទី បន្ទាប់មកទើបយើងចាប់ផ្តើមធ្វើការពិភាក្សា ។ ក្រុមយើងខ្ញុំបានពិភាក្សាអំពីសំណួរមួយចំនួនទៅកាន់អ្នកភូមិដូចជា៖ តើមានដែលឮអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ? តើដឹងអ្វីខ្លះអំពីអង្គជំនុំជម្រះនេះ? ខណៈនោះ បុរសវ័យចំណាស់ម្នាក់ដែលអង្គុយជួរមុខគេបានឆ្លើយថា គាត់បានឮអំពីសាលាក្តីខ្មែរក្រហមតាមវិទ្យុ ហើយថា ឌុច ធ្លាប់រស់នៅខេត្តកំពង់ធំ ប៉ុន្តែគាត់មិនដែលឃើញមុខទេ ។

ក្រោយមក ក្រុមយើងខ្ញុំបានបកស្រាយអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងការចាប់ខ្លួនមេដឹកនាំខ្មែរក្រហម ។ យើងនិយាយលម្អិតអំពីការចាប់ខ្លួន ឌុច ហើយប្រាប់អ្នកភូមិអំពីសវនាការដំបូងរបស់ ឌុច ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែកុម្ភៈ ខាងមុខនេះ ហើយនឹងផ្តោតទៅលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងវិធានការការពារដល់សាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណី ។ យើងក៏បានជម្រាបប្រជាជនឲ្យដឹងផងដែរថា សូមត្រៀមខ្លួនដើម្បីតាមដានអំពីការវិវត្តរបស់តុលាការខ្មែរក្រហមបន្តទៀត តាមរយៈសារព័ត៌មាននានា ។


អ្នកភូមិទស្សនាភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

អ្នកចូលរួមទាំងអស់មានការចាប់អារម្មណ៍នឹងព័ត៌មានដែលយើងផ្តល់ជូន ហើយមួយចំនួនបានសួរសំណួរមកកាន់ក្រុមយើង ។ ស្ត្រីម្នាក់មានចម្ងល់ថាតើអង្គជំនុំជម្រះនោះនឹងមានការផ្សាយបន្តផ្ទាល់ឬទេ? ក្រុមយើងខ្ញុំបានបកស្រាយប្រាប់គាត់ថា «សវនាការសាធារណៈ» និងសារសំខាន់នៃការរក្សាការសម្ងាត់ក្នុងដំណើរការសវនាការ ។ តុលាការជាអ្នកធ្វើការសេចក្តីសម្រេចថាត្រូវផ្សាយផ្ទាល់ឬអត់ ។ ក្រោយមកអ្នកភូមិទាំងនោះនាំគ្នាទៅបំពេញបែបបទពាក្យបណ្តឹងដែលក្រុមយើងខ្ញុំជាអ្នកជួយដល់ពួកគាត់អំពីដំណើរការដាក់ពាក្យបណ្តឹងនោះ ។ ស្ត្រីម្នាក់ចង់ដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហម ព្រោះឪពុកក្មេករបស់គាត់ត្រូវបានសម្លាប់ក្នុងរបបខ្មែរក្រហម ។ ប្រជាជនមួយចំនួនទៀតចង់ដឹងថាតើតុលាការមានផ្តល់សំណងជាលុយដល់ប្រជាជនកម្ពុជាដូចជាកសាងសាលារៀន ផ្លូវថ្នល់ ឬទេ ។

ក្រុមយើងខ្ញុំសង្កេតឃើញថា ប្រជាជនហាក់បីដូចជាទទួលព័ត៌មានតិចតួចណាស់អំពីដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សំណួរមួយចំនួនដែលប្រជាជនច្រើនសួរមានដូចជា តើនរណាខ្លះនិងមនុស្សប៉ុន្មាននាក់ដែលតុលាការត្រូវធ្វើការកាត់ទោស? ហើយមេដឹកនាំខ្មែរក្រហមប៉ុន្មាននាក់ដែលបានស្លាប់ ហើយពួកគេគឺជានរណា? តើ ឌុច មានស្រុកកំណើតទៅកន្លែងណាពិតប្រាកដក្នុងស្រុកស្ទោងនេះ?

នៅចុងបញ្ចប់នៃកិច្ចប្រជុំនេះ ស្ត្រីម្នាក់ឈ្មោះ ផេ ហាន បានស្នើក្រុមយើងខ្ញុំប្រកាសស្វែងរកអ៊ំរបស់គាត់ដែលបានបាត់ខ្លួនក្នុងឆ្នាំ១៩៧០ ។ គាត់បានប្រាប់យើងថា អ៊ំរបស់គាត់ឈ្មោះ ហ៊ុន ផាត មានស្រុកកំណើតនៅភូមិលាបតង ឃុំទ្រា ស្រុកស្ទោង ។

ក្នុងឆ្នាំ១៩៧៥ គាត់ត្រូវបានបញ្ជូនទៅធ្វើការនៅភ្នំពេញ ហើយក៏បាត់ដំណឹងរហូតតាំងពីពេលនោះមក ។ គាត់បានបន្តទៀតថា កាលពីឆ្នាំ១៩៩៩ មានអ្នករកស៊ីដូរញដូរម្នាក់បានប្រាប់គាត់ថា អ៊ំរបស់គាត់ឥឡូវនេះរស់នៅក្រុងព្រះសីហនុ តែគាត់មិនដែលទទួលដំណឹងអ្វីទៀតទេតាំងពីពេលនោះមក ។

អ្នកភូមិមានការពេញចិត្តនឹងការបញ្ចាំងខ្សែភាពយន្តអំពីរបបខ្មែរក្រហមនិងដំណើរការកាត់ក្តីខ្មែរក្រហមក្នុងភូមិរបស់គាត់ ។ អ្នកភូមិភាគច្រើនយល់ថា នេះជាវិធីដ៏មានប្រសិទ្ធភាពបំផុតដើម្បីឲ្យក្មេងជំនាន់ក្រោយបានរៀនសូត្រពីរបបខ្មែរក្រហម ។ អ្នកភូមិម្នាក់ឈ្មោះ ឡាវ រស់ មកពីភូមិសំកោក បាននិយាយថា ឥឡូវក្មេងៗក្នុងភូមិនេះជឿនូវអ្វីដែលគាត់និយាយប្រាប់អំពីរបបខ្មែរក្រហមហើយ ដោយសារតែបានឃើញខ្សែភាពយន្តរបស់ក្រុមយើងបញ្ចាំង ។ រស់ បាននិយាយថា គាត់ជាសមាជិកក្រុមសិល្បៈខ្មែរក្រហមតាំងពីឆ្នាំ១៩៧២-៧៣ ។ ក្រោយមក គាត់ត្រូវបានបញ្ជូនឲ្យទៅសមរភូមិនៅកំពង់ចាមរហូតដល់ឆ្នាំ១៩៧៥ ។ អំឡុងពេលនោះគាត់ត្រូវបានបង្ហាត់និងឃោសនាអំពីកិច្ចការបដិវត្តន៍ ក្រោយមកគាត់ជាប្រជាជនសាមញ្ញនៅក្នុងសហករណ៍ ។ នៅសហករណ៍ គាត់ត្រូវធ្វើការយ៉ាងខ្លាំងដូចប្រជាជនដទៃទៀតដែរ ហើយទទួលរបបអាហារមិនគ្រប់គ្រាន់ទេ ទោះបីជាគាត់ជាប្រជាជនមូលដ្ឋានក៏ដោយ ។ ជីវិតមានការលំបាកនិងភ័យខ្លាចជាប់ជាប្រចាំ ។

បន្ថែមទៅលើព័ត៌មានដែលយើងផ្តល់ឲ្យអ្នកភូមិអំពីតុលាការខ្មែរក្រហម ការបញ្ចាំងកុនរបស់យើងនេះនឹងផ្តល់នូវចំណេះដឹងដល់ក្មេងជំនាន់ក្រោយផងដែរ ។ មេភូមិទទាឈ្មោះ ម៉ាក់ នី បានប្រាប់ក្រុមយើងថា គាត់មានការសប្បាយចិត្តដោយសារប្រជាជនយល់ដឹងអំពីការរំលោភសិទ្ធិមនុស្សកាលពីអតីតកាល ។ គាត់បាននិយាយថា «តាមការប្រជុំលើកនេះ ខ្ញុំជឿថា នៅថ្ងៃខាងមុខនឹងមានអ្នកចេះដឹងការពារការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរនេះ ដើម្បីកុំឲ្យកើតមានឡើងទៀត» ។ នី បានបន្ថែមទៀតថា ប្រសិនបើតុលាការនេះប្រកបទៅដោយជោគជ័យនោះនឹងក្លាយជាគំរូមួយដ៏សំខាន់សម្រាប់មេដឹកនាំ និងក្មេងជំនាន់ក្រោយ ។ គាត់បានបន្ថែមយោបល់ទៀតថា «ប្រជាជនភូមិខ្ញុំមិនសូវបានដឹងពីដំណើរការរបស់តុលាការខ្មែរក្រហមទេ បើសិនជាអាច ខ្ញុំចង់ឲ្យប្រជាជនភូមិខ្ញុំមានឱកាសដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហមដែរ» ។ ចុងក្រោយគាត់បន្ថែមថា «បន្ទាប់ពីបានចូលរួមក្នុងការបញ្ចាំងកុននេះ ខ្ញុំសង្ឃឹមថា អ្នកភូមិនឹងចង់តាមដានដំណឹងអំពីដំណើរការនេះតទៅទៀត» ។

នេះគឺជាលើកទីមួយហើយដែលការបញ្ចាំងកុននិងការពិភាក្សាបានធ្វើឡើងនៅក្នុងឃុំទ្រានេះ ហើយដែលមិនធ្លាប់មានអ្នកភូមិណាម្នាក់បានទៅចូលរួមស្តាប់ក្នុងសវនាការសាលាក្តីខ្មែរក្រហមម្តងណាទេ ។ អ្នកភូមិនៅទីនេះបានទទួលព័ត៌មានតិចតួចណាស់ទាក់ទងទៅនឹងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហេតុដូចនេះអ្នកភូមិនេះមានការសប្បាយចិត្តយ៉ាងខ្លាំងក្នុងការទទួលព័ត៌មានដែលក្រុមយើងផ្តល់ជូន ។ អ្នកភូមិបានចូលរួមក្នុងការពិភាក្សានេះ ដោយចោទសួរជាសំណួរនិងចែករំលែកទស្សនៈគ្នា ។ ខ្សែភាពយន្តរបស់យើងបានទទួលនូវការចាប់អារម្មណ៍ពីសំណាក់អ្នកភូមិ ហើយជំរុញឲ្យមានការពិភាក្សាអំពីបញ្ហាដំណើរការសាលាក្តី ។ យោងតាមការសម្ភាសន៍ជាមួយអ្នកភូមិមួយចំនួនបានឲ្យដឹងថា អ្នកភូមិជាច្រើនយល់ឃើញថា វាមានសារសំខាន់ក្នុងការបង្ហាញរូបភាពអំពីរបបខ្មែរក្រហមទើបក្មេងៗអាចយល់ដឹងអំពីរបបនោះ ។ តាមរយៈការពិភាក្សានិងការសម្ភាសន៍ជាមួយអ្នកភូមិម្នាក់ៗបានឲ្យដឹងថា អ្នកភូមិមានចំណាប់អារម្មណ៍បំផុតអំពីព័ត៌មានដែលទាក់ទងទៅនឹងការបំពេញពាក្យបណ្តឹង ហើយចង់ដឹងអំពីការកាត់ទោសខ្មែរក្រហម ព្រោះអ្នកភូមិភាគច្រើនសុទ្ធតែបាត់បង់សាច់ញាតិកាលពីជំនាន់ខ្មែរក្រហម ហើយចង់ធ្វើអ្វីមួយដើម្បីទទួលសំណង ដោយសារខ្លួនបានបាត់បង់ ។ ទោះបីយ៉ាងណា ក៏មានអ្នកភូមិមួយចំនួនមានការលំបាកក្នុងការធ្វើដំណើរទៅទីក្រុងភ្នំពេញ ដើម្បីចូលរួមដំណើរការសាលាក្តី ដោយសារគាត់ខ្វះមធ្យោបាយ ។ អ្នកភូមិដែលយើងបានជួបសុទ្ធតែចង់មកមើល និងធ្វើជាសាក្សីដល់ដំណើរការកាត់ទោសខ្មែរក្រហមព្រោះតែអ្នកភូមិទាំងអស់នោះចាត់ទុកខ្លួនឯងជាជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ចុងបញ្ចប់ អ្នកភូមិពីរបីនាក់ស្នើសុំជំនួយពីក្រុមយើងខ្ញុំដើម្បីឲ្យពួកគាត់មានឱកាសទៅមើលសវនាការកាត់ទោស ។ **ស៊ឹរ សាទីណា**

# បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ទៅកាន់អង្គការសហប្រជាជាតិ

*ភ្នំពេញ ថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៩*

*ក) អត្ថបទដែលបានផ្សព្វផ្សាយនៅថ្ងៃទី៣១ ខែធ្នូ តាមរយៈទូរលេខពី អៀង សារី ទៅកាន់ប្រធានក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ៖*

*លោកប្រធាន ខ្ញុំមានកិត្តិយសណាស់ដើម្បីជម្រាបជូនក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិថា ប្រទេសវៀតណាមកំពុងតែធ្វើសកម្មភាពរំលោភបំពាននិងលុកលុយកាន់តែខ្លាំងឡើងៗប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ ជាពិសេស ៖*

*១) នៅក្នុងខេត្តរតនគិរី ស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា នៅថ្ងៃទី២១, ២៥, ២៧, ២៨, ២៩ និងថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៨ កងពលលេខ៣០៧ និង៣០៤ របស់វៀតណាមបានវាយប្រហារនិងសម្រុកចូលយ៉ាងជ្រៅចូលក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យតាមបណ្តោយផ្លូវជាតិលេខ១៩ រហូតដល់អូរយ៉ាដាវដែលស្ថិតនៅក្នុងស្រុកអណ្តូងទឹក ។ សព្វថ្ងៃនេះ គេកំពុងតែព្យាយាមវាយសម្រុកចូលមកទៀត ។*

*២) នៅក្នុងទិសដៅដូចគ្នាជាមួយនឹងការវាយប្រហារទាំងនេះនៅក្នុងខេត្តរតនគិរី យន្តហោះវៀតណាមរួមជាមួយសូវៀតជាច្រើនគ្រឿងបានទម្លាក់គ្រាប់បែកម្តងទៀតនៅក្នុងទីរួមស្រុកវឺនសៃនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៧៨ ទីរួមស្រុកអណ្តូងទឹក និងទីតាំងនៃស្រុកបានលុងនៅថ្ងៃទី២៨ និង ២៩ ខែធ្នូ ឆ្នាំ១៩៧៨ ។*

*៣) នៅក្នុងខេត្តក្រចេះ ថ្ងៃទី២៥, ២៦, ២៧, ២៨, ២៩ និង ៣០ ខែធ្នូ ឆ្នាំ១៩៧៨ កងពលលេខ៣ និងលេខ៥របស់វៀតណាមបានវាយប្រហារនិងសម្រុកចូលយ៉ាងជ្រៅក្នុងទឹកដីកម្ពុជាតាមបណ្តោយផ្លូវជាតិលេខ៧ អតីតផ្លូវជាតិលេខ១៣ ដែលស្ថិតនៅខាងក្រោយទីរួមស្រុកស្នួល ។ បច្ចុប្បន្ន គេកំពុងតែព្យាយាមវាយសម្រុកចូលទីរួមស្រុកស្នួលនៅក្នុងទឹកដីកម្ពុជា ។ នៅអំឡុងពេលនៃការរំលោភបំពានរបស់គេប្រឆាំងទៅនឹងប្រទេសកម្ពុជា កងទ័ពវៀតណាមបានធ្វើអំពើយ៉ាងសាហាវឃោរឃៅបំផុតដូចជា សម្លាប់ កម្ទេច និងដុតអ្វីៗគ្រប់យ៉ាងទាំងអស់ ។ ការវាយឆ្មក់តាមអាកាសរបស់គេបានសម្លាប់ប្រជាជនជាច្រើនក្នុងចំណោមប្រជាជនស៊ីវិល និងបានបំផ្លាញនូវទ្រព្យសម្បត្តិជាច្រើនទៀត ។ នៅពេលដដែលនោះ ព្រោះតែការស្រេកឃ្លាន កងទ័ពវៀតណាមបានប្លន់យកអង្ករ គោក្របី មាន់ ទា និងទ្រព្យសម្បត្តិដទៃទៀតរបស់ប្រជាជនកម្ពុជា ។ កងទ័ពវៀតណាមបានបំផ្លាញនូវអ្វីៗដែលគេមិនអាចយកទៅជាមួយបាន ។*

*នៅក្នុងទីតាំងដទៃទៀតក្នុងខេត្តមណ្ឌលគិរី នៅភូមិភាគបូព៌ានិងនិរតី កងទ័ពវៀតណាមបានចាប់ផ្តើមវាយប្រហារយ៉ាងសាហាវប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ ។ គេបានប្រើយន្តហោះវាយប្រហារប្រភេទ មិុក១៩* (MiG-19) *និង មិុក២១* (MiG-21) *ក៏ដូចជាយន្តហោះទម្លាក់គ្រាប់បែកកង្ហាបួន* (four-engined bombers) *។ ការទំនាក់ទំនងតាមវិទ្យុទៅវិញទៅមករវាងអ្នកបើកយន្តហោះនៃយន្តហោះទម្លាប់គ្រាប់បែកទាំងនេះត្រូវចាប់ខ្លួនបានដោយកងទ័ពបដិវត្តន៍កម្ពុជា ដែលគេបានឲ្យដឹងថា យន្តហោះទម្លាក់គ្រាប់បែកទាំងនេះមួយចំនួនត្រូវបានបើកបរដោយជនជាតិសូវៀត ។ បច្ចុប្បន្នយន្តហោះទម្លាក់គ្រាប់បែកទាំងនេះបានអនុវត្តការវាយឆ្មក់តាមអាកាសដ៏ធ្ងន់ធ្ងរមកលើខេត្តរតនគិរី ស្ទឹងត្រែង និងខេត្តមណ្ឌលគិរី ភូមិភាគបូព៌ានៃខេត្តកំពង់ចាម និងជាពិសេសចន្លោះរវាងទីរួមស្រុកស្នួល និងខេត្តក្រចេះ ។*

*ដោយសារសកម្មភាពរំលោភបំពាននិងឈ្លានពានចូលក្នុងប្រទេសកម្ពុជា វៀតណាមមានគោលបំណងគ្រប់គ្រងលើប្រទេសកម្ពុជានិងវាតទីនិយមនៅលើតំបន់អាស៊ីអាគ្នេយ៍ដើម្បីសម្រេចបានមហិច្ឆតាគ្រប់គ្រងតំបន់របស់វា និងនៅពេលជាមួយគ្នានោះដែរនឹងដើម្បីសម្រេចបាននូវមហិច្ឆតាវាតទីនិយមក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានប្រទេសសូវៀតជាមហាអំណាច ។*

*ក្រោយឆ្នាំ១៩៧៨ យុទ្ធសាស្ត្រដើម្បីយកឈ្នះសង្គ្រាមឈ្លានពានរបស់វាប្រឆាំងនឹងប្រទេសកម្ពុជា វៀតណាមបានធ្វើឲ្យវាកាន់តែប្រសើរឡើង និងធ្វើការផ្លាស់ប្តូរសង្គ្រាមនេះ ។ ដោយអាស្រ័យទៅលើកម្លាំងទ័ពរបស់ខ្លួនផ្ទាល់ ប្រជាជនកម្ពុជា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនិងកងទ័ពបដិវត្តន៍កម្ពុជាបានកេណ្ឌកម្លាំងទាំងអស់ដើម្បីការពារកម្ពុជាប្រជាធិបតេយ្យ ដែលជាប្រទេស*

ឯករាជ្យ សន្តិភាព អព្យាក្រឹត្យ និងមិនចូលបក្សសម្ព័ន្ធជារៀងរហូត ។ ប៉ុន្តែ នៅពេលជាមួយគ្នានេះ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យគួរតែទាក់ទាញការចាប់អារម្មណ៍របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងអង្គការដែលទាក់ទង ក៏ដូចជាប្រទេសទាំងអស់ដែលស្រឡាញ់យុត្តិធម៌និងសន្តិភាពឲ្យដឹងពីការគំរាមគំហែងដ៏ធ្ងន់ធ្ងរទាក់ទងនឹងសន្តិភាព សុវត្ថិភាព ឯករាជ្យ និងស្ថិរភាពនៅអាស៊ីអាគ្នេយ៍និងនៅអាស៊ីដែលបង្កឡើងដោយប្រទេសវៀតណាមនិងសហភាពសូវៀតនៅក្នុងការរំលោភបំពានយ៉ាងធ្ងន់ធ្ងររបស់គេប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ ។ ដើម្បីបញ្ចប់សកម្មភាពរំលោភបំពាន ការវាតទីនិយម ការបញ្ចូលជាខបសម្ព័ន្ធ និងការគំរាមកំហែងដែលបង្កឡើងដោយប្រទេសវៀតណាមក៏ដូចជាសហភាពសូវៀត រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានអំពាវនាវទៅកាន់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងអង្គការដែលទាក់ទងនិងប្រទេសទាំងអស់ដែលស្រឡាញ់យុត្តិធម៌និងសន្តិភាពដើម្បីចាត់វិធានការដូចខាងក្រោម ៈ

១) ផ្តន្ទាទោសប្រទេសវៀតណាមសម្រាប់ការរំលោភបំពានរបស់វាប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ និងទាមទារឲ្យប្រទេសវៀតណាមបញ្ឈប់ការរំលោភបំពានរបស់វាប្រឆាំងនឹងឯករាជ្យកម្ពុជា បញ្ចប់មហិច្ឆតាលេបយកប្រទេសកម្ពុជា និងគោរពឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដីនៃកម្ពុជាប្រជាធិបតេយ្យ និងសិទ្ធិរបស់ប្រជាជនកម្ពុជាដើម្បីសម្រេចជោគវាសនារបស់ខ្លួនឯងផ្ទាល់ ។

២) បញ្ឈប់នូវរាល់ជំនួយខបត្ថម្ភនិងជំនួយការទាំងអស់ទៅដល់ប្រទេសវៀតណាម ធ្វើដូច្នេះទើបវាមិនអាចពង្រីកកងទ័ពដើម្បីរំលោភបំពានប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ ។

៣) ផ្តល់ការគាំទ្ររបស់គេចំពោះការតស៊ូរបស់កម្ពុជាប្រជាធិបតេយ្យ ។

ខ្ញុំមានកិត្តិយសដើម្បីស្នើសុំលោកប្រធានថា ទូរលេខនេះបានបញ្ជូនទៅជាឯកសារសម្រាប់ក្រុមប្រឹក្សាសន្តិសុខ ។ វាជាការសម្រេចចិត្តដ៏ខ្ពង់ខ្ពស់បំផុត ។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨ ហត្ថលេខា អៀង សារី អនុរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងការបរទេសនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

១) អត្ថបទដែលបានផ្សព្វផ្សាយនៅថ្ងៃទី១ ខែមករា តាមរយៈទូរលេខពី អៀង សារី ទៅកាន់ប្រធានក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ៈ

ខាងក្រោមនេះជាទូរលេខរបស់ខ្ញុំ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨ ផ្ញើទៅកាន់ក្រុមប្រឹក្សាសន្តិសុខ ខ្ញុំមានកិត្តិយសណាស់ក្នុងការជម្រាបលោកថា ប្រទេសវៀតណាមកំពុងតែធ្វើសង្គ្រាមរំលោភបំពានកាន់តែខ្លាំងឡើងៗប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ ។ សកម្មភាពរំលោភបំពានយ៉ាងឃោរឃៅរបស់វៀតណាមបានបំពាន ទៅលើឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដីនៃកម្ពុជាប្រជាធិបតេយ្យ និងគំរាមកំហែងទៅលើសន្តិភាព សុវត្ថិភាព ឯករាជ្យ និងស្ថិរភាពនៅអាស៊ីអាគ្នេយ៍ និងបណ្តាប្រទេសដទៃទៀត ។

ដោយហេតុថាវៀតណាមបានបំពានរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិនិងច្បាប់អន្តរជាតិដោយឥតអៀនខ្មាស់ ជំនួសឲ្យរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ខ្ញុំត្រូវតែស្នើសុំឲ្យមានការកោះប្រជុំក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជាបន្ទាន់ដើម្បីបញ្ឈប់ការរំលោភបំពានរបស់វៀតណាមនិងចាត់វិធានការជាបន្ទាន់ ដើម្បីយើងអាចបញ្ចប់ការឈ្លានពាននេះ និងគោរពនូវឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដីនៃកម្ពុជាប្រជាធិបតេយ្យ និងសិទ្ធិរបស់ប្រជាជនកម្ពុជាក្នុងការសម្រេចចិត្តលើជោគវាសនារបស់ខ្លួនឯងផ្ទាល់ ។

គណៈប្រតិភូមួយរូបរបស់កម្ពុជាប្រជាធិបតេយ្យនឹងមកដល់ទីក្រុងញូវយ៉កនៅសប្តាហ៍ក្រោយ ដើម្បីបំភ្លឺទៅដល់ក្រុមប្រឹក្សាសន្តិសុខ និងបញ្ជាក់លើបញ្ហានេះ ។ នេះជាការសម្រេចចិត្តដ៏ខ្ពង់ខ្ពស់បំផុត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩

ហត្ថលេខា

អៀង សារី

អនុរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស
នៃកម្ពុជាប្រជាធិបតេយ្យ ។

**ឯកសារD៣០៩៦១**

# ការបង្ហាញឱ្យឃើញពីភាពរន្ធត់ក្នុងរបប ប៉ុល ពត តាមរយៈកញ្ចក់ម៉ាស៊ីនថត

អ្នកថតរូប ហូ វ៉ាន់ តាយ បច្ចុប្បន្នមានអាយុ៧៦ឆ្នាំ បានធ្វើដំណើរមកប្រទេសកម្ពុជាក្នុងអំឡុងហេតុការណ៍សំខាន់ៗពីរនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើបរបស់ប្រទេសកម្ពុជា ដូចជានៅឆ្នាំ ១៩៧៦ នៅពេលដែលប្រទេសកម្ពុជាស្ថិតក្រោមការគ្រប់គ្រងបែបប្រល័យពូជសាសន៍របស់របបខ្មែរក្រហមនិងនៅឆ្នាំ១៩៧៩ នៅពេលដែលកងកម្លាំងវៀតណាមលុកលុយប្រទេសកម្ពុជា ដែលបានបញ្ចប់របបខ្មែរក្រហមនិងភាពសាហាវឃោរឃៅរបស់ខ្មែរក្រហម ។ យោងតាម ហូ គាត់ជាមនុស្សដំបូងម្នាក់ក្នុងចំណោមមនុស្សជាច្រើននាក់ដែលបានរកឃើញគុកទួលស្លែងជាមន្ទីរសន្តិសុខកម្រិតខ្ពស់ក្នុងរបបខ្មែរក្រហម ដែលទទួលខុសត្រូវចំពោះការស្លាប់មនុស្សចំនួន១៤.០០០នាក់ ។ ខ្សែវីដេអូស្តីពីគុកទួលស្លែងរបស់គាត់ត្រូវបានថតនៅខែមករា ឆ្នាំ១៩៧៩ ដែលរួមមានជញ្ជាំងប្រឡាក់ដោយឈាម សត្វមាន់ធាត់ៗកំពុងចឹកស៊ីសាកសពមនុស្ស និងបន្ទប់គុកងងឹតតូចៗ បានផ្តល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានៅចុងខែធ្នូ ឆ្នាំ២០០៨ រួមជាមួយភាពយន្តបណ្ណសារដទៃទៀត ដែលសរុបទាំងអស់ប្រហែល៥០០នាទីសម្រាប់ខ្សែវីដេអូបណ្ណសារ ។ ខ្សែភាពយន្តទាំងនេះផ្តល់ភ័ស្តុតាងដោយឥតប្រកែកបានអំពីភាពរន្ធត់ក្នុងរបប ប៉ុល ពត ។


ហូ វ៉ាន់ តាយ ធ្វើសន្និសីទកាសែតនៅសណ្ឋាគារកាំបូឌីយ៉ាណា

នៅក្នុងបទសម្ភាសន៍ថ្មីៗនេះជាមួយលោក ឡុង ដានី មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងប្រទេសវៀតណាម នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ហូ រំឭកអំពីបទពិសោធន៍របស់គាត់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៦និងឆ្នាំ១៩៧៩ និងខ្សែភាពយន្តដែលគាត់បានផលិតនៅពេលត្រឡប់មកការិយាល័យរបស់គាត់នៅស្ថានីយទូរទស្សន៍ទីក្រុងហូជីមិញ ។ ខ្សែភាពយន្តរបស់គាត់ស្តីពីប្រទេសកម្ពុជា ប្រជាជនកម្ពុជា និងជាពិសេសគុកទួលស្លែង (លេខកូដឈ្មោះ ស-២១ នៅក្រោមរបបខ្មែរក្រហម) ភាគច្រើនចងក្រងជាឯកសារស្តីពីភាពឃោរឃៅ និងសោកនាដកម្មលើប្រទេសកម្ពុជា ប៉ុន្តែមានពីរ-បីករណីដែលបង្ហាញពីការរស់ឡើងវិញរបស់ប្រទេសកម្ពុជាផងដែរ ។

នៅឆ្នាំ១៩៧៦ ហូ ស្ថិតក្នុងវ័យជាង៤០ឆ្នាំ បានធ្វើដំណើរមកកាន់ប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលជាប្រទេសជិតខាងតាមការអញ្ជើញជាផ្លូវការមួយ ។ ការមកដល់ជាមួយក្រុមអ្នកយកព័ត៌មានវៀតណាម ហូ រំឭកឡើងវិញថាគាត់ត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅពីមន្ត្រីមួយចំនួននៅក្នុងរាជធានីភ្នំពេញ ។ ទោះបីយ៉ាងណាក៏ដោយ អ្វីៗបានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។ ក្នុងអំឡុងពេលស្នាក់នៅរបស់គាត់ដែលមានរយៈពេលជាង២សប្តាហ៍ គាត់រួមជាមួយក្រុមអ្នកយកព័ត៌មានដទៃទៀតបានស្ថិតក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងក្នុងការធ្វើដំណើរនិងធ្វើការងាររបស់ពួកគាត់ ។ កន្លែងស្នាក់នៅរបស់ពួកគាត់ត្រូវបានយាមល្បាតដោយកម្មាភិបាលខ្មែរក្រហមពីរនាក់ ហើយពួកគាត់មិនអាចចាកចេញបានទេប្រសិនគ្មានរថយន្តមកទទួលពួកគាត់ និងដឹកពួកគាត់ទៅកន្លែងដែលបានកំណត់ទុកជាមុនឡើយ ។ យោងតាម ហូ ប៉ុល ពត ចង់ឲ្យគាត់និងក្រុមអ្នកយកព័ត៌មានទាំងនោះផ្សព្វផ្សាយព័ត៌មាន

ថាចាប់តាំងពីការកាន់កាប់របស់ខ្លួននៅឆ្នាំ១៩៧៥ ប្រទេសកម្ពុជា និងប្រជាជនមានស្ថិរភាពនិងជឿនលឿន ។ តាមពិតទៅ អ្វីដែល ហូ ឃើញផ្ទាល់ភ្នែកគឺលំនៅដ្ឋានត្រូវបានបោះបង់ចោលនៅក្នុងទីក្រុងភ្នំពេញ អ្នកធ្វើការប្រកបដោយភាពភ័យខ្លាចក្នុងសណ្ឋាគារខេត្តសៀមរាប និងអាងក្រពើ ដែលចិញ្ចឹមដោយឲ្យស៊ីសាកសពមនុស្ស (ប្រហែលជាមេដឹកនាំខ្មែរក្រហមចូលចិត្តចិញ្ចឹមក្រពើ) ។ ទោះបីយ៉ាងក៏ដោយ នៅពេលគាត់ព្យាយាមថតយកទិដ្ឋភាពទាំងនោះ កម្មាភិបាលខ្មែរក្រហមដែលបានដើរតាមគាត់បានយកដៃបាំងកញ្ចក់ម៉ាស៊ីនថតរបស់គាត់ ។ ហូ មិនហ៊ានប្រឆាំងនឹងកម្មាភិបាលខ្មែរក្រហមឡើយ ។

បីឆ្នាំក្រោយមក ហូ បានត្រឡប់មកប្រទេសកម្ពុជាជាមួយកងទ័ពវៀតណាម នៅពេលដែលកងទ័ពវៀតណាមលុកលុយនិងដណ្ដើមកាន់កាប់ប្រទេសកម្ពុជាយ៉ាងឆាប់រហ័សនៅខែមករា ឆ្នាំ១៩៧៩ ។ ការរកឃើញមន្ទីរស-២១របស់ ហូ ហាក់ដូចជាមានភាពចៃដន្យបន្តិច ។ នៅពេលគាត់និងក្រុមថតភាពយន្តរបស់គាត់ដែលរួមមានជំនួយការម្នាក់និងអ្នកបើកបរម្នាក់បានបើករថយន្តក្បែរទីតាំងបរិវេណគុក ពួកគាត់បានធុំក្លិនស្អុយសាកសពដែលរលួយ ។ ដើម្បីស្វែងរកប្រភពនៃក្លិនឈ្ងួលខ្លាំងនេះ ពួកគាត់បានរកឃើញបរិវេណដែលបានបោះបង់ចោលហ៊ុមព័ទ្ធជុំវិញដោយខ្សែលួសបន្លា ។ ទីតាំងនោះគឺជាមន្ទីរសន្តិសុខស-២១ ដែលជាមជ្ឈមណ្ឌលសួរចម្លើយនិងធ្វើទារុណកម្មរបស់ខ្មែរក្រហម ។ បន្ទាប់ពីប្រាប់កងទ័ពវៀតណាមឲ្យដឹងអំពីការរកឃើញរបស់គាត់ ឃើញថា គាត់និងជំនួយការរបស់គាត់មិនមែននៅក្នុងមន្ទីរសន្តិសុខស-២១តែឯងនោះទេ ។ មានកុមារ៥នាក់ដែលស្ថិតនៅក្នុងអគារមួយក្នុងចំណោមអគារជាច្រើនដែលខ្លះកំពុងតែយំ ហើយខ្លះទៀតកំពុងតែដេកលក់ ។ កុមារទាំង៥នាក់នោះគឺជាកូនរបស់កម្មាភិបាលខ្មែរក្រហមដែល ប៉ុល ពត បានបញ្ជូនទៅកាន់មន្ទីរសន្តិសុខនោះ ។ ស្ថិតនៅពីមុខ ហូ និង កងទ័ពវៀតណាម កុមារទាំងនោះមានសភាពស្គមកំព្រឹងហើយជិតស្លាប់ ។ កងទ័ពកម្ពុជាផ្នែកនារីត្រូវបានហៅឲ្យមកថែទាំកុមារទាំងនោះ ។

ក្នុងអំឡុងស្នាក់នៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៩ របស់គាត់ ហូ បានប្រទះឃើញប្រជាជនកម្ពុជាដទៃទៀត ដែលក្រោយមកបានក្លាយជាសាច់រឿងនៅក្នុងខ្សែភាពយន្តរបស់គាត់ស្ដីពីប្រទេសកម្ពុជា ។ មានក្មេងប្រុសតូចម្នាក់ដែលពីដំបូង ហូ បានរកឃើញនៅខេត្តសៀមរាប ហើយក្រោយមកបានថតនៅក្នុងទីក្រុងភ្នំពេញ ។ នៅពេលដែល ហូ ជួបក្មេងនេះដំបូង ក្មេងនេះមានសភាពគ្រៀមស្វិត អន្ទះសា និងមានស្នាមពៀចនៅចំពីលើក្បាល ។ ក្មេងប្រុសតូចនេះបាននិយាយថា ខ្មែរក្រហមបានអា-កវាយចំក្បាល ហើយជះទឹកក្ដៅមកលើខ្លួន ។ ប្រហែល៥ឆ្នាំក្រោយមក នៅពេល ហូ ត្រឡប់មកប្រទេសកម្ពុជានៅឆ្នាំ១៩៨៤ គាត់បានជួបក្មេងនេះម្ដងទៀត ហើយបានថតយកស្ថានភាពថ្មីៗនិងប្រសើរជាងមុនរបស់ក្មេងប្រុសនេះ ។ ក្មេងប្រុសនេះបានធំធាត់ ហើយស្លៀកពាក់ឯកសណ្ឋានកូនសិស្ស ។ ហូ ថែមទាំងបានលើកឡើងថា ក្មេងប្រុសនេះធាត់ទៀតផង ។

ហូ បានថតខ្សែភាពយន្តផ្សេងទៀតមានចំណងជើងថា «ការរស់ឡើងវិញនូវទម្រង់សិល្បៈ» ។ នៅក្នុងខ្សែភាពយន្តរបស់គាត់ ស្ត្រីរស់រានមានជីវិតម្នាក់ដែលបានទៅសិក្សារបាំបុរាណនៅសហភាពសូវៀតមុនឆ្នាំ១៩៧៥ និយាយអំពីការលំបាក



ពីឆ្វេង: ឌិញ ហុង,

របស់គាត់នៅក្រោមរបបខ្មែរក្រហម ។ ហូ ក៏បានផលិតខ្សែភាពយន្តឯកសារស្តីពីស្ថានភាពទូទៅរបស់កុមារនៅប្រទេសកម្ពុជា ដោយផុសចេញពីទីតាំងដែលកុមារមានសភាពស្គមស្គាំងនិងស្លេកស្លាំងកំពុងអង្គុយម្នាក់ឯងនៅក្បែរកំពង់ផែទន្លេនៅអ្នកលឿងនៅឆ្នាំ១៩៧៩ ។ ខ្សែភាពយន្តនេះបានទទួលពានរង្វាន់ ។

ខ្សែភាពយន្តមួយផ្សេងទៀតផ្តោតជាពិសេសលើមនុស្សម្នាក់ដែលមិនមែនជាប្រជាជនកម្ពុជា ។ នៅឆ្នាំ១៩៧៩ ហូ បានរកឃើញស្ត្រីជនជាតិជប៉ុនម្នាក់កំពុងដើរតាមផ្លូវជាតិស្ថិតក្នុងសភាពវង្វេងវង្វាន់ ។ ស្ត្រីនោះគឺជាប្រពន្ធរបស់អតីតឯកអគ្គរាជទូតខ្មែរប្រចាំនៅប្រទេសជប៉ុន ។ បន្ទាប់ពីប្តីរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ គាត់ត្រូវបានចាប់ដាក់គុកនិងបង្ខំឲ្យថែរក្សាកុមារ ។ ហូ បានជួយស្ត្រីនោះ ដោយបានផ្តល់ដំណឹងដល់សារព័ត៌មានជប៉ុនអាសាហ៊ិ អំពីស្ត្រីនោះ នៅពេលដែល ហូ ត្រឡប់ទៅប្រទេសវៀតណាម ។ ប្រទេសជប៉ុនបានបញ្ជូនក្រុមគ្រួសាររបស់ស្ត្រីនោះនិងយន្តហោះមួយគ្រឿងឲ្យមកទទួលយកស្ត្រីនោះទៅកាន់ប្រទេសកំណើតវិញ ។ ហូ បានរំឭកថា នោះគឺជាការមកទទួលដ៏រំភើបនិងល្អិតល្អន់មួយ ។ កន្លះឆ្នាំក្រោយមក ហូ បានទទួលសំបុត្រមួយច្បាប់ពីស្ត្រីនោះ ដែលគាត់ទុកនៅក្បែររូបថតដែលគាត់បានថតជាមួយស្ត្រីនោះ ។


ង ដានី, ហូ វ៉ាន់ តាយ និង នង ចាន់ផល នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

ទោះបីយ៉ាងក៏ដោយ ខ្សែភាពយន្ត៣-៤រឿងរបស់ ហូ មិនមែនជាកម្មសិទ្ធិរបស់គាត់ទេ ខ្សែភាពយន្តនោះទុកនៅជាមួយទូរទស្សន៍ហូជីមិញ ។ រូបថតចំនួនជិត៧០សន្លឹកដែលបានថតនៅស-២១ ក្នុងឆ្នាំ១៩៧៩ ក៏ទូរទស្សន៍ហូជីមិញរក្សាទុកដែរ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញ ហូ មកទីក្រុងភ្នំពេញនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៩ ដើម្បីចូលរួមសវនាការ ឌុច ដែលជាមេដឹកនាំមន្ទីរស-២១ ។ ឌុច ដែលមានឈ្មោះពិត ថា កាំង ហ្គេកអ៊ាវ ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅខែកក្កដា ឆ្នាំ២០០៧ ហើយនឹងត្រូវជំនុំជម្រះទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដែលស្គាល់ជាទូទៅថាជាសាលាក្តីខ្មែរក្រហម ។ ឥឡូវនេះ បទពិសោធន៍ថតខ្សែភាពយន្តទៅលើរបបខ្មែរក្រហមរបស់ ហូ មានលក្ខណៈពេញលេញរាប់ចាប់តាំងពីដំណើរទស្សនកិច្ចក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦ ការរកឃើញមន្ទីរស-២១នៅឆ្នាំ១៩៧៩ ការតាមដានហេតុការណ៍ជាបន្តបន្ទាប់មកលើប្រទេសកម្ពុជានៅឆ្នាំ១៩៨៤ និងការមកមើលឃើញផ្ទាល់ភ្នែកទៅលើសវនាការរបស់មេដឹកនាំមន្ទីរស-២១នៅពេលខាងមុខ ។ ទោះបីចូលនិវត្តន៍ក៏ដោយ ក៏វាជាឱកាសល្អមួយដែល ហូ នៅតែមានបំណងប្រាថ្នាបន្តនិងបញ្ចប់ខ្សែភាពយន្តរបស់គាត់ស្តីពីប្រទេសកម្ពុជា ។ ការវិលត្រឡប់របស់គាត់មកប្រទេសកម្ពុជានៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៩ នេះនឹងកត់សម្គាល់ដំណើរទស្សនៈកិច្ចមួយទៀតមកកាន់ប្រទេសកម្ពុជាក្នុងអំឡុងឱកាសសំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។

◆ **កំណត់ចំណាំ** ៖ ហូ វ៉ាន់ តាយ នឹងជួបជាមួយ នង ចាន់ផល (កុមារដែលបានរស់រានជីវិតពីមន្ទីរស-២១ ។ គាត់ជាកុមារម្នាក់ក្នុងចំណោមកុមារ៥នាក់ដែលបានរកឃើញដោយ វ៉ាន់ តាយ នៅឆ្នាំ១៩៧៩) ជាលើកដំបូងក្នុងរយៈពេល៣០ឆ្នាំនៅថ្ងៃច័ន្ទ ទី១៦ ឆ្នាំ២០០៩ នៅក្លិបអ្នកកាសែតកម្ពុជា ។

**វ៉ែកខ ដាស៊ីល**



កងទ័ពវៀតណាមចូលមកសង្គ្រោះក្មេងកំព្រាដែលឪពុកម្តាយត្រូវបានសម្លាប់នៅគុកទួលស្លែងក្នុងឆ្នាំ១៩៧៩



# យ៉ែម យឹម អ្នកធ្វើខ្នោះសម័យខ្មែរក្រហម

បុរសម្នាក់ក្នុងចំណោមមនុស្សបួននាក់ដែលធ្លាប់បានធ្វើខ្នោះឈើសម្រាប់ដាក់អ្នកទោសនៅមន្ទីរសន្តិសុខ៩៩ ឬមន្ទីរ៩៩ ឈ្មោះ យ៉ែម យឹម អាយុ៧៣ឆ្នាំ បានរស់រានរហូតមកដល់បច្ចុប្បន្ន។ គាត់ជាអាចារ្យវត្តធម្មត្រៃយ៍ ភូមិរស្មីសាមគ្គី ឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។ ជីវិតប្រចាំថ្ងៃរបស់គាត់មិនសូវធូរធាប៉ុន្មានទេ ប៉ុន្តែគាត់សប្បាយនឹងរស់នៅក្នុងជីវភាពបែបនេះ ព្រោះពុំមាននរណាម្នាក់បង្ខំឲ្យគាត់ធ្វើការដូចក្នុងរបបខ្មែរក្រហមឡើយ ។ លោកតា យឹម ឧស្សាហ៍ធ្វើដំណើរទៅលេងផ្ទះកូនបង្កើតរបស់គាត់នៅឯភូមិរលាំងជ្រៃ ឃុំកាហែង ស្រុកសំរោងទង និងឆ្លៀតពេលទៅព្យាបាលជំងឺនៅទីរួមខេត្តកំពង់ស្ពឺទៀតផង ។ នៅក្នុងភូមិរស្មីសាមគ្គី ឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ឯណោះវិញ លោកតា យឹម តែងតែត្រូវបានអ្នកភូមិអញ្ជើញឲ្យធ្វើជាអាចារ្យក្នុងពិធីមង្គលការបុណ្យផ្សេងៗទៅតាមប្រពៃណីទំនៀមទម្លាប់របស់ខ្មែរ ។ នៅពេលទំនេរគាត់តែងធ្វើការងារនៅផ្ទះ ប៉ុន្តែគាត់មិនប្រកបអាជីពជាជាងឈើដូចកាលពីជំនាន់ខ្មែរក្រហមទៀតឡើយ ។

ផ្តើមចេញពីការជជែកលេងជាមួយគាត់ និងអ្នកភូមិពីរបីនាក់ទៀត លោកតា យឹម បានរៀបរាប់ពីជីវប្រវត្តិរបស់គាត់តាំងពីកុមារភាពរហូតដល់ពេលបច្ចុប្បន្នថា គាត់មានស្រុកកំណើតនៅឃុំដើងភ្នំ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ កាលពីកុមារភាព លោកតាធ្លាប់បានរៀននៅសាលាមួយក្នុងភូមិថមល្អ ហើយលោកតាបានឈប់រៀននៅថ្នាក់ទី៩ចាស់ ដោយសារជីវភាពក្រីក្រ និងចលាចលក្នុងសង្គម ។ នៅមុនពេលលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ គាត់បានផ្លាស់ប្តូរទីលំនៅទៅរស់នៅជាមួយបងប្រុសម្នាក់ឯភូមិរស្មីសាមគ្គី ឃុំរស្មីសាមគ្គី ពេលគាត់មានអាយុ២០ឆ្នាំ ។ នៅទីនោះគាត់ប្រកបការងារជាអ្នកធ្វើស្រែចម្ការ ដូចអ្នកភូមិដទៃទៀតដែរ ។


យ៉ែម យឹម

មិនយូរប៉ុន្មាន លោកតា យឹម បានរៀបការជាមួយនារីមូលដ្ឋានម្នាក់ ហើយបន្តការងារធ្វើស្រែចម្ការដដែលរហូតក្រុមខ្មែររំដោះចូលមកត្រួតត្រា ។ ក្នុងស្ថានភាពប្រែប្រួលប្រែប្រួលនេះ លោកតា យឹម មិនបានចូលរួមក្នុងចលានាខ្មែររំដោះដូចអ្នកភូមិឯទៀតឡើយ ហើយគាត់តែងតែកុហកថាមកលេងស្រុកកំណើតរបស់គាត់នៅពេលដែលមានការគៀងគរអ្នកស្រុកឲ្យរត់ចូលព្រៃធ្វើជាខ្មែររំដោះម្តងៗ ។ រហូតមកដល់ឆ្នាំ១៩៧២ យឹម មិនត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរដោយសេរីដូចសព្វដងទៀតទេ ព្រោះគាត់ត្រូវក្រុមខ្មែររំដោះចាត់តាំងឲ្យចូលធ្វើការងារនៅក្នុងកងសិប្បកម្មមួយក្នុងឃុំដែលមានសមាជិក៤០នាក់ដើម្បីផលិតឧបករណ៍ប្រើប្រាស់ផ្សេងៗប្រចាំភូមិនិងឃុំ ។ លោក តា យឹម ពុំមានជំនាញជាងឈើពីមុនមកទេ ប៉ុន្តែដោយសារគាត់ធ្លាប់រៀនចេះដឹងបន្តិចបន្តួចពីមុនមក ហើយអាចមានលទ្ធភាពយល់កិច្ចការបានល្អ ទើបគាត់ក្លាយជាសមាជិករបស់ក្រុមជាង ប្រចាំឃុំតាសាល ។ លោកតានិយាយដូច្នេះថា «*...គេចេះតែរើសឲ្យធ្វើ គេមើលទៅថាយើងអាចយល់និងធ្វើកិច្ចការនេះបាន*» ។ លោកតាបានធ្វើកិច្ចការជាមួយសមាជិកឯទៀតនៅក្នុងក្រុមពុំដែលមានជម្លោះឡើយ ហើយការងាររបស់ពួកគាត់គឺធ្វើរហាត់ទឹក ត្បាល់កិន ផ្ទះរបប (ផ្ទះបាយ) មណ្ឌលកុមារ គុ និងស្ពាន ។ លោកតាមិនមែនជាប្រធានក្រុមជាងទេ ប៉ុន្តែ

គាត់ជាអ្នកដែលបានធ្វើកិច្ចការច្រើនជាងគេនៅក្នុងក្រុម ។ ជួនកាលគាត់ទទួលបញ្ជាឲ្យទៅធ្វើស្ពាន ឬការងារសិប្បកម្មផ្សេងទៀតនៅទីកន្លែងឆ្ងាយៗពីភូមិ និងកម្របានដឹងពីស្ថានភាពនៅក្នុងភូមិថាតើមានរឿងអ្វីកើតឡើងណាស់ ។

នៅឆ្នាំ១៩៧៣ លោកតាបានទទួលបញ្ជាពី សមមិត្ត សន ជាប្រធានសហករណ៍រោងម៉ាស៊ីនឃុំតាសាលឲ្យចូលទៅមើលគំរូខ្នោះឈើដែលមានស្រាប់នៅក្នុងមន្ទីរសន្តិសុខ៩៩ ឬមន្ទីរ៩៩ ដើម្បីងាយស្រួលក្នុងការផលិតឲ្យដូចគ្នា បន្ទាប់ពីគាត់បានត្រឡប់មកពីធ្វើស្ពាននៅស្ទឹងថ្មកំបោរនិងស្ទឹងចារវិញនាពេលរសៀលថ្ងៃមួយ ។ កងឈ្លបដែលយាមខាងក្រោមន្ទីរពីរនាក់គឺ យ៉ាន់ និង ម៉ឺន ជាអ្នកជូនលោកតា ឃឹម ទៅកាន់មន្ទីរ ប៉ុន្តែកងឈ្លបទាំងពីរមិនត្រូវបានអនុញ្ញាតឲ្យចូលទៅខាងក្នុងមន្ទីរជាមួយគាត់ទេ ។ លោកតានិយាយយ៉ាងដូច្នេះថា *«កងឈ្លបដែលនាំខ្ញុំពីនេះទៅគឺមិនបានចូលទៅក្នុងមន្ទីរទេ គេឲ្យនៅចាំខាងក្រៅ ហើយមានកងឈ្លបសម្ងាត់ម្នាក់ទៀតមកនាំខ្ញុំចូលទៅមើលគំរូខ្នោះ»* ។ គាត់បានឃើញអ្នកទោសជាច្រើននាក់បានជាប់ឃុំឃាំង និងជាប់ខ្នោះឈើចំនួនពីរជួរ នៅក្នុងមន្ទីរឃុំឃាំងមួយខ្នងក្នុងចំណោមមន្ទីរឃុំឃាំងបី-បួនខ្នងផ្សេងទៀតនៃមន្ទីរសន្តិសុខ៩៩ ។ លោកតាបានប្រាប់ថាមានអ្នកទោសច្រើនប្រភេទជាប់ខាងក្នុង ប៉ុន្តែគាត់មិនស្គាល់នរណាម្នាក់ឡើយ ។ *«ខ្ញុំមិនដឹងសោះថាមានអ្នកទោសច្រើនជាប់នៅទីនោះទេ ហើយខ្ញុំមានការតក់ស្លុតខ្លាំង ពេលដែលឃើញអ្នកទោសកំពុងជាប់ខ្នោះទាំងនោះធ្វើការងារស្រាលដូចជាធ្វើអំបោស វៃក្រចកត្នោត វេញខ្សែគោ និង ធ្វើកន្ត្រក»* ។

បន្ទាប់ពីបានមើលគំរូខ្នោះឈើទាំងនោះហើយ លោកតានិងសមាជិកក្រុមជាងបីនាក់ផ្សេងទៀតបានចាប់ផ្តើមការងារធ្វើខ្នោះតាមគំរូដែលគាត់បានឃើញ ។ គាត់បានយកឈើដែលមានប្រវែងប្រហែលពី៥ ទៅ៧ម៉ែត្រ កម្រាស់៦សង់ទីម៉ែង គុណនឹង១២សង់ទីម៉ែត្រ មកចោះប្រហោងដែលល្មមសម្រាប់ដាក់កជើងអ្នកទោសបាន ហើយមានគម្លាតពីប្រហោងមួយទៅប្រហោងមួយទៀតប្រវែង៣០សង់ទីម៉ែត្រ ។ ក្នុងមួយថ្ងៃៗ សមាជិកក្រុមជាងទាំងបួននាក់អាចធ្វើខ្នោះឈើឲ្យបានពីបួនទៅប្រាំខ្នោះ ហើយកងឈ្លបប្រចាំមន្ទីរជាអ្នកមកប្រមូលយកខ្នោះឈើទាំងនោះទៅកាន់មន្ទីរ ។ លោកតាត្អូញត្អែរថា *«ខ្ញុំមិនចាំបានទេថាតើមានខ្នោះឈើប៉ុន្មានដែលខ្ញុំបានធ្វើទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា ខ្ញុំអាចធ្វើបានពីបួនទៅប្រាំខ្នោះក្នុងមួយថ្ងៃ ហើយខ្ញុំបានធ្វើខ្នោះនេះរយៈពេលជិតមួយសប្តាហ៍»* ។ បន្ទាប់ពីធ្វើខ្នោះរួចរាល់ លោកតា ឃឹម និងសមាជិកបីនាក់ទៀតបានត្រូវអង្គការផ្លាស់ប្តូរឲ្យទៅធ្វើនៅកន្លែងឆ្ងាយៗ ។ រហូតមកដល់ឆ្នាំ១៩៧៧ សមាជិកក្រុមបីនាក់ដែលធ្លាប់បានធ្វើខ្នោះជាមួយលោកតាស្រាប់តែត្រូវអង្គការចាប់ខ្លួន ហើយមិនដឹងជាស្លាប់ឬនៅរស់ទេនៅពេលបច្ចុប្បន្ននេះ ។ លោកតាបានប្រាប់ថា ក្នុងចំណោមអ្នកទាំងបីដែលត្រូវអង្គការចាប់ខ្លួននោះមានម្នាក់ដែលគាត់មិនចាំឈ្មោះត្រូវបានបញ្ជូនមកកាន់មន្ទីរស-២១ពីបទបានក្បត់នឹងអង្គការ ។ ចំណែក លោកតាវិញមិនត្រូវបានចាប់ខ្លួនដូចអ្នកទាំងបីទេ ប៉ុន្តែបងប្អូនរបស់គាត់ទាំងអស់ត្រូវបានសម្លាប់នៅឆ្នាំ១៩៧៦ ពីបទជាប់និន្នាការនយោបាយពីសង្គមមុន ។

ទោះបីជារយៈពេល៣០ឆ្នាំក្រោយការដួលរលំរបបខ្មែរក្រហម ឃឹម បានបំភ្លេចរឿងនេះអស់ទៅហើយ ប៉ុន្តែគាត់នៅចងចាំពីវិធីធ្វើខ្នោះឈើជូនអង្គការដដែល ។ លោកតាមិនដែលបានទៅមើលឬពិនិត្យមន្ទីរ៩៩ទៀតទេចាប់តាំងពីគាត់បានទៅមើលគំរូខ្នោះជាលើកដំបូងកាលពីឆ្នាំ១៩៧៣មក ហើយគាត់ក៏មិនបានដឹងដែរថា ខ្នោះឈើដែលគាត់ធ្វើនៅមានសេសសល់ឬបាត់អស់ដែររហូតបច្ចុប្បន្ននេះ ។ អ្វីដែលលោកតាចាប់អារម្មណ៍ជាងគេនៅពេលនេះនិងពេលអនាគត គឺការសន្សំសីលទាន និងធ្វើអំពើល្អ ។ សព្វថ្ងៃ លោកតាជាអាចារ្យដែលអ្នកភូមិគោរពស្រឡាញ់និងចាត់ទុកជាមនុស្សចាស់ទុំដែលមានការគោរពរាប់អានពីប្រជា-ជនក្នុងភូមិ ។ ទាក់ទិននឹងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហមដែលកំពុងដំណើរការ លោកតាមិនបានយកចិត្តទុកដាក់ឡើយ ហើយគាត់ក៏មិនដែលដឹងពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដែរ ។ *«ខ្ញុំមិនចាប់អារម្មណ៍ពីដំណើរការរបស់តុលាការទេ ទុកឲ្យគេជាអ្នកដោះស្រាយចុះ ។ ចំណែកខ្ញុំគិតតែពីកិច្ចការដែលខ្ញុំអាចធ្វើបាននាពេលនេះ និងទៅអនាគតប៉ុណ្ណោះ»* ។

**ផេង ពង្សរ៉ាស៊ី**

# ចំណាក់ចំណងភូមិភាគបូព៌ា
# វិទ្យុភ្នំពេញផ្សាយអំពីពិធីរំឮកខួបរដ្ឋប្រហារឆ្នាំ១៩៧០

*ភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧*

បទអត្ថាធិប្បាយ «រំឭកខួបរដ្ឋប្រហារលើកទី៧ ដែលចក្រពត្តិអាមេរិក និងបនក្បត់ លន់ នល់ បានដកយកឯករាជ្យ សន្តិភាពនិងអព្យាក្រឹត្យភាពរបស់ប្រទេសកម្ពុជានៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ កម្មករ កសិករ និង កងទ័ពបដិវត្តន៍យើង ប្តេជ្ញាចិត្តចងកំហឹងប្រឆាំងនឹងសត្រូវក្នុងជំហរស្នេហាជាតិដើម្បីបំពេញរាល់ភារកិច្ចក្នុងឆ្នាំ១៩៧៧ របស់បដិវត្តន៍មហាលោតផ្លោះ មហាអស្ចារ្យ» ។

បនក្បត់ លន់ នល់, សិរី មតៈ, ស៊ិន ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត សុសស្តែន ហ៊ែណាន់ដេ និងបរិវារចក្រពត្តិអាមេរិក ដែលបានជំពាក់បំណុលឈាមប្រជាជនយើង ។ នៅមុនពេលនិងក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពួកគេបានជិះជាន់ សង្កត់សង្កិន និងសម្លាប់រង្គាលប្រជាជនយើងយ៉ាងព្រៃផ្សៃ ។ នៅពេលដែលពួកចក្រពត្តិអាមេរិកប្រព្រឹត្តសកម្មភាពឈ្លានពានមកលើយើង ពួកគេគឺជាឆ្កែបម្រើចក្រពត្តិអាមេរិក ។ ជាមួយនឹងការញុះញង់របស់ពួកចក្រពត្តិអាមេរិកនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពួកគេបានធ្វើរដ្ឋប្រហារ ដោយដកយកឯករាជ្យភាព សន្តិភាព និងអព្យាក្រឹត្យភាពរបស់កម្ពុជា ។

រដ្ឋប្រហារបានធ្វើឲ្យប្រជាជនយើងមានកំហឹងយ៉ាងខ្លាំង និងជំរុញឲ្យប្រជាជនធ្វើសង្គ្រាម នយោបាយ និងសង្គ្រាមប្រដាប់អាវុធ ។ ប្រជាជនយើងបានរួបរួមគ្នាជាធ្លុងមួយ ដើម្បីធ្វើបាតុកម្ម និងកូតកម្ម ព្រមទាំងធ្វើការវាយប្រហារប្រឆាំងនឹងពួកចក្រពត្តិអាមេរិក និងក្រុមធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ។ នៅទូទាំងប្រទេស ប្រជាជនយើងរាប់សែននាក់បានចូលរួមធ្វើបាតុកម្ម ។ ការធ្វើបាតុកម្មនេះបានរីករាលដាល់ពីខេត្តមួយទៅខេត្តមួយ ។

ថ្វីបើបក្សពួកក្បត់ លន់ នល់ បានបញ្ជូនកងទ័ព កងរថក្រោះ និងកងកាំភ្លើងធំទៅវាយប្រហារប្រជាជនយើងយ៉ាងព្រៃផ្សៃ ប៉ុន្តែបាតុករយើងនៅតែតស៊ូទៅមុខទៀតក្នុងគោលបំណងកម្ទេចបណ្តាញបនក្បត់ប្រតិកិរិយា ។ នៅក្នុងទីរួមខេត្តនិងតំបន់ផ្សេងៗ ក្រុមបាតុករបានដុតសាលាខេត្ត តុលាការ សាលាស្រុក សាលាឃុំ ស្ថានីយប៉ូលីស និងមន្ទីរសន្តិសុខ ។ ជាងនេះទៅទៀត ដើម្បីតបតនឹងសត្រូវ ក្រុមបាតុករបានប្រើដៃទទេសម្លាប់បរិវារបក្សពួកក្បត់ទៀត ។

នៅពេលនោះ បាតុករបានបង្កើននិងពង្រីកកម្លាំងពីកន្លែងមួយទៅកន្លែងមួយ ពីច្រាំងខាងកើតនៃទន្លេមេគង្គទៅដល់ខេត្តកំពង់ចាម ពីកំពង់ចាមទៅជ្រោយចង្វារនិងភ្នំពេញ ពីស្វាយរៀង និង ព្រៃវែង ទៅអ្នកលឿង និងពីកំពត តាកែវ អង្គតាសោម និងកំពង់ស្ពឺ ទៅភ្នំពេញ ។ គោលបំណងរបស់បាតុករគឺដើម្បីវាយកម្ទេចបណ្តាញបក្សពួកក្បត់នៅភ្នំពេញ ។

នៅក្រោមការដឹកនាំដ៏ត្រឹមត្រូវច្បាស់លាស់របស់អង្គការបដិវត្តន៍ ប្រជាជន និងកងទ័ពបដិវត្តន៍យើងដែលប្រកាន់ខ្ជាប់នូវជំហរតស៊ូខ្លាំងក្លា ការពលីដ៏ថ្លៃថ្នូរ និងតស៊ូជម្នះនូវរាល់កិច្ចការលំបាក និងទុក្ខវេទនាដោយស្របទៅតាមមាគ៌ាឯករាជ្យនិងការ



***យោធាខ្មែរក្រហមអបអរសាទរគណៈប្រតិភូ***

ពឹងផ្អែកលើខ្លួនឯង បានបន្តធ្វើការតស៊ូកម្ទេចរាល់ផែនការឈ្លានពានរបស់ពួកចក្រពត្តិអាមេរិក និងបរិវាររបស់ពួកគេគឺបក្សពួកក្បត់លន់ នល់ ។ សង្គ្រាមអាមេរិកភាវូបនីយកម្មនៅកម្ពុជា សង្គ្រាមកម្ពុជាភាវូបនីយកម្ម និងសង្គ្រាមអាកាសដ៏ព្រៃផ្សៃរបស់ពួកចក្រពត្តិអាមេរិកធ្វើឲ្យប្រជាជនវាយប្រហារយ៉ាងខ្លាំង និងជាបន្តបន្ទាប់ទៅលើពួកគេ ហើយរំដោះបានភ្នំពេញ និងប្រទេសទាំងមូលនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាថ្ងៃជ័យជម្នះប្រវត្តិសាស្ត្រ ។

ចាប់តាំងពីថ្ងៃជ័យជម្នះ១៧មេសា ក្រោមការគាំទ្របដិវត្តន៍មហាអស្ចារ្យ ប្រជាជនយើងដូចជាកម្មករ និងកសិករព្រមទាំងកងទ័ពបដិវត្តន៍បានរួមដៃគ្នាតស៊ូដើម្បីការពារនិងកសាងប្រទេស ។ កម្មករ កសិករ និង កងទ័ពបដិវត្តន៍យើងបានតស៊ូដើម្បីជួយស្រោចស្រង់សេដ្ឋកិច្ចជាតិដែលត្រូវបានបំផ្លេចបំផ្លាញដោយសង្គ្រាមរបស់ពួកចក្រពត្តិអាមេរិក និងបរិវាររបស់ពួកគេ ។

តាមរយៈការតស៊ូដ៏តានតឹងនិងខ្លាំងក្លាដើម្បីជម្នះរាល់ឧបសគ្គ កិច្ចការលំបាក និងការខ្វះខាតទូទៅ ប្រជាជននិងកងទ័ពបដិវត្តន៍យើងបានជួយស្រោចស្រង់សេដ្ឋកិច្ចជាតិ ដោយធ្វើឲ្យបានរីកចម្រើនគ្រប់ផ្នែក ។ បច្ចុប្បន្ន យើងអាចធ្វើឲ្យស្ថានភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើង និងបន្តការពារ និងកសាងប្រទេស ។ គោលជំហរតស៊ូដ៏អង់អាច និងការពលី គោលជំហរសមូហភាពនិងស្មារតីស្នេហាជាតិរបស់ប្រជាជនយើងតែងតែរឹងមាំនិងខ្លាំងក្លា ទោះបីជានៅក្នុងកាលៈទេសៈតស៊ូបដិវត្តន៍ប្រឆាំងនឹងការវាយប្រហារឈ្លានពានរបស់ពួកចក្រពត្តិអាមេរិក និងបរិវាររបស់ពួកគេ ឬនៅពេលបច្ចុប្បន្ន ដែលយើងកំពុងប្រឹងប្រែងការពារនិងកសាងកម្ពុជាប្រជាធិបតេយ្យដើម្បីធ្វើឲ្យរីកចម្រើនដូចកម្ពុជាមហាលោតផ្លោះ ។ បងប្អូនកម្មករ កសិករក្រីក្រ និងថ្នាក់កណ្តាល ជាមូលដ្ឋានសំខាន់ និងជាកម្លាំងមជ្ឈិមរបស់ចលនាបដិវត្តន៍នៅគ្រប់សម័យកាលបានការយល់ដឹងពីបច្ចេកទេស មនោគមន៍វិជ្ជានយោបាយ និងសមូហភាព ។ អ្នកទាំងនោះប្រកាន់ខ្ជាប់យ៉ាងខ្លាំងជាមួយនឹងស្មារតីច្នៃប្រឌិត ។



នៅក្រោមការដឹកនាំរបស់អង្គការបដិវត្តន៍ដ៏វៃឆ្លាត ជាពិសេសតាំងពីខែមីនា ឆ្នាំ១៩៧៣ នៅពេលដែលមានការសម្រេចចិត្តថា ការបង្កបង្កើតជាសហករណ៍ត្រូវធ្វើឡើងនៅតាមតំបន់រំដោះ កម្លាំងពលកម្មរបស់កសិករ និងកម្មករក្រីក្រ និងថ្នាក់កណ្តាលដើរតួនាទីនៅកណ្តាលនិងសំខាន់បំផុត ។ នៅឆ្នាំ១៩៧៦ ប្រជាជនយើងដែលជាកម្មករ កសិករ អ្នកតស៊ូប្រុសស្រី និងកម្មាភិបាលបដិវត្តន៍នៅសហគមន៍កម្មករ សហករណ៍ កងបដិវត្តន៍ផ្សេងៗ មន្ទីរនិងក្រសួងរដ្ឋាភិបាលផ្សេងៗបានរួមដៃគ្នាធ្វើការតស៊ូដើម្បីដោះស្រាយបញ្ហាការផ្គត់ផ្គង់ទឹក ដើម្បីធានាឲ្យមានទឹកគ្រប់គ្រាន់សម្រាប់ធ្វើស្រែនៅរដូវភ្លៀងនិងរដូវវស្សា ។ កិច្ចខំប្រឹងប្រែងនេះធ្វើឲ្យដំណាំស្រូវល្អ ។

លទ្ធផលនៃកិច្ចខំប្រឹងប្រែងរបស់ប្រជាជនយើងនៅឆ្នាំចាស់គឺស្ថិតនៅក្នុងដៃរបស់ពួកគេ ។ បច្ចុប្បន្ននេះមិនមានវណ្ណៈជិះជាន់ឬបក្សពួកក្បត់របស់អ្នកកេងប្រវ័ញ្ច លួច ឬឆក់ប្លន់ប្រជាជនយើងទេ ។ ទិន្នផលស្រូវឆ្នាំនេះមានប្រសិទ្ធភាពអាចបំពេញតម្រូវការរបស់ប្រជាជនយើង បង្កើនជីវភាពរស់នៅ និងជួយដល់ការកសាងជាតិ ។

បងប្អូនប្រជាជនមានភាពសប្បាយរីករាយ ពេញចិត្ត មានមោទនភាព និងជឿជាក់ទៅលើការដឹកនាំដ៏ត្រឹមត្រូវ ច្បាស់លាស់ និងអស្ចារ្យរបស់អង្គការបដិវត្តន៍យើង ។ ផ្អែកទៅលើថ្ងៃជ័យជម្នះដ៏អស្ចារ្យឆ្នាំ១៩៧៦ បងប្អូនប្រជាជនយើងមានបទពិសោធន៍ថ្មីមួយចំនួនខាងវិស័យកសិកម្ម ដោយរួមបញ្ចូលទាំងការរក្សាទឹកទុក

ប្រព័ន្ធធារាសាស្ត្រ ផលិតកម្ម និងការប្រើប្រាស់ដី ការជ្រើសរើសពូជស្រូវ ការគ្រប់គ្រងកម្លាំងពលកម្ម និងផ្នែកផ្សេងៗទៀត ។ តាមការពិត កត្តាដំបូងដែលបណ្តាលឲ្យមានជ័យជម្នះឆ្នាំ១៩៧៦ គឺមកពីប្រជាជនយើងបានយល់យ៉ាងច្បាស់និងប្រតិបត្តិយ៉ាងត្រឹមត្រូវតាមមាគ៌ានយោបាយរបស់អង្គការបដិវត្តន៍យើង ជាពិសេសគោលនយោបាយកសិកម្ម ដោយភ្ជាប់ភាពចាំបាច់ទៅនឹងបញ្ហាផលិតផលស្រូវដ៏មានសារសំខាន់ គឺការផ្គត់ផ្គង់ទឹក ការដាក់ជី និងការជ្រើសរើសគ្រាប់ពូជ ។

នៅក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងច្បាស់លាស់របស់អង្គការបដិវត្តន៍យើងដែលប្រកាន់ខ្ជាប់នឹងជំហរឯករាជ្យ និងការជឿជាក់លើខ្លួនឯង ហើយយោងទៅតាមមូលហេតុដែលបានអះអាងខាងលើ ប្រជាជនយើងដែលជាកម្មករ កសិករ និងកងទ័ពបដិវត្តន៍យើងបានសម្រេចចូលរួមចលនាប្រជាជន គឺការវាយលុកដ៏ខ្លាំងក្លានិងមុតមាំ មហាលោតផ្លោះដើម្បីការពារនិងកសាងប្រទេសយើងឲ្យទៅជាប្រទេសដែលមានភាពរីកចម្រើនគ្រប់វិស័យ ជាពិសេសគឺវិស័យកសិកម្មដែលមានសារសំខាន់បំផុត ។ បងប្អូនកសិករនៅសហករណ៍ យុទ្ធមិត្ត និងកម្មាភិបាលប្រុសស្រីត្រូវបានកំណត់ឲ្យបង្កើនផលិតផលស្រូវឲ្យច្រើនជាងនៅឆ្នាំ១៩៧៦ ។ តាមការពិត បងប្អូនប្រជាជនយើងសុទ្ធតែដឹងថា ការផ្គត់ផ្គង់ទឹកគឺជាបញ្ហាសំខាន់ ហើយដើម្បីបង្កើនការគ្រប់គ្រងទៅលើប្រព័ន្ធធារាសាស្ត្រ បងប្អូនប្រជាជនយើងរួមកម្លាំងគ្នាជីកប្រឡាយ អាងស្តុកទឹកនៅក្នុងរដូវក្តៅនេះដោយក្តីសោមនស្សរីករាយ ដោយប្រែក្លាយតំបន់ជនបទយើងនៅគ្រប់ទីកន្លែងទៅជាកន្លែងធ្វើការ ដែលពោរពេញទៅដោយបរិយាកាសអធឹកអធម ។ នៅពេលជាមួយគ្នានេះដែរ ប្រជាជនយើងក៏បានភ្ជាប់សារសំខាន់នៃការជ្រើសរើសគ្រាប់ពូជសម្រាប់ដំណាំដែលប្រើរយៈពេលមធ្យមនិងវែង ការដាក់ជី ការបាញ់ថ្នាំ ទៅនឹងការសាងសង់ និងការផលិតម៉ាស៊ីន និងឧបករណ៍កសិកម្មផ្សេងៗ និងចងក្រងបទពិសោធន៍ការធ្វើកសិកម្មដើម្បីអភិវឌ្ឍនិងបង្កើតបច្ចេកទេសធ្វើកសិកម្ម ។

បន្ថែមទៅលើស្រូវ បងប្អូនប្រជាជនយើងក៏បានដំណាំស្រូវ និងដំណាំសំខាន់ៗផ្សេងៗជាច្រើន ដូចជា ពោត សណ្តែកខៀវ សណ្តែកដី សណ្តែកសៀង បន្លែផ្សេងៗទៀត និងដំណាំឧស្សាហកម្មផ្សេងៗរួមមាន កប្បាស ក្រចៅ សាវម៉ៅ ល្ហុងអំពៅ ថ្នាំជក់ សំឡីគរ ដូង ឫស្សី ដំឡូងឈើ ដើមអាកាស្យា និងដំណាំផ្សេងៗទៀត ។ នៅពេលជាមួយគ្នានេះដែរ បងប្អូនប្រជាជនយើងបានផ្សារភ្ជាប់ភាពចាំបាច់នៃការចិញ្ចឹមសត្វឲ្យកាន់តែច្រើន ដើម្បីបំពេញតម្រូវការគេ និងជួយការពារនិងកសាងប្រទេស ។

នៅក្នុងវិស័យឧស្សាហកម្មបងប្អូនកម្មករយើងនៅក្នុងរោងចក្រដែលផលិតឧបករណ៍កសិកម្ម និងផលិតផលប្រើប្រាស់របស់ប្រជាជន បានខិតខំប្រឹងប្រែងបង្កើនផលិតកម្ម ។ រោងចក្រចាស់ៗកាលពីមុនថ្ងៃរំដោះបានប្រើប្រាស់វត្ថុធាតុដើមពីបរទេស បច្ចុប្បន្នប្រជាជនយើងបានកែប្រែរោងចក្រទាំងនោះទៅជារោងចក្រឯករាជ្យ ដែលអាចផលិតឧបករណ៍កសិកម្ម និងផលិតផលប្រើប្រាស់សម្រាប់ប្រជាជនយើងដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុកដែលអាចប្រើប្រាស់បានជាពិសេស ។ បងប្អូនប្រុសស្រីយើងចាប់អារម្មណ៍ជាពិសេសទៅលើការបង្កើតនិងពង្រីករោងជាងធំៗនិងកន្លែងឧស្សាហកម្មនៅគ្រប់ទីកន្លែងនិងប្រែក្លាយកន្លែងទាំងនេះទៅជារោងចក្រនៅថ្ងៃអនាគតឲ្យដូចទៅនឹងកាលដែលកងបដិវត្តន៍យើងត្រូវបានបង្កើតឡើង ។ កងទ័ពបដិវត្តន៍យើងត្រូវបានពង្រឹង ពង្រីក និងកែប្រែពីកងការពារសម្ងាត់ទៅជាកងទ័ពព្រៃកងទ័ពតំបន់ហើយបន្ទាប់មកទៅជាកងទ័ពពិតប្រាកដ ។

អ្នកប្រយុទ្ធរបស់កងទ័ពបដិវត្តន៍យើង ដៃម្ខាងកាន់កាំភ្លើងដើម្បីការពារប្រទេស ដៃម្ខាងទៀតកាន់ចបនិងបង្គីជីកប្រឡាយ និងសងអាងស្តុកទឹកដើម្បីផលិតស្រូវ ដើម្បីបំពេញតម្រូវការរបស់ពួកគេ តម្រូវការរបស់ប្រជាជននិងដើម្បីការពារប្រទេស ។

ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងភ្លឺស្វាងរបស់អង្គការបដិវត្តន៍យើង កម្ពុជាប្រជាធិបតេយ្យយើងកំពុងឆ្ពោះទៅមុខដោយមហាលោតផ្លោះស្របទៅតាមគោលការណ៍ឯករាជ្យ ការពឹងផ្អែកលើខ្លួនឯង និងការសម្រេចចិត្តដោយខ្លួនឯង ។ កម្មករ កសិករ និងយុទ្ធមិត្តបដិវត្តន៍យើងបានតាំងចិត្តប្រកៀកស្មាគ្នាបំពេញគ្រប់កិច្ចការនៅឆ្នាំ១៩៧៧ និងប្រឹងប្រែងការពារនិងកសាងកម្ពុជាថ្មីក្នុងស្មារតីស្នេហាជាតិ ដោយធ្វើការវាយប្រហារដ៏ខ្លាំងក្លានិងមុតមាំនៅក្នុងចលនាប្រជាជនដោយមហាលោតផ្លោះ ។

**ឯកសារD២៨៩៩៦**

# សវនាការរួមនិងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

មានការរំពឹងគិតទុកថា ប្រសិនបើ អៀង សារី, នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អ្នកទាំងនេះនឹងទទួលបានការជំនុំជម្រះទោសរួមគ្នា ។ នៅក្នុងដំណើរការរួម ជនត្រូវចោទច្រើននាក់នឹងត្រូវបានជំនុំជម្រះក្លាមៗសម្រាប់ឧក្រិដ្ឋកម្មដូចគ្នាឬឧក្រិដ្ឋកម្មដែលពាក់ព័ន្ធគ្នា ។ យន្តកម្មនីតិវិធីនេះត្រូវបានហៅថា «សវនាការរួម» ហើយតាមទ្រឹស្តីយន្តការនេះជំរុញឲ្យមានសវនាការដ៏មានប្រសិទ្ធភាព ។ «ការបំបែកសំណុំរឿង» ដែលជាការបំបែកការជំនុំជម្រះរួមគ្នាគឺជាយន្តការដើម្បីបំបែករឿងក្តីដែលត្រូវបានចោទប្រកាន់រួមគ្នាហើយធ្វើការជំនុំជម្រះរឿងក្តីដាច់ពីគ្នា ។

ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងវិធានផ្ទៃក្នុងមិនបានចែងពីបញ្ញត្តិច្បាស់លាស់ដើម្បីដោះស្រាយថាតើតុលាការគួរតែដោះស្រាយនូវសំណួរអំពីសវនាការរួមគ្នាឬដាច់ពីគ្នាយ៉ាងណានោះទេ ។ ទោះបីជាយ៉ាងណា ឯកសារទាំងនេះចែងពីបញ្ញត្តិទូទៅដូចទៅនឹងឯកសារសំខាន់ៗរបស់តុលាការនិងសាលាក្តីអន្តរជាតិដោយសង្កត់ធ្ងន់ទៅលើ ១) សារសំខាន់នៃប្រសិទ្ធភាពតុលាការ ២) សិទ្ធិរបស់ជនត្រូវចោទដើម្បីទទួលបានការកាត់សេចក្តីត្រឹមត្រូវដែលមិនទទួលនូវការលម្អៀងមិនសមហេតុផល ឬការពន្យារពេលមិនសមស្រប និង ៣) សិទ្ធិរបស់ជនរងគ្រោះនិងសាក្សី ។ ឧទាហរណ៍ មាត្រា២២របស់ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា «ធានាថាសវនាការមានភាពយុត្តិធម៌ត្រឹមត្រូវនិងមានប្រសិទ្ធភាព... ដោយមានការគោរពសិទ្ធិរបស់ជនត្រូវចោទនិងដើម្បីការពារជនរងគ្រោះនិងសាក្សី» ។ មាត្រា៣៣ចែងថា អង្គជំនុំជម្រះវិសាមញ្ញត្រូវតែ «អនុវត្តន៍យុត្តិសាស្ត្ររបស់ខ្លួនឲ្យស្របតាមស្តង់ដារអន្តរជាតិចំពោះភាពត្រឹមត្រូវ យុត្តិធម៌និងប្រព្រឹត្តទៅតាមដំណើរការសមស្របតាមច្បាប់» ។ បន្ថែមលើសពីនេះទៅទៀត មាត្រា៣៨នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តល់ឲ្យជនត្រូវចោទ «នូវសិទ្ធិទទួលបានការជំនុំជម្រះទោស ដោយគ្មានការពន្យារពេលមិនសមស្រប» ។ ដូចនៅឯតុលាការនិងសាលាក្តីអន្តរជាតិជាច្រើន ការធានានេះនឹងឆ្ពោះទៅរកវិធីសាស្ត្រសវនាការរួមនិងសវនាការដាច់ដោយឡែករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**ច្បាប់ស្តីពីសវនាការរួមនិងសវនាការដាច់ឡែកនៅតុលាការអន្តរជាតិ**

យោងតាមមាត្រា៣៣នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា «ប្រសិនបើនីតិវិធីមានស្រាប់មិនដោះស្រាយរឿងជាក់លាក់មួយ... ការណែនាំអាចស្វែងរកតាមវិធាននីតិវិធីដែលបង្កើតនៅក្នុងកម្រិតអន្តរជាតិ» ។ សម្រាប់ហេតុផលនេះ វាសមស្របក្នុងការមើលទៅលើថាតើតុលាការអន្តរជាតិដោះស្រាយសំណួរនេះដោយរបៀបណា ។ ក្រៅពីបទបញ្ញត្តិជាទូទៅទាក់ទិននឹងភាពត្រឹមត្រូវ យុត្តិធម៌និងមានប្រសិទ្ធភាព ឧបករណ៍សំខាន់ៗរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងតុលាការពិសេសសម្រាប់អតីតប្រទេសសេរ៉ាឡេអូនចែងពីច្បាប់ក្នុងការដោះស្រាយសវនាការរួមនិងសវនាការដាច់ដោយឡែក ។ ឧទាហរណ៍ វិធាន ៤៨ ដែលស្របទៅនឹងវិធាននីតិវិធីនិងភ័ស្តុតាងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនចែងថា «បុគ្គលទាំងឡាយដែលត្រូវបានចោទប្រកាន់ដោយបទឧក្រិដ្ឋដូចគ្នាឬផ្សេងគ្នា ប្រព្រឹត្តឡើងនៅក្នុងដំណាក់កាលប្រតិបត្តិការដូចគ្នា អាចត្រូវបានចោទនិងជំនុំជម្រះទោសរួមគ្នា» ។ តុលាការនេះអាចស្នើឲ្យមានសវនាការរួមឬសវនាការដាច់ដោយឡែកនៅពេលដែលជនត្រូវចោទចាត់ទុកថាសមស្រប ដែលជារឿយៗនៅពេលមានសំណើពីព្រះរាជអាជ្ញាឬជនត្រូវចោទ ។

**ការសាកល្បង «ទៅលើប្រតិបត្តិការដូចគ្នា»**

ប្រសិនបើធ្វើតាមវិធីសាស្ត្រដែលទទួលបានការអនុញ្ញាតពីតុលាការអន្តរជាតិ នៅពេលពិចារណាទៅលើបញ្ញត្តិឲ្យមានសវនាការរួមឬសវនាការដាច់ដោយឡែក សំណួរទីមួយដែលអង្គជំនុំជម្រះវិសាមញ្ញនឹងចោទសួរគឺថាតើជនដែលត្រូវចោទបានប្រព្រឹត្តបទឧក្រិដ្ឋដូចគ្នាឬស្រដៀងគ្នា ប្រព្រឹត្តឡើងនៅក្នុងដំណាក់កាល «ប្រតិបត្តិការដូចគ្នា» ឬទេ? ច្បាប់នីតិវិធីរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនឲ្យនិយមន័យ «ប្រតិបត្តិការ» ថាជា «អំពើឬការខកខានមួយចំនួន» ថាតើកើតឡើងនៅក្នុងហេតុការណ៍តែមួយឬហេតុការណ៍មួយចំនួននៅត្រង់ទីតាំងដូចគ្នា ឬផ្សេងគ្នា ហើយជាផ្នែកមួយរបស់គម្រោងរួម វិធីសាស្ត្ររួម ឬផែនការរួមឬអត់» ។ តុលាការទាំងនោះបង្កើតឡើងនូវលក្ខណៈវិនិច្ឆ័យលម្អិតដើម្បីកំណត់នៅពេលណាដែលអំពើទាំងឡាយបង្កើតបានជាគម្រោងរួម វិធីសាស្ត្ររួម ឬផែនការរួម ។

អំពើទាំងឡាយជាផ្នែករបស់ប្រតិបត្តិការដូចគ្នានៅពេលដែល ១) ទាក់ទងនឹងធាតុផ្សំផ្នែកសម្ភារៈនៃបទឧក្រិដ្ឋ ២) អាចកំណត់បាននូវភាពជាក់លាក់អំពីពេលវេលានិងទំហំ និង៣) បកស្រាយគម្រោងរួម វិធីសាស្ត្ររួម ឬផែនការរួមដែលមានស្រាប់ ។ ធាតុផ្សំពីរដំបូងនៃការវិភាគនេះងាយស្រួលបំពេញ ប៉ុន្តែធាតុផ្សំទីបីត្រូវការសេចក្តីអះអាងបន្ថែមទៀត ។ ដូច្នេះការវិភាគរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទំនងជាផ្តោតខ្លាំងទៅលើថាតើគម្រោងរួម វិធីសាស្ត្ររួម និងផែនការរួមកើតមានរវាងជនត្រូវចោទឬអត់ ។ នៅពេលវាយតម្លៃលើសវនាការរួម ជាទូទៅតុលាការអន្តរជាតិផ្តល់សេរីភាពទូលំទូលាយដល់ការចោទប្រកាន់របស់ព្រះរាជអាជ្ញាចំពោះផែនការរួម ។ ជាលទ្ធផល តុលាការអន្តរជាតិផ្តល់ឲ្យនូវសវនាការរួមនៅពេលដែលជនត្រូវចោទត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទឧក្រិដ្ឋនៅទីតាំងភូមិសាស្ត្រដាច់ពីគ្នានិងពេលវេលាផ្សេងគ្នា ឬជាសមាជិករបស់អង្គការនយោបាយឬអង្គការយោធាផ្សេងគ្នា ។

ឧទាហរណ៍ នៅក្នុងរឿងក្តី បារ៉ាយ៉ាវីហ្សានិងគូរកនរបស់គាត់ *(Barayagwiza, et al.)* តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានអនុញ្ញាតឲ្យបញ្ញតិរបស់ព្រះរាជអាជ្ញា ដើម្បីបញ្ចូលជនត្រូវចោទឲ្យនៅមួយក្រុមរួមគ្នាដែលបានត្រួតត្រាលើសារព័ត៌មាន ដោយបានផ្សព្វផ្សាយមនោគមន៍វិជ្ជាជ្រុលនិយម ហើយក្រុមមួយទៀតត្រូវបានចោទប្រកាន់ថាបានបង្កើតស្ថានីយវិទ្យុសម្រាប់គោលបំណងដូចគ្នា ។ នៅក្នុងរឿងក្តីរបស់ ប្រាដានិន និងគូរកនរបស់គាត់ *(Brdanin, et al.)* តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីជំនុំជម្រះទោសជនត្រូវចោទម្នាក់ដែលជាសមាជិករបស់អង្គការចាត់តាំងនយោបាយ និងជនត្រូវចោទម្នាក់ទៀតដែលជាសមាជិកអង្គការចាត់តាំងយោធារួមគ្នា ។ នៅក្នុងរឿងក្តីនោះ តុលាការបានឲ្យហេតុផលថា ទោះបីជាអង្គហេតុដែលបានចោទប្រកាន់មិនដូចគ្នា ជនត្រូវចោទទាំងពីររូបនេះអាចត្រូវបានជំនុំជម្រះទោសរួមគ្នា ពីព្រោះជនត្រូវ


សវនាការជំនុំជម្រះក្តី កាំង ហ្គេចអ៊ាវ (ឌុច) អតីតប្រធានមន្ទីរស-២១

ចោទទាំងនេះត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងអំឡុងពេលនិងតំបន់ដូចគ្នានៅក្នុងអតីតប្រទេសយូហ្គោស្លាវី ។

នៅពេលតុលាការទាំងនេះត្រូវបានស្នើសុំឲ្យមានការកាត់ទោសរួមគ្នានូវជនជាប់ចោទដែលបានប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងតំបន់និងទីតាំងផ្សេងគ្នា តុលាការទាំងនេះសួរថាតើមានការពាក់ព័ន្ធគ្រប់គ្រាន់រវាងអំពើដែលបានចោទប្រកាន់ឬទេ? វាចាំបាច់ថាតើគម្រោងឬផែនការរួមចងភ្ជាប់សហជនត្រូវចោទបានឬទេ? នៅក្នុងរឿងក្តីរបស់ ណាតាគីរូទីម៉ាណា និងគូរកនរបស់គាត់ *(Ntakirutimana, et al.)* ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាយល់ព្រមឲ្យមានសវនាការរួមនៅពេលដែលជនត្រូវចោទពីរក្រុមត្រូវបានជំនុំជម្រះទោសនិងចោទប្រកាន់លើអំពើដែលកើតឡើងក្នុងទីតាំងពីរផ្សេងគ្នា ។ ជនត្រូវចោទមួយក្រុមត្រូវបានចោទប្រកាន់ថាបានចូលរួមក្នុងការសម្លាប់រង្គាលនៅទីតាំងទីមួយ ហើយបន្ទាប់មកទៀតថាបានតាមរកអ្នករស់រានមានជីវិតនៅពេលដែលពួកគេជម្លៀសខ្លួនទៅទីតាំងទីពីរ ។ ជនត្រូវចោទក្នុងក្រុមទីពីរត្រូវបានចោទប្រកាន់ថាបានសម្លាប់អ្នកដែលរស់រានមានជីវិតនៅទីតាំងទីពីរ ។ នៅក្នុងការផ្តល់ឲ្យនូវសវនាការរួម តុលាការសម្គាល់ឃើញថា អំពើរបស់ជនត្រូវចោទទាំងពីរក្រុមអាចបង្កើតបានជាផ្នែកប្រតិបត្តិការដូចគ្នា ពីព្រោះមានការពាក់ព័ន្ធគ្នាគ្រប់គ្រាន់រវាងអំពើដែលបានប្រព្រឹត្តនៅក្នុងតំបន់ពីរ ។ នៅក្នុងការឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីការពារក្តីដែលថា ការសម្លាប់រង្គាលខុសគ្នាទៅនឹងអត្តសញ្ញាណជនរងគ្រោះនិងកម្រិតដែលជនត្រូវចោទនីមួយៗបានចូលរួមតុលាការសម្គាល់ឃើញថា គម្រោងវិធីសាស្ត្រឬផែនការនៅរាល់ទីតាំងនីមួយៗ



*មិនចាំបាច់ដូចគ្នាបេះបិទឡើយ ។ បន្ថែមលើសពីនេះទៀត គម្រោងនោះអាចផ្លាស់ប្តូរតាមពេលវេលា បើទោះជាគម្រោងនោះនៅតែមានលក្ខណៈ «រួម» ខាងសារជាតិនិងគោលបំណង ។*

*ភាសាដែលតុលាការទាំងនេះប្រើប្រាស់គឺ «គម្រោងរួម វិធីសាស្ត្ររួម ឬផែនការរួម» ដើម្បីវាយតម្លៃថាតើបទឧក្រិដ្ឋជាផ្នែករបស់ប្រតិបត្តិការដូចគ្នា បំផុសភាសាផ្សំគំនិត ឬការទទួលខុសត្រូវតាមផ្លូវច្បាប់ទៅលើ «សហកម្មឧក្រិដ្ឋកម្មរួម» ឬទេ? សម្រាប់ហេតុផលនេះ នៅក្នុងការវាយតម្លៃថាតើសវនាការរួមសមស្រប ឬទេ? តុលាការមួយចំនួនសួរថាតើប្រសិនបើអាចបញ្ជាក់ថាពិតការចោទប្រកាន់របស់ព្រះរាជអាជ្ញាបង្កើតបានការផ្សំគំនិតឬទេ? ប្រសិនបើអាចបង្កើតបាននូវការផ្សំគំនិតនោះ នឹងមានមូលដ្ឋានសម្រាប់ការរួមបញ្ចូលគ្នាដែរ ។ សម្រាប់ហេតុផលនេះ តុលាការមួយចំនួនបង្កើតឲ្យមានការសន្មតទុកជាមុននូវការផ្សំគំនិតរបស់ជនត្រូវចោទជាបុគ្គលដែលបានប្រព្រឹត្តបទឧក្រិដ្ឋដូចគ្នាត្រូវទទួលបានការកាត់ទោសរួមគ្នា ។ ទោះបីយ៉ាងណាក៏ដោយ សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាដែលមិនចោទប្រកាន់ការផ្សំគំនិតរវាងជនត្រូវចោទមិនបង្កើតបានការសន្មតទុកជាមុនប្រឆាំងនឹងសវនាការរួមឡើយ ។*

## កត្តាសម្រេចចិត្ត

*ច្បាប់នីតិវិធីនិងភ័ស្តុតាងរបស់សាលាក្តីអន្តរជាតិទាំងអស់ចង្អុលបង្ហាញថា នៅពេលដែលតុលាការរកឃើញថា ការតម្រូវទុកជាមុនទៅលើប្រតិបត្តិការដូចគ្នារបស់សវនាការរួមត្រូវបានបំពេញ តុលាការនៅតែត្រូវពិចារណាថាតើសវនាការដាច់ដោយឡែកសមស្របដើម្បីគេចផុតពីទំនាស់ផលប្រយោជន៍ដែលអាចបណ្តាលឲ្យមាន «ការលម្អៀងធ្ងន់ធ្ងរ» ដល់ជនត្រូវចោទ ឬដើម្បីការពារ «ផលប្រយោជន៍យុត្តិធម៌» ឬទេ? ជាទូទៅ តុលាការពិចារណាចំណុចដូចខាងក្រោមដើម្បីវាយតម្លៃថាតើការលម្អៀងធ្ងន់ធ្ងរដល់ជនត្រូវចោទនឹងធ្វើឲ្យមានភាពសមហេតុផលដល់សវនាការដាច់ដោយឡែកឬអត់ ដែលរួមមានសក្តានុពលសម្រាប់ ១) ការពន្យារពេលមិនសមស្របនៅក្នុងដំណើរការ ២) ភ័ស្តុតាងដែលបង្ហាញឡើងប្រឆាំងនឹងជនត្រូវចោទម្នាក់អាចនាំឲ្យមានភាពលម្អៀងដល់ជនត្រូវចោទផ្សេងទៀតនៅក្នុងសវនាការរួម និង ៣) សក្ខីភាពសាក្សីជំទាស់និងការមិនយល់ស្របទៅលើយុត្តិសាស្ត្រការពារក្តី ។*

*នៅក្នុងការវាយតម្លៃសក្តានុពលសម្រាប់ការពន្យារពេលមិនសមស្រប តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ពិចារណាហេតុការណ៍ទាំងស្រុងនិងថ្លឹងថ្លែងផលប្រយោជន៍នៃសវនាការរួមប្រឆាំងនឹងលទ្ធភាព ព្រមទាំងកម្រិតនៃការពន្យារពេល ។ សាលក្រមលើរឿងក្តីរបស់ បាហ្គោសូរ៉ា និងគូរកនរបស់គាត់* (**Bagosora, et al.**) *តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាសម្គាល់ឃើញកត្តាបួនយ៉ាងដើម្បីពិចារណាក្នុងការវាយតម្លៃការអូសបន្លាយការពន្យារពេលដូចជា រយៈពេលនៃការពន្យារពេល ហេតុផលចំពោះការពន្យារពេល ថាតើជនដែលត្រូវចោទបង្ហាញសិទ្ធិរបស់ខ្លួនឲ្យមានសវនាការឆាប់ឬទេ ហើយការពន្យារពេលលើភាពលម្អៀងអាចកើតឡើងចំពោះជនត្រូវចោទ ។ ឧទាហរណ៍ នៅក្នុងរឿងក្តីមួយរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការឲ្យហេតុផលថា ដោយសារជនត្រូវចោទមួយចំនួនត្រូវបានស្ថិតក្នុងការឃុំឃាំងអស់រយៈពេល៣ឆ្នាំរួចមកហើយ ការចោទប្រកាន់រួមលើជនត្រូវចោទបន្ថែមទៀតនឹងប៉ះពាល់ដល់រយៈពេលនៃសវនាការរបស់ជនត្រូវចោទ ។ យោងតាមតុលាការ ចំណុចនេះគឺស្ថិតក្នុងការពន្យារពេលមិនសមស្របដែលច្បាប់ស៊ុះស៊ែងរកការការពារជនត្រូវចោទ ។*

*នៅពេលព្រះរាជអាជ្ញាស្នើសុំឲ្យមានសវនាការរួមជារឿយៗជនត្រូវចោទជំទាស់ថា ខ្លួននឹងទទួលរងនូវភាពលម្អៀងដោយសារភ័ស្តុតាងជាច្រើននិងភាពច្របូកច្របល់នៃភ័ស្តុតាងដែលនឹងបង្ហាញនៅក្នុងដំណើរការ ។ ទី១) ភ័ស្តុតាងស្មុចស្មើងអាចធ្វើឲ្យសវនាការលំបាកនិងច្របូកច្របល់ ។ ទី២) ភ័ស្តុតាងឬសក្ខីភាពទាក់ទងនឹងសហជនត្រូវចោទប្រហែលធ្វើឲ្យមានភាពលម្អៀងដល់សហជនត្រូវចោទដទៃទៀតដែលភ័ស្តុតាងមិនទាក់ទងគ្នាដែលហៅថា ទស្សីករណ៍ «បំពុល» ។ ជាទូទៅតុលាការទាត់ចោលការជំទាស់ទាំងពីរនេះដោយហេតុផលថា មិនដូចសវនាការនៅចំពោះមុខគណៈវិនិច្ឆ័យដែលលទ្ធភាពនៃភ័ស្តុតាងលម្អៀងមាន*

យ៉ាងច្រើន ចៅក្រមអាចកាត់បន្ថយភាពលម្អៀងបែបនោះតាមរយៈការបណ្តុះបណ្តាលផ្នែកអាជីពរបស់ខ្លួន ។

ជាធម្មតា ជនត្រូវចោទជំទាស់ថា នៅក្នុងដំណើរការសវនាការរួម ខ្លួនអាចត្រូវបានបង្ខំឲ្យផ្តល់ចម្លើយកសិណតទល់គ្នាទៅវិញទៅមក ឬថាមេធាវីការពារក្តីរបស់ខ្លួននឹងទទួលយកវិធីសាស្ត្រការពារក្តីប្រឆាំងគ្នាទៅវិញទៅមក ។ តុលាការអន្តរជាតិកម្រទាត់ចោលសំណើឲ្យមានសវនាការរួមនៅលើមូលដ្ឋានបែបនេះណាស់ ប៉ុន្តែតុលាការអន្តរជាតិផ្តល់ឲ្យនូវការណែនាំអំពីកាលៈទេសៈដែលតុលាការអាចផ្តល់ឲ្យបាន ។ ឧទាហរណ៍ តុលាការអន្តរជាតិឲ្យយោបល់ថា ប្រសិនបើសហជនត្រូវចោទមិនផ្តល់កសិណសាក្សីនៅក្នុងដំណើរការសវនាការរួមដោយសារភ័យខ្លាចថាជាការចោទប្រកាន់ខ្លួនឯង តុលាការគួរតែសួរថាតើសវនាការដាច់ដោយឡែកនឹងជំរុញឲ្យជនត្រូវចោទផ្តល់ចម្លើយកសិណឬទេ ។ តុលាការអន្តរជាតិក៏បានឲ្យយោបល់ផងដែរថា ខ្លួននឹងបង្គាប់ឲ្យមានសវនាការដាច់ដោយឡែកនៅពេលដែលជនត្រូវចោទម្នាក់ក្នុងចំណោមសហជនត្រូវចោទអាចផ្តល់សក្ខីភាពដែលនាំឲ្យមានភាពលម្អៀងដល់ជនត្រូវចោទផ្សេងទៀត ប្រសិនបើកាលៈទេសៈ «មិនធម្មតា» ទោះបីជាតុលាការមិនពិនិត្យពិច័យទៅលើលក្ខខណ្ឌដែលអាចធ្វើឲ្យសវនាការដាច់ដោយឡែកមានគុណភាពក៏ដោយ ។

## ផលប្រយោជន៍យុត្តិធម៌និងប្រសិទ្ធភាព

ដូចដែលបានពិភាក្សាខាងលើ តុលាការអន្តរជាតិក៏បដិសេធមិនយល់ស្របឲ្យមានសវនាការរួមនៅពេលដែលមានការចាំបាច់ការពារផលប្រយោជន៍យុត្តិធម៌ ។ នៅក្នុងសេចក្តីសម្រេចចិត្តថាតើត្រូវផ្តល់ឲ្យមានឬបដិសេធមិនឲ្យមានសវនាការរួម តុលាការអន្តរជាតិថ្លឹងថ្លែងផលប្រយោជន៍យុត្តិធម៌ជារួមប្រឆាំងនឹងសិទ្ធិរបស់ជនត្រូវចោទជាបុគ្គល ។ ដើម្បីធ្វើបែបនេះ តុលាការពិចារណាកត្តាមួយចំនួនដូចខាងក្រោម ៖ ១) សេដ្ឋកិច្ចផ្លូវច្បាប់ ហៅម្យ៉ាងទៀតថាការសន្សំពេលវេលានិងការចំណាយ) ២) ការការពារសាក្សី ៣) ភាពស្របគ្នារបស់សាលក្រម និង៤) ការបង្ហាញភ័ស្តុតាងស្របគ្នា ។

បញ្ហាពេលវេលានិងចំណាយទាក់ទិនទៅនឹងចំនួនសាក្សីនិងទំហំភ័ស្តុតាងដែលនឹងត្រូវបង្ហាញនៅចំពោះមុខតុលាការ នៅក្នុងដំណើរការសវនាការរួម ។ សំណួរសំខាន់បំផុតគឺថា សាក្សីនិងភ័ស្តុតាងកម្រិតណាដែលស័ក្តិសមសម្រាប់សហជនត្រូវចោទ ។ ប្រសិនបើសាក្សីនិងភ័ស្តុតាងសមស្របចំពោះសហជនត្រូវចោទស្ទើរទាំងអស់ ឆន្ទានុសិទ្ធិរបស់តុលាការជាទូទៅនឹងសម្រេចយកសវនាការរួម ។ ឧទាហរណ៍ នៅក្នុងរឿងក្តី ប៉ូប៉ូវិកនិងគូរកនរបស់គាត់ (Popovic, et al.) តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីយល់ព្រមឲ្យមានសវនាការរួមនៅពេលដែលព្រះរាជអាជ្ញាជំទាស់ថា ការជំនុំជម្រះជនត្រូវចោទដែលធ្វើដាច់ពីគ្នានឹងនាំឲ្យមានការបង្ហាញភ័ស្តុតាងលើសលប់ដែលមិនចាំបាច់ ហើយនឹងបង្កើនពេលវេលាដែលបានប៉ាន់ស្មានទុកសម្រាប់សវនាការពី១-២ឆ្នាំដល់៧-៨ឆ្នាំ ។ ក្នុងករណីខ្លះទៀត តុលាការបដិសេធសវនាការរួម ទោះបីអង្គហេតុដែលបង្ហាញពីអំពើរបស់សហជនត្រូវចោទជាផ្នែកនៃប្រតិបត្តិការដូចគ្នា នៅពេលដែលភាគីតែមួយរបស់សាក្សីសមស្របចំពោះសហជនត្រូវចោទ ។ ទិដ្ឋភាពមួយទៀតនៃការបារម្ភនេះគឺសេចក្តីត្រូវការក្នុងការការពារសាក្សី ។ ឧទាហរណ៍ សាលក្រមរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានពិចារណាអំពីចំនួនសាក្សីដែលសមស្របចំពោះសហជនត្រូវចោទទាំងអស់រួមជាមួយនឹងការព្រួយបារម្ភជាក់លាក់អំពីការកាត់បន្ថយតម្រូវការសាក្សីដែលធ្វើដំណើរមកចូលរួមដំណើរការច្រើនដងឬផ្តល់នូវសក្ខីភាពឈឺចាប់ដដែលៗ ។

ទោះបីយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្ត វាមិនទាន់ច្បាស់ថាតើសវនាការរួមពិតជាធ្វើឲ្យរយៈពេលដំណើរការសវនាការខ្លីនៅក្នុងសាលាក្តីអន្តរជាតិជាច្រើនឬអត់ ។ ឧទាហរណ៍ នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា សវនាការទៅលើបុគ្គលចំណាយពេលរវាង៣០ទៅ៤០ថ្ងៃដើម្បីបញ្ចប់ ។ នៅក្នុងករណីដែលក្រុមជនត្រូវចោទទទួលបានការជំនុំជម្រះទោសរួមគ្នា សវនាការចំណាយពេលពី១ឆ្នាំទៅ២ឆ្នាំកន្លះ ។ នៅក្នុងរឿងក្តី ញីរ៉ាម៉ាសាហ៊ុកូ និងគូរកនរបស់គាត់ (Nyiramasahuko, et al.) ដែលពាក់ព័ន្ធនឹងជនត្រូវចោទ៦នាក់ត្រូវបានជំនុំជម្រះទោសរួមគ្នា ដែលចំណាយពេលលើសពីនេះតិចតួចប៉ុណ្ណោះគឺ៧០០ថ្ងៃ ។ ជាមធ្យម សវនាការចំណាយពេល១០០ថ្ងៃដើម្បីជំនុំជម្រះទោស

បុគ្គលម្នាក់ៗជារយៈពេលនៃពេលវេលាដែលវែងជាងសវនាការជាច្រើននៅតុលាការខុក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ។ ស្រដៀងគ្នាដែរ ដំណើរការរួមនៅតុលាការខុក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីហាក់ដូចជាមិនកាត់បន្ថយពេលវេលាសវនាការប្រឆាំងដំណើរការបុគ្គលម្នាក់ៗឡើយ ។ ទោះបីជាការខកខានមិនបានសមស្របតាមស្តង់ដារបែបនេះក៏ដោយ ជនត្រូវចោទកម្រចង្អុលបង្ហាញភាពមិនស្របគ្នានេះថាជាការជំទាស់ប្រឆាំងនឹងសវនាការរួមដែរ ។

## *សវនាការរួមនិងជនត្រូវចោទនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

មកដល់ពេលនេះ មានតែជនត្រូវចោទ (កាំង ហ្គេកអ៊ាវ «ឌុច») ប៉ុណ្ណោះត្រូវបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ឌុច ត្រូវបានចោទប្រកាន់ពីតួនាទីរបស់គាត់ជាប្រធាននិងលេខាមជ្ឈមណ្ឌលធ្វើទារុណកម្មស-២១នៅក្នុងទីក្រុងភ្នំពេញ ។ ទោះបីជា ឌុច បានទាក់ទងជាមួយជនត្រូវចោទមួយចំនួនទៀត ជាប្រក្រតីសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានញែករឿងក្តីរបស់គាត់ដាច់ដោយឡែកពីជនត្រូវចោទ៤រូបផ្សេងទៀត ។ ឌុច ត្រូវបានចាប់ខ្លួនដោយរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៩ និងត្រូវបានផ្ទេរឲ្យស្ថិតនៅក្រោមការត្រួតត្រារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅខែកក្កដា ឆ្នាំ២០០៧នេះតែប៉ុណ្ណោះ ។ គាត់បានជាប់ពន្ធនាគារអស់រយៈពេលជាង៩ឆ្នាំមកហើយ ។ បំណងប្រាថ្នារបស់សាធារណជនកម្ពុជាចង់ឃើញសវនាការចាប់ផ្តើមឡើងឆាប់ៗ រួមជាមួយនឹងសិទ្ធិរបស់ ឌុច ទទួលបានសវនាការដោយគ្មានការពន្យារពេលមិនសមស្របដោយថ្លឹងថ្លែងមើលពីលទ្ធភាពដែលថាការិយាល័យព្រះរាជអាជ្ញានឹងស្នើសុំដើម្បីបញ្ចូលការចោទប្រកាន់របស់ ឌុច ទៅនឹងអ្នកដទៃទៀតនៅក្នុងដំណាក់កាលនេះ ។

ជនត្រូវចោទដែលនៅសល់មិនទាន់ត្រូវបានចោទប្រកាន់ ។ ហេតុដូច្នេះ វាមានការលំបាកក្នុងការស្វែងរកឲ្យឃើញពីភាពប្រាកដប្រជាចំពោះអំពើទាំងឡាយណាដែលត្រូវជំនុំជម្រះនិងថាតើសវនាការរួមនឹងសមស្របឬទេ? នៅក្នុងសេចក្តីបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាំង នួន ជា និង អៀង សារី ត្រូវបានចោទប្រកាន់ថាជាសមាជិករបស់គណៈកម្មាធិការមជ្ឈិមនិងអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលជាអង្គភាពធំជាងគេបង្អស់របស់របបខ្មែរក្រហម ។ អ្នកទាំងពីរត្រូវបានជឿថាមានអំណាចខ្លាំងក្នុងការគាក់តែងនិងអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ អ្នកទាំងពីរអាចត្រូវបានជំនុំជម្រះទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាម ។ ខៀវ សំផន មិនត្រូវបានចោទប្រកាន់ថាជាផ្នែកមួយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាទេ ប៉ុន្តែអ្នកស្រាវជ្រាវជាន់ខ្ពស់មួយចំនួនបាននិយាយថា គាត់បានជំរុញគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានិងបានត្រួតពិនិត្យការអនុវត្តគោលនយោបាយនោះ ។ អាចទៅរួចដែលថាជនដែលត្រូវបានចោទប្រកាន់ទាំងបីនាក់អាចទទួលបានការចោទប្រកាន់រួម ។

ជនត្រូវបានចោទប្រកាន់ទី៤គឺ អៀង ធីរិទ្ធ ដែលជារដ្ឋមន្ត្រីសង្គមកិច្ចក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាតំណែងតូចជាងជនត្រូវបានចោទប្រកាន់ផ្សេងទៀត ។ ទោះបីយ៉ាងណាក៏ដោយ អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ពីបទផ្តល់ការគាំទ្រនិងជំរុញគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ដូច្នេះហើយ នៅតែឃើញថា អៀង ធីរិទ្ធ នឹងត្រូវបានចោទប្រកាន់ដាច់ដោយឡែក មិនត្រឹមតែដោយសារគាត់មានតំណែងទាបនៅក្នុងក្បាលម៉ាស៊ីនរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ថែមទាំងដើម្បីចៀសវាងសវនាការរួមជាមួយស្វាមីរបស់គាត់ អៀង សារី ដែលរំពឹងថាអាចនឹងនាំឲ្យមានទំនាស់ផលប្រយោជន៍ ។

នៅក្នុងដំណាក់កាលនេះ មានការលំបាកដើម្បីវាយតម្លៃថាតើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងសម្រេចជំនុំជម្រះទោសបុគ្គលដែលត្រូវចោទប្រកាន់រួមគ្នាឬដាច់គ្នា ។ ដូចសវនាការដទៃទៀតដែរ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចង់វិនិច្ឆ័យទោសរឿងក្តីទាំងអស់ឲ្យបានឆាប់រហ័សនិងមានប្រសិទ្ធភាព ហើយការណ៍នេះអាចឆកទៅរកដំណើរការរួមយ៉ាងហោចណាស់សម្រាប់បុគ្គលដែលត្រូវបានចោទប្រកាន់មួយចំនួន ។

**ម៉ារ៉ាន់ សេរ៉េល**

# សវនាការជំនុំជម្រះសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាលើកទីមួយ នៅលើឧក្រិដ្ឋកម្មនៃ របបខ្មែរក្រហមក្នុងទសវត្សរ៍ ១៩៧0 បើកជាផ្លូវការ

*នៅថៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ផ្តើមសវនាការជំនុំជម្រះលើសំណុំរឿងទាក់ទងទៅនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខ ។*

*នៅភ្នំពេញអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាមួយកិច្ចខិតខំប្រឹងប្រែងក្នុងការនាំយកយុត្តិធម៌និងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងក្នុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ បានឈានមួយជំហានទៅមុខជាមួយនឹងការចាប់ផ្តើមសវនាការបឋមលើសំណុំរឿងទី១របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

*នៅថ្ងៃនេះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាតុលាការកូនកាត់ឯករាជ្យ គាំទ្រដោយអង្គការសហប្រជាជាតិ បានចាប់ផ្តើមដំណើរការសវនាការទៅលើជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ កាំង ហ្គេកអ៊ាវ ត្រូវប្រឈមមុខនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសន្ធិសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ រួមទាំងបទឧក្រិដ្ឋដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ដែលរួមមានអំពើមនុស្សឃាតដោយចេតនា និងការធ្វើទារុណកម្ម ។*

*បន្ទាប់ពីស៊ើបអង្កេតតាមរយៈតុលាការរួចមក នៅថ្ងៃទី៨ ខែសីហា កាលពីឆ្នាំមុន ការិយាល័យសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្តីចោទប្រកាន់ប្រឆាំងនឹងបទឧក្រិដ្ឋទាំងឡាយប្រព្រឹត្តិឡើងនៅមន្ទីរស-២១ដែលគេស្គាល់ថាគុកទួលស្លែងនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ បន្ទាប់ពីដំណោះស្រាយទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចោទប្រកាន់ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះនាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ។*

*នៅថ្ងៃសវនាការនេះ តុលាការបានសម្រេចពិចារណាទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនិងវិធានការការពារមួយចំនួនដែលទាមទារដោយបណ្តាភាគីទាំងនេះក៏ដូចជាបញ្ហាផ្លូវច្បាប់ជាបឋម និងនីតិវិធីមួយចំនួនដែលមានឥទ្ធិពលទៅដល់ការប្រព្រឹត្តទៅនៃសវការជំនុំជម្រះទៅលើអង្គសេចក្តីនៃការចោទប្រកាន់ ។*

*ក្នុងសវនាការនោះផងដែរ តុលាការនឹងបញ្ចប់នូវការកំណត់កាលវិភាគសម្រាប់សាក្សីនិងអ្នកជំនាញក្នុងការមកឆ្លើយបំភ្លឺក្នុងពេលសវនាការ ។ ជនជាប់ចោទ សាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណីមិននិយាយពាក់ព័ន្ធលើបញ្ហាក្នុងអង្គសេចក្តីក្នុងពេលសវនាការបឋម ប្រធានអង្គជំនុំជម្រះសាលាដំបូងដោយមានការពិគ្រោះយោបល់ជាមួយនឹងសមាជិកដ៏ទៃទៀតនឹងកំណត់នូវកាលបរិច្ឆេទនៃការចាប់ផ្តើមសវនាការលើអង្គសេចក្តីក្នុងពេលដ៏ខ្លីខាងមុខនេះ ។*

*សវនាការលើលើអង្គសេចក្តីនឹងពិចារណាទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ។ ជនជាប់ចោទ សាក្សី អ្នកជំនាញនិងដើមបណ្តឹងរដ្ឋប្បវេណី អាចឆ្លើយបំភ្លឺ ឬក៏ធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ក្នុងផ្នែកណាមួយនៃសវនាការលើអង្គសេចក្តីនេះ ។*

*ក្រោមកិច្ចព្រមព្រៀងឆ្នាំ២០០៣ រវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងអង្គការសហប្រជាជាតិ អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងជាតុលាការឯករាជ្យមួយ ។ តុលាការនេះមានបុគ្គលិកជាតិនិងអន្តរជាតិ ហើយមានយុត្តាធិការកាត់ទោសតែទៅលើមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិនិងអន្តរជាតិដែលបានប្រព្រឹត្តឡើងក្នុងពេលខ្មែរក្រហមកាន់កាប់អំណាចពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។*

00278451

C26/5/13

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៥)**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម នៃយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ៦ កុម្ភៈ ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / FEB / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. [illegible]

---

សាធារណៈ:

**សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើ មូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងដីកាកំណត់កាលបរិច្ឆេទសវនាការ**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Vincent de WILDE d'ESTMAEL

**ជនត្រូវចោទ**

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
ទី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR

**សហមេធាវីការពារក្តី**

ស សូវាន
Jacques VERGÉS

00278452

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៥)

C26/5/13

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") កត់សម្គាល់ឃើញមាន "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ **ខៀវ សំផន** ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន" ("ចម្លើយតប")។ ចម្លើយតបនេះ បានដាក់នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ ដែលនៅក្នុងនោះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គបុរេជំនុំជម្រះ សម្រេចលើបណ្ដឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ("សំណើ")។

២. នៅក្នុងសំណើរបស់ខ្លួន, សហព្រះរាជអាជ្ញាសន្និដ្ឋានថា "ទោះបីសហព្រះរាជអាជ្ញាគាំទ្រសវនាការផ្ទាល់មាត់សម្រាប់បណ្ដឹងឧទ្ធរណ៍ក៏ដោយ ក៏ប៉ុន្តែបណ្ដឹងឧទ្ធរណ៍មួយនេះទាក់ទងតែទៅនឹងការបន្តចិរវេលានៃការឃុំខ្លួន ហើយបណ្ដឹងឧទ្ធរណ៍នេះ ពុំបានលើកអំណះអំណាងអង្គហេតុ ឬ អង្គច្បាប់ថ្មីៗដែលចាំបាច់សម្រាប់សវនាការផ្ទាល់មាត់ទេ។"[១]

៣. នៅក្នុងសេចក្ដីបង្គាប់ចេញថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩, អង្គបុរេជំនុំជម្រះបានអញ្ជើញឱ្យភាគីនានា ដែលពាក់ព័ន្ធនៅក្នុងរឿងក្ដីនេះ ដាក់សេចក្ដីសន្និដ្ឋានតប ត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩។

៤. នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩, សហមេធាវីការពារក្ដីបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា។ នៅក្នុងសេចក្ដីសន្និដ្ឋានតបនោះ សហមេធាវីការពារក្ដីស្នើសុំឱ្យអង្គបុរេជំនុំជម្រះបើកសវនាការជាសាធារណៈលើបណ្ដឹងឧទ្ធរណ៍នេះ ដោយសារបណ្ដឹងឧទ្ធរណ៍នេះលើកឡើងបញ្ហាគតិយុត្តថ្មី ហើយពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទក្នុងការទទួលបាននូវសេរីភាព។[២] សហមេធាវីការពារក្ដីស្នើសុំបន្ថែមទៀតថា "សារណាបណ្ដឹងឧទ្ធរណ៍របស់ខ្លួនចំពោះដីកាបដិសេធការដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨" ដែលបានដាក់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ គួរយកមកជំនុំជម្រះនៅក្នុងពេលសវនាការជាមួយគ្នាតែម្ដង ដោយសារបណ្ដឹងឧទ្ធរណ៍ទាំងពីរនេះពាក់ព័ន្ធនឹងអធិឡាធិក្កុលភាពនៃការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន។ ដូច្នេះ បណ្ដឹងឧទ្ធរណ៍ទាំងពីរនេះ មានការពាក់ព័ន្ធគ្នា។

---

[១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ **ខៀវ សំផន** ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី[illegible] ខែវិច្ឆិកា ឆ្នាំ២០០៨, ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ C26/5/10 វាក្យខណ្ឌទី ៥។

[២] ចម្លើយតបរបស់ក្រុមការពារក្ដីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យសម្រេចលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ C26/5/12 វាក្យខណ្ឌទី ២។

សេចក្ដីសម្រេចបើកសវនាការជាសាធារណៈ

00278453

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៥)
C26/5/13

៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាក៏បានស្នើសុំឱ្យសម្រេចបណ្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធការដោះលែងឱ្យមានសេរីភាព ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះដែរ។[៣]

៦. វិធាន ៧៧ នៃវិធានផ្ទៃក្នុង (វិ.២) ចែងនៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធថា:

> "៣. (ខ) បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។"

៧. ដោយទទួលស្គាល់អំពីសារៈសំខាន់នៃបណ្តឹងឧទ្ធរណ៍ទាំងពីរ ដែលពាក់ព័ន្ធនឹងសេរីភាពរបស់ជនត្រូវចោទ និងដោយពិចារណាថា ក្រុមមេធាវីការពារក្តី បានស្នើសុំឱ្យមានសវនាការដេញដោល, អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមស្របក្នុងការរៀបចំសវនាការនេះឡើង មុនពេលសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងនេះ។

៨. ដោយពិចារណាឃើញថា បណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធការដោះលែងឱ្យមានសេរីភាព នឹងរៀបចំរួចរាល់សម្រាប់ការជំនុំជម្រះក្នុងពេលឆាប់ៗនេះ ហើយបណ្តឹងឧទ្ធរណ៍នេះ បានលើកឡើងបញ្ហានានា ដែលជាប់ទាក់ទងជិតស្និទទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, អង្គបុរេជំនុំជម្រះនឹងបើកសវនាការលើបណ្តឹងឧទ្ធរណ៍ទាំងពីរនេះ រួមគ្នាតែម្តង។

៩. សវនាការលើរឿងក្តីទាំងនេះ ត្រូវធ្វើឡើងជាសាធារណៈ។

---

[៣] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤), ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធការដោះលែងឱ្យមានសេរីភាពនៃថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ C40/5/2 វាក្យខណ្ឌ [illegible]

សេចក្តីសម្រេចបើកសវនាការជាសាធារណៈ

00278454

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៥)

C26/5/13

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះ៖**

(១) **បដិសេធចោល**សំណើសុំឱ្យធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរណ៍តែប៉ុណ្ណោះ នៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤) និង ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៥)។

(២) **កំណត់**បើកសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធការដោះលែងឱ្យមានសេរីភាព **នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ៩:០០ ព្រឹក**។ និង

(៣) **អញ្ជើញ**គ្រប់ភាគីដែលពាក់ព័ន្ធនឹងរឿងក្តីនេះ ចូលរួមនៅក្នុងសវនាការតាមកាលបរិច្ឆេទកំណត់។ ✓

ភ្នំពេញ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៩

**ប្រធានអង្គបុរេជំនុំជម្រះ**

ប្រាក់ គីមសាន



# យុត្តិធម៌ដែលត្រូវបានរំខាន ភាពប្រថុយប្រថានរបស់តុលាការកាត់ទោសខ្មែរក្រហមកម្ពុជាបានក្លាយជាការបោកបញ្ឆោត

គ្មានតុលាការណាមួយដែលយើងអាចចាត់ទុកថាបានប្រព្រឹត្តទៅតាមលក្ខណៈច្បាប់ទាំងអស់ឡើយ ប្រសិនបើចៅក្រមនិងព្រះរាជអាជ្ញាស្ថិតនៅក្រោមសម្ពាធផ្នែកនយោបាយ ។ ជាការមួយគួរឲ្យព្រួយបារម្ភដែលតុលាការគាំទ្រដោយអង្គការសហប្រជាជាតិនៅក្នុងទីក្រុងភ្នំពេញធ្វើការស៊ើបអង្កេតនិងកាត់ទោសអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជាមានភាពប្រថុយប្រថានក្នុងការធ្វើកិច្ចការនេះ ។

តុលាការដែលមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអះអាងថា មានមនុស្សតែ៥នាក់ប៉ុណ្ណោះបានសម្លាប់ប្រជាជនជិត២លាននាក់នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ កាលពីសប្តាហ៍មុន សហព្រះរាជអាជ្ញាអន្តរជាតិរបស់តុលាការនេះឈ្មោះ រ៉ូប៊ែ ពើទីត Robert Petit បានស្នើឲ្យមានការស៊ើបអង្កេតជាផ្លូវការលើជនសង្ស័យមួយចំនួនតូចបន្ថែមទៀត ។ ដោយយោងទៅតាមព័ត៌មានចុះថ្ងៃទី៨ ខែធ្នូ ចេញផ្សាយពីការិយាល័យរបស់លោក ពើទីត ហើយដៃគូនៅក្នុងតំបន់របស់គាត់គឺសហព្រះរាជអាជ្ញាអ្នកស្រី ជា លាង បានជំទាស់ទៅនឹងដំណើរការនេះ ពីព្រោះវិធីសម្រាប់ដោះស្រាយការជំទាស់រវាងព្រះរាជអាជ្ញាត្រូវរក្សាជាការសម្ងាត់ ហេតុផលរបស់អ្នកស្រី ជា លាង សម្រាប់ជំទាស់ទៅនឹងការស៊ើបអង្កេតបន្ថែមគឺគ្មាននរណាដឹងទេ ។

លោក ពើទីត បានធ្វើសេចក្តីថ្លែងការណ៍ស្តីពីការមិនយល់ព្រមជាផ្លូវការមួយដែលរៀបរាប់ពីការប្តេជ្ញារបស់គាត់ដើម្បីដាក់បន្ទុកបន្ថែមទៀត ។ នៅក្រោមរចនាសម្ព័ន្ធដ៏ស្មុគស្មាញរបស់តុលាការ គាត់អាចធ្វើដូច្នេះបាន ប្រសិនបើសិទ្ធិត្រូវបានផ្តល់ឲ្យដោយអង្គបុរេជំនុំជម្រះវិសាមញ្ញគឺជាផ្នែកមួយរបស់តុលាការដែលទទួលខុសត្រូវលើការត្រួតពិនិត្យមើលដំណើរការកាត់ក្តីជាសំខាន់ដើម្បីកាត់ទោសនិងដោះស្រាយលើការជំទាស់រវាងសហព្រះរាជអាជ្ញានិងសហចៅក្រម ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីពេលមុនបានផ្តល់យោបល់ថា ការសាកល្បងកាត់ទោស



អ្នកទោសនៅមន្ទីរស-២១


អ្នកទោសនៅមន្ទីរស-២១


អ្នកទោសនៅម

មនុស្សបួនប្រាំនាក់គឺគ្រប់គ្រាន់ហើយ ។ ទោះបីជាសព្វថ្ងៃមន្ត្រីរាជការរបស់កម្ពុជាភាគច្រើននិយាយថា រាជរដ្ឋាភិបាលមិនគួរកំណត់ចំនួនមនុស្សដែលត្រូវកាត់ទោសទេ ប៉ុន្តែគំនិតបែបនេះស្ថិតនៅត្រង់ថាការសាកល្បងកាត់ទោសមនុស្សច្រើនធ្វើឲ្យខូចផលប្រយោជន៍ប្ដូរផ្ដាច់ច្របល់ ។ ដោយមិនមានកិច្ចព្រមព្រៀងរវាងសហព្រះរាជអាជ្ញាទាំងពីរ ការវិនិច្ឆ័យទោសរបស់តុលាការនឹងត្រូវចោទសួរឡើងដើម្បីដោះស្រាយជម្លោះ ។

ប្រសិនបើមានឱកាសដើម្បីបង្ហាញថា តុលាការនេះមិនមែនជាឧបករណ៍របស់រាជរដ្ឋាភិបាលកម្ពុជា គឺស្ថិតនៅពេលនេះហើយ ។ ជាអកុសល ច្បាប់របស់តុលាការបានចែងថា បញ្ហានេះនឹងមិនជាប់ទាក់ទងទៅនឹងទស្សនៈនៃការយល់ឃើញរបស់មហាជននោះទេ ។ គ្រប់ៗគ្នាគួរតែយល់ថា ទោះបីជាតុលាការនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ចំពោះប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិក៏ដោយ ក៏វាគ្រាន់តែជាបន្ដោលប៉ុណ្ណោះ ។ តុលាការនេះត្រូវតែអនុវត្តឲ្យគេបានឃើញតាមតែអាចធ្វើទៅបាននៅក្នុងពេលឆាប់ៗខាងមុខនេះ ។

វាពិបាកក្នុងការផ្ដល់ឲ្យថា តុលាការនេះគឺជាលទ្ធផលនៃការចរចារយៈពេល១០ឆ្នាំ រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ ក្នុងនាមតុលាការកូនកាត់មួយ វាមានរចនាសម្ព័ន្ធមួយមិនសូវល្អ ។ សហព្រះរាជអាជ្ញាក្នុងស្រុកនិងអន្តរជាតិ ហើយនឹងសហចៅក្រមស៊ើបអង្កេតត្រូវតែធ្វើកិច្ចព្រមព្រៀងជាមួយគ្នាមុនដំណើរការកាត់ក្ដីលើការសម្រេចចិត្ត ។ នៅពេលដែលមិនមានការយល់ស្របគ្នាជាឯកច្ឆន្ទ នោះតម្រូវឲ្យមានមតិភាគច្រើនលើសលប់ដែលយ៉ាងហោចណាស់ក៏មានចៅក្រមអន្តរជាតិមួយរូបដែរ ។ កិច្ចព្រមព្រៀងដែលមិនរឹងមាំនេះបានធ្វើឲ្យចំនួនអ្នកសង្ស័យមានការកើនឡើងអំពីសមត្ថភាពរបស់តុលាការដើម្បីត្រឡប់មករកប្រវត្តិសាស្ត្រកម្ពុជាដ៏យូរលង់នៃការធ្វើអន្តរាគមន៍ដែលមិនសមរម្យនៅក្នុងការអនុវត្តការវិនិច្ឆ័យទោស ។




កាលពីអតីតកាល មានការនិយាយបំផ្លើសដ៏ធ្ងន់ធ្ងរអំពីការរំលោភពុករលួយដែលអនុវត្តនៅក្នុងផ្នែកមួយនៃតុលាការកម្ពុជាដែលបានលុបបំបាត់ ។ អង្គការសហប្រជាជាតិបានស៊ើបអង្កេតអំពីបញ្ហានេះនៅខែកញ្ញា ប៉ុន្តែមិនបានរកឃើញអ្វីទេ ។ ការរីករាលដាលដែលខុះការបើកចំហនៅក្នុងតុលាការនេះ គឺមិនបានជួយអ្វីទាល់តែសោះ ។ នេះគឺជាស្ថានភាពធ្ងន់ធ្ងរជាពិសេសមួយនៅខណៈពេលដែលការវិនិច្ឆ័យទោសនៅពេលខាងមុខធ្វើឲ្យប៉ះពាល់ដល់ការអះអាងផ្នែកច្បាប់ ។

ប៉ុន្តែឧបសគ្គធំបំផុតរបស់តុលាការគឺជាការលំបាកថ្មីមួយដែលរារាំងមិនឲ្យមានការកាត់ទោសនៅលើកក្រោយទៀត ។ វាត្រូវបានស្នើសុំជាយូរមកហើយថាឲ្យមានការកំណត់ការកាត់ទោសទៅលើចុងចោទទាំងប្រាំរូបជាអតីតមេដឹកនាំខ្មែរក្រហមដែលមិនមានជាប់ទាក់ទងទៅនឹងបុគ្គលជាន់ខ្ពស់របស់រាជរដ្ឋាភិបាលនាពេលថ្មីៗនេះ ដែលជាផ្នែកមួយដ៏សំខាន់នៃកិច្ចព្រមព្រៀងដែលមិនមានសរសេរជាលាយលក្ខណ៍អក្សរដែលធ្វើឲ្យរាជរដ្ឋាភិបាលព្រមទទួលយកតុលាការនេះ ។ មន្ត្រីជាន់ខ្ពស់បច្ចុប្បន្ននៅក្នុងជួររាជរដ្ឋាភិបាលមួយចំនួនមានការព្រួយបារម្ភពីផលវិបាកនៃការបង្កើតតុលាការគាំទ្រដ៏មានតម្លាភាពនិងមានការទទួលខុសត្រូវ ។ ការផ្ដល់ឲ្យនូវកម្រិតនៃបទឧក្រិដ្ឋនិងទំហំបទឧក្រិដ្ឋនៃការទទួលខុសត្រូវលើដំណើរការវិនិច្ឆ័យទោសដែលតូចចង្អៀត ហើយយកចិត្តទុកដាក់តែលើបុគ្គលទាំងនោះប៉ុណ្ណោះអាចជាការបោកបញ្ឆោត ។

នេះជាពេលសម្រាប់រដ្ឋាភិបាលម្ចាស់ជំនួយដែលគាំទ្រតុលាការនេះ រួមមានប្រទេសជប៉ុន បារាំង និងសហរដ្ឋអាមេរិកដែលថ្មីៗនេះបានសន្យាផ្ដល់ជំនួយដោយមិនកំណត់ចំនួនជាលើកដំបូង ដោយទទូចសុំឲ្យតុលាការនេះអនុវត្តដូចច្បាប់តុលាការដែលមានចែង ។ អ្វីដែលមិនប្រាកដអាចក្បត់ទៅនឹងព្រលឹងរបស់មនុស្សពីរលាននាក់ដែលបានស្លាប់ និងមនុស្សជាច្រើនទៀតដែលស៊ូទ្រាំទាំងរបួសផ្នែករូបរាងកាយនិងសតិអារម្មណ៍ ។ ទាំងជនរងគ្រោះនៅសម័យខ្មែរក្រហមនិងអ្នកជំនាន់ក្រោយនៃប្រជាជនកម្ពុជាគួរតែសមនឹងទទួលបាននូវការស្មោះត្រង់ ការវិនិច្ឆ័យទោសដោយរាប់បញ្ចូលទាំងអំពើដ៏ឃោរឃៅអស់រយៈពេល២០សតវត្សរ៍ ។

**ហ្វូសស្ទូន ទេម**

# "ល្ខោននិយាយ : រឿងទម្លាយភាពស្ងប់ស្ងាត់" បានធ្វើឱ្យប្រទេសកម្ពុជាត្រូវប្រឈមនឹងអតីតកាលរបស់ខ្លួន

សិល្បៈអាចជាឧបករណ៍ដ៏មានឥទ្ធិពលក្នុងការជួយជនរងគ្រោះដោះស្រាយនូវភាពឈឺចាប់ដែលមិនអាចផ្សះផ្សាបាននិងវិបត្តិផ្លូវចិត្តដ៏ធ្ងន់ធ្ងរ ជាពិសេសគឺនៅពេលដែលមធ្យោបាយដទៃទៀតមិនមានប្រសិទ្ធភាព ។ នៅក្នុងប្រទេសកម្ពុជាជាកន្លែងដែលមនុស្សរាប់លាននាក់បានឆ្លងកាត់បទពិសោធន៍នូវអំពើអមនុស្សធម៌ និងអំពើព្រៃផ្សៃអស់រយៈពេលបួនឆ្នាំនៅក្រោមរបបខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥-១៩៧៩ គេឃើញមានពេទ្យផ្នែកចិត្តសាស្ត្រតិចជាងសាមសិបនាក់ប៉ុណ្ណោះនៅក្នុងប្រទេសនេះ ។ ជនរងគ្រោះដែលនៅរស់រានមានជីវិតអាចចាំបាននូវអ្នកដែលបានប្រព្រឹត្តអំពើទាំងនេះអស់ជាងពីរទសវត្សរ៍មកហើយ ។ យុត្តិធម៌ផ្លូវច្បាប់រួមជាមួយការបកស្រាយទាំងចាំបាច់និងមិនចាំបាច់ ចុងក្រោយទើបតែបានលេចរូបរាងជាតុលាការកាត់ក្តីខ្មែរក្រហមថ្មីៗនេះប៉ុណ្ណោះ ។ បេសកកម្មរបស់តុលាការកាត់ក្តីខ្មែរក្រហមគឺធ្វើការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួនតិចជាងដប់រូប ប៉ុន្តែតើត្រូវប្រើយន្តការអ្វីដើម្បីដោះស្រាយជាមួយជនដៃដល់ ដែលពិតជាបានប្រព្រឹត្តនូវអំពើឃោរឃៅទាំងនេះជាមួយនិងជនរងគ្រោះដែលស្គាល់មុខពួកគេ? អ្នកស្រីនាយកផ្នែកភាពយន្ត អានីម៉ារី ព្រីនស៍ ជឿថាសិល្បៈអាចជាផ្នែកមួយនៃចម្លើយ ។ អ្នកស្រីសង្ឃឹមថា ការសម្តែងរបស់អ្នកស្រី «រឿងទម្លាយភាពស្ងប់ស្ងាត់» នឹងជួយជំរុញឲ្យមានកិច្ចពិភាក្សាជាចំហដែលជាផ្នែកមួយក្នុងដំណើរការផ្សះផ្សាជាតិនៅកម្ពុជា ។

ការចូលរួមរបស់អ្នកស្រី ព្រីនស៍ ទៅក្នុងការសម្តែងបែបនេះបានចាប់ផ្តើមឡើងតាំងពីបួនឆ្នាំមុន នៅឯសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលអ្នកស្រីបានបង្រៀននៅក្នុងសិក្ខាសាលាមួយនៅទីនោះ ។ អ្នកស្រីបានធ្វើបទបង្ហាញនិងទាញចំណាប់អារម្មណ៍របស់អ្នកចូលរួមនៅទីនោះទៅនឹងល្ខោនសម័យបច្ចុប្បន្នរបស់លោកខាងលិច ។ នៅក្នុងអំឡុងពេលធ្វើបទបង្ហាញរយៈពេលពីរសប្តាហ៍ គេឃើញមានអ្នកចូលរួមជាច្រើននាក់បានប្រាប់អ្នកស្រីនូវអ្វីដែលពួកគាត់បានទទួលរងការឈឺចាប់ក្នុងរបបប្រល័យពូជសាសន៍ ។ រឿងទាំងនេះបានក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការសម្តែងដំបូងរបស់អ្នកស្រី ព្រីនស៍ ដែលមានចំណងជើងថា «បីឆ្នាំប្រាំបីខែម្ភៃថ្ងៃ» ដែលជាចំណងជើងមួយសំដៅលើចំនួនថ្ងៃដ៏ពិតប្រាកដក្នុងពេលដែលរបបខ្មែរក្រហមបានកាន់កាប់អំណាច ។ ការសម្តែងលើកទីពីររបស់អ្នកស្រី ដែលផលិតដោយក្រុមសម្តែងសិល្បៈអម្រឹតា បានពង្រីកមូលន័យរឿងនិងបញ្ហាជាច្រើនដែលដោះស្រាយលើកដំបូងដោយបញ្ចូលជាមួយនឹងសាច់រឿងរបស់ជនដែលនៅរស់រានមានជីវិត និងបន្ថែមនូវភាពស្មុគស្មាញនៃវិធានការដោះស្រាយបញ្ហាទាំងនោះនៅពេលបច្ចុប្បន្ន ។

«រឿងទម្លាយភាពស្ងប់ស្ងាត់» គឺជាការសម្តែងនូវសាច់រឿងចំនួនប្រាំពីរដែលឆ្លុះបញ្ចាំងអំពីចំណងមិត្តភាពដែលពោរពេញដោយវិបត្តិរវាងអ្នករស់រានមានជីវិតដែលមានទាំងជនរងគ្រោះនិងជនដៃដល់ក្នុងរបបនោះ ។ នេះគឺជាការខិតខំប្រឹងប្រែងដែលបង្កើតឡើងដើម្បីទម្លាយអាថ៌កំបាំងជុំវិញការឈឺចាប់កាលពីអតីតកាលរបស់កម្ពុជា ដូច្នេះវាក៏បានក្លាយជាចំណងជើងនៃការសម្តែងនេះ ។ សាច់រឿងទាំងនេះត្រូវបានសម្តែងដោយនិស្សិតស្រីបួននាក់របស់សាលាមធ្យមវិចិត្រសិល្បៈ ដែលពួកគេនឹងសម្តែងទាំងតួអង្គប្រុស និងតួអង្គស្រីនៅក្នុងសាច់រឿង ។ បញ្ហាក្នុងសាច់រឿងដែលត្រូវបានដោះស្រាយគឺហាក់បីដូចការពិត ដោយមានអមជាមួយនឹងបទចំរៀងមនោសញ្ចេតនា រឿងនិទាន និងការរាំរបាំ ។

ក្នុងសាច់រឿងមួយ អតីតកម្មាភិបាលខ្មែរក្រហមម្នាក់បានលន់តួអង្វរសុំការលើកលែងទោសពីម្តាយរបស់ខ្លួន ខណៈពេលដែលខ្លួនបានជួបគាត់នៅផ្សារកាលពីថ្ងៃសៅរ៍ ប៉ុន្តែមិនបាននិយាយជាមួយគាត់ ។ នៅពេលដែលពួកគេកំពុងនិយាយឆ្លើយឆ្លងគ្នា ម្តាយរបស់សមមិត្តបានឆ្លើយតបថា «វានឹងមិនអាចដូចមុនទេ វានឹងមិនអាចដូចមុនទេកូនម្តាយ» ។ សាច់រឿងមួយទៀតនិយាយអំពីអតីតកងកុមារពីរនាក់ដែលពួកគេធ្វើការដោះស្រាយបញ្ហា

*អតីតកាលរបស់គេខុសៗពីគ្នា ។ កុមារម្នាក់មានវិប្បដិសារីយ៉ាងខ្លាំង ហើយក៏ធ្វើដំណើរទៅកាន់មន្ទីរឃុំឃាំងជាកន្លែងដែលការសម្លាប់និងការធ្វើទារុណកម្មបានកើតឡើងដើម្បីសុំការលើកលែងទោស ។ ចំណែកកុមារម្នាក់ទៀតនៅតែការពាររាល់សកម្មភាពរបស់ខ្លួននៅអំឡុងពេលថ្ងៃ តែត្រូវសុខចិត្តចុះចាញ់សុបិន្តអាក្រក់នៅពេលយប់ពេលគាត់ចូលដេក ។ សាច់រឿងទីបីគឺផ្តោតជាចម្បងលើបុរសម្នាក់ដែលនឹងឈានទៅរកការសងសឹកចំពោះមរណភាពរបស់ឪពុកគាត់ ហើយបច្ចុប្បន្ននេះត្រូវបានធ្វើឲ្យវាវែករវាងពុទ្ធឱវាទស្តីអំពីកម្មផលនិងកំហឹងឈឺចាប់ផ្ទាល់ខ្លួន ។ ចំណែកសាច់រឿងបួនទៀតបានឆ្លុះបញ្ចាំងនូវអារម្មណ៍ដែលប៉ះទង្គិចស្រដៀងគ្នារវាងអ្នករស់រានមានជីវិត ហើយក្នុងចំណោមពួកអ្នកទាំងនោះវិធានការដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់ពួកគាត់គឺខុសដោយឡែកៗពីគ្នា ។ រាល់សាច់រឿងទាំងអស់គឺធ្វើការបែករំលែកមូលន័យរឿងនៃភាពស្ងៀមស្ងាត់ដែលស្ថិតក្នុងលក្ខណៈជាការបដិសេធកិច្ចសន្ទនាគ្មានខ្លឹមសារ ឬការនិយាយមិនបាន ។ មូលន័យរឿងនៃភាពស្ងប់ស្ងាត់ គឺពិតជាឃើញច្បាស់ ព្រច្បាស់និងពិតប្រាកដ ដែលឆ្លុះបញ្ចាំងនូវមនោសញ្ចេតនានិងការគិតពិចារណារបស់ទស្សនិកជន ។*

*រឿងទម្លាយភាពស្ងប់ស្ងាត់របស់អ្នកស្រី ព្រីនស៍ សង្ឃឹមថានឹងទាក់ទាញទស្សនិកជនកាន់តែច្រើនជាងខ្សែភាពយន្តដំបូងរបស់អ្នកស្រី ហើយជាមួយគ្នានេះ គេឃើញមានគម្រោងជាច្រើនទៀតសម្រាប់ដំណើរទស្សនកិច្ចទូទាំងប្រទេសផងដែរ ។ ដោយមានកិច្ចគាំទ្រពីស្ថានទូតរបស់រាជាណាចក្រហូឡង់និងអង្គការមួយចំនួនរួមមានមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់នូវឯកសារស្រាវជ្រាវ ហើយដែលនាំមកនូវផលិតកម្មរឿងទាំងនេះទៅកាន់បណ្តាខេត្តផ្សេងៗទៀត ដែលជាផ្នែកមួយនៃសកម្មភាពឈានមុខរបស់ខ្លួននោះ ការសម្តែង «រឿងទម្លាយភាពស្ងប់ស្ងាត់នេះ» មានសក្តានុពលដែលផ្តល់ជាការបរិច្ចាគដ៏មានសារសំខាន់មួយទៅក្នុងដំណើរការផ្សះផ្សានៃភាពឈឺចាប់របស់កម្ពុជា ។ ខណៈពេលដែលភាពស្ងប់ស្ងាត់ធ្វើការគ្រប់គ្រងអ្នករស់រានមានជីវិត ហើយប្រព័ន្ធច្បាប់មិនអាចជឿទុកចិត្តបាននោះ ការសម្តែងរបស់អ្នកស្រី ព្រីនស៍ នេះ គឺជាគន្លឹះមួយក្នុងចំណោមគន្លឹះដទៃទៀតទៅនឹងការបកស្រាយជំងឺផ្លូវចិត្តដ៏ធ្ងន់ធ្ងរ ហើយនៅក្នុងដំណើរការនេះ វានឹងធ្វើឲ្យជាសះស្បើយនូវការឈឺចាប់នេះបន្តិចម្តងៗ ។ យន្តការក្នុងស្រុកសម្រាប់ដោះស្រាយវិបត្តិផ្លូវចិត្តនេះត្រូវតែធ្វើឲ្យបានព្រដល់ប្រជាជនក្នុងស្រុក ដូចនេះហើយការសម្តែងនេះអាចក្លាយជាឧបករណ៍ដ៏សំខាន់ប្រចាំកម្ពុជា ។ លោក ឆាំង យុ ជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ការសម្តែងរបស់អ្នកស្រី ព្រីនស៍ «នឹងធ្វើទំនាក់ទំនងយ៉ាងល្អជាមួយនិងបេះដូងរបស់អ្នកភូមិទាំងអស់» ហើយក៏ជឿផងដែរថា ការសម្តែងប្រភេទនេះ គឺពិតជាមានសារសំខាន់ណាស់ ពីព្រោះវាបានជួយឲ្យយើង «ស្គាល់នូវសម្រស់នៅក្នុងភាពអន្ធការ ហើយឲ្យតម្លៃវា» ។ ខណៈពេលដែលអ្នកខ្លះអាចមិនយល់ស្របថា សម្រស់តែងតែមាននៅក្នុងភាពអន្ធការនោះ មនុស្សគ្រប់រូបអាចយល់ស្របភាពអន្ធការគឺជាផ្នែកមួយនៃជីវិតរបស់ពួកយើង ហើយសម្រស់អាចកើតឡើងក្នុងលក្ខណៈដែលការឆ្លុះបញ្ចាំងដ៏ពិតប្រាកដនៃភាពអន្ធការ គឺត្រូវបានបង្ហាញយ៉ាងប៉ិនប្រសប់តាមរយៈសិល្បៈ ។ ស្របពេលដែលប្រទេសកម្ពុជាព្យាយាមជម្នះភាពអន្ធការរបស់ខ្លួន ការសម្តែងដូចជារបស់អ្នកស្រី ព្រីនស៍ ផ្តល់នូវក្តីសង្ឃឹមសាជាថ្មីដល់កម្លាំងចិត្តរបស់ប្រជាជនខ្មែរគ្រប់រូប ។*

*«រឿងទម្លាយភាពស្ងប់ស្ងាត់» ដែលផ្តល់ការចូលរួមទស្សនាដោយឥតគិតថ្លៃ និងមានការប្រែសម្រួលជាភាសាអង់គ្លេសនិងចាក់ជូនទស្សនានៅទីក្រុងភ្នំពេញថ្ងៃទី២១ និង ២២ វេលាម៉ោង ៦:៣០នាទី នៅសាលតាំងពិព័រណ៍ ។ ចំណែកទីតាំងដែលបានកំណត់ផ្សេងទៀតរួមមាន ខេត្តកំពង់ចាម ឃុំអំពៅព្រៃ និងឃុំទៀនក្នុងខេត្តកណ្តាល ហើយនៅឃុំអង្គរបុរី (នៅក្នុងស្រុកព្រៃកប្បាស) ខេត្តតាកែវ ។* **កែវ ជាសីល**


*ឈុតមួយនៃការសម្តែងក្នុងរឿងទម្លាយភាពស្ងប់ស្ងាត់*

# ការសិក្សាអប់រំពីអំពើប្រល័យពូជសាសន៍ក្នុងបរិបទសកលលោក ការសិក្សាប្រៀបធៀបអំពី របបហ្វូឡូខសត៍ និងរបបខ្មែរក្រហម

**(តចប់)**

*ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀននៅតែជាបញ្ហាសម្រាប់កម្ពុជានាពេលបច្ចុប្បន្នដដែល ។ ប្រវត្តិសាស្ត្រគឺជាចំណុចកណ្តាលមួយនៃភាពចម្រូងចម្រាស់នៅក្នុងការអប់រំរបស់ប្រទេសកម្ពុជា ដោយសារតែនយោបាយនិងប្រវត្តិនៃជម្លោះដ៏ខ្លាំងក្លាបំផុតនៃបក្សកុម្មុយនីស្ត ។ យ៉ាងណាមិញ ឫសគល់នៃភាពចម្រូងចម្រាស់នេះគឺដោយសារមន្ត្រីជាន់ខ្ពស់ជាច្រើននៃគណបក្សប្រជាជនកម្ពុជាដែលកាន់កាប់អំណាចនាពេលបច្ចុប្បន្ននេះជាអតីតសមាជិកខ្មែរក្រហម ។ ម្យ៉ាងវិញទៀត ការសម្រេចចិត្តនៃការរៀបចំមាតិកានៃមុខវិជ្ជាសិក្សាគឺនៅតែស្ថិតនៅក្នុងដៃរបស់អ្នកនយោបាយដដែល ចំណែកឯការពិពណ៌នានៃប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្ននៅក្នុងសៀវភៅមេរៀនសិក្សាសង្គមនៅតែមានភាពចម្រូងចម្រាស់ផ្នែកនយោបាយនៅឡើយ ដូចមាននៅក្នុងសៀវភៅមេរៀនថ្នាក់ទី១២ (បោះពុម្ពឆ្នាំ២០០១) បាននិយាយពីភាពជោគជ័យរបស់គណបក្សប្រជាជនកម្ពុជានៅក្នុងការបោះឆ្នោតជាតិឆ្នាំ១៩៩៨ ប៉ុន្តែមិនបាននិយាយអំពីជ័យជម្នះរបស់គណបក្សហ៊្វុនស៊ិនប៉ិចនៅក្នុងការបោះឆ្នោតជាតិលើកទីមួយនៅឆ្នាំ១៩៩៣នោះទេ។ សម្តេច នរោត្តម បុណ្ណរិទ្ធិ ដែលជាប្រធានគណបក្សហ៊្វុនស៊ិនប៉ិចនិងប្រធាននៃរដ្ឋសភាជាតិកម្ពុជា បានធ្វើការរិះគន់ពីការខ្វះខាតក្នុងការពិពណ៌នានូវជ័យជម្នះរបស់គណបក្សហ៊្វុនស៊ិនប៉ិច ហើយទ្រង់ក៏ធ្វើការស្នើសុំឲ្យមានការត្រួតពិនិត្យឡើងវិញផងដែរ ។ ដើម្បីឆ្លើយតបផ្នែកដែលនិយាយអំពីប្រវត្តិសាស្ត្រទំនើបកម្ពុជាដែលរួមទាំងប្រវត្តិនៃសម័យខ្មែរក្រហម គឺត្រូវបានលុបចោលទាំងស្រុងចេញពីសៀវភៅមេរៀនថ្នាក់ទី១២ ។ បន្ទាប់មក នៅពាក់កណ្តាលឆ្នាំសិក្សា២០០២ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឲ្យដកសៀវភៅសិក្សាសង្គមថ្នាក់ទី១២ទាំងអស់ចេញពីកម្មវិធីសិក្សា ។ ទន្ទឹមនឹងនេះផងដែររដ្ឋាភិបាលបានធ្វើការអភិវឌ្ឍលើកម្មវិធីសិក្សាតិចតួចបំផុត ហើយក៏មិនបានបោះពុម្ពអត្ថបទថ្មីៗដែលផ្តោតសំខាន់ទៅលើរបបខ្មែរក្រហមនោះដែរ ។ រហូតមកដល់បច្ចុប្បន្ននេះ សិស្ស និស្សិតកម្ពុជាសិក្សាអំពីប្រវត្តិសាស្ត្រដោយមិនមានសៀវភៅមេរៀនច្បាស់លាស់នៅឡើយទេ ។*

*ក្រសួងអប់រំរបស់ប្រទេសកម្ពុជាដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៨០ បានធ្វើការគ្រប់គ្រងយ៉ាងរឹងមាំទៅលើកម្មវិធីសិក្សាសម្រាប់គ្រប់កម្រិតទាំងអស់ ។ ក្រសួងបានធ្វើការណែនាំគ្រូបង្រៀន អ្នកនិពន្ធសៀវភៅ និងអ្នករៀបចំកម្មវិធីសិក្សាអំពីប្រធានបទដែលត្រូវបង្រៀននិងគោលដៅដ៏សំខាន់បំផុតក្នុងការបង្រៀនប្រវត្តិសាស្ត្រ ។ យ៉ាងណាមិញ កាលពីប៉ុន្មានឆ្នាំមុនមានការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងករណីដែលថាការសិក្សាអប់រំពីអំពើប្រល័យពូជសាសន៍ត្រូវបានរដ្ឋាភិបាលយកចិត្តទុកដាក់ ហើយនឹងចាប់យកជំហានវិជ្ជមានមួយដើម្បីធ្វើការពិចារណាទៅលើករណីនេះ ។*

*ដំណើរការនៃការអភិវឌ្ឍកម្មវិធីសិក្សាអំពី «ការអប់រំអំពើប្រល័យពូជសាសន៍» នៅកម្ពុជាមានការរីកចម្រើនគួរឲ្យកត់សម្គាល់នេះ គឺមួយផ្នែកធំកើតឡើងដោយសារតែការខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាអង្គការក្រៅរដ្ឋាភិបាលមួយនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅមួយដែលមានចំណងជើងថាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ហើយថែមទាំងធ្វើការស្នើសុំឲ្យរដ្ឋាភិបាលរួមបញ្ចូលសៀវភៅនេះឬក៏ផ្នែកខ្លះនៃសៀវភៅនេះនៅក្នុងកម្មវិធីសិក្សាថ្នាក់វិទ្យាល័យ ។ ការឆ្លើយតបរបស់រដ្ឋាភិបាលដំបូងគឺមិនបានផ្តល់នូវហេតុផលច្រើននោះទេសម្រាប់ភាពសុទិដ្ឋិនិយមនេះ ។*

*នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៦ សម្តេចនាយករដ្ឋមន្ត្រី*

ហ៊ុន សែន បានសរសេរលិខិតមួយច្បាប់ផ្ញើជូនលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ឲ្យបង្កើតគណៈកម្មាធិការរដ្ឋាភិបាលមួយដើម្បីត្រួតពិនិត្យមើលនិងពិចារណាឡើងវិញនូវសំណើរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងនៅថ្ងៃទី៦ ខែសីហា ក្រោមក្រឹត្យច្បាប់របស់រាជរដ្ឋាភិបាល ។ គណៈកម្មាធិការនេះមានសមាជិក៧នាក់ ដែលមានលោក អ៊ឹម សិទ្ធី រដ្ឋលេខាធិការនៃក្រសួងអប់រំជាប្រធាន ។ ចំណែកឯសមាជិកដទៃទៀតវិញគឺជាមន្ត្រីមកពីក្រសួងអប់រំនិងរាជបណ្ឌិតសភាកម្ពុជា ។ មិនមានអ្នកជំនាញឬអ្នកអប់រំឯកជនណាត្រូវបានអនុញ្ញាតឲ្យពាក់ពន្ធ័នៅក្នុងដំណើរការនេះឡើយ ។

នៅថ្ងៃទី១៨ ខែធ្នូ គណៈកម្មាធិការនេះបានជួបពិភាក្សាទៅលើសំណៅនៃសៀវភៅនេះ ។ លោក ស៊ិន សំណាង សមាជិកនៃគណៈកម្មាធិការបានផ្តល់យោបល់ថា សៀវភៅនេះមានន័យវែងឆ្ងាយហួសពីសម័យឆ្នាំ១៩៧៥ដល់១៩៧៩ ។ សៀវភៅនេះនិយាយពីរបបនយោបាយនីមួយៗ...ដែលគួរតែត្រូវទុករយៈពេលយ៉ាងតិចណាស់៦០ឆ្នាំដើម្បីលើកយកមកពិភាក្សា ។ យ៉ាងណាមិញ លោក កួយ ធាវី មានយោបល់ថា ពួកយើងមានការព្រួយបារម្ភថា ប្រសិនបើយើងបង្ហាញពីអំពើហិង្សាច្រើនពេក នោះវានឹងអាចធ្វើឲ្យមានអំពើហិង្សាកាន់តែច្រើនឡើងៗ ។ រីឯសមាជិកដទៃទៀតបានលើកឡើងឲ្យមានការផ្លាស់ប្តូរនៅក្នុងសៀវភៅនេះ ហើយលុបចោលនូវជំពូកខ្លះចោល ។ ទោះបីជាយ៉ាងណាលោក អ៊ឹម សិទ្ធី ក៏បានផ្តល់នូវការគាំទ្រចំពោះការប្រឹងប្រែងក្នុងការបោះពុម្ពជាសៀវភៅនេះឡើង ។ ក្នុងអំឡុងជំនួបនោះគឺបានលើកឡើងនូវពាក្យរបស់លោកដែលថា ៖

អត្ថបទនេះសរសេរបានល្អណាស់ ហើយបានរៀបចំយ៉ាងល្អសម្រាប់អ្នកសិក្សាប្រវត្តិសាស្ត្រនៅថ្ងៃក្រោយ ។ ការសរសេរអត្ថបទប្រវត្តិសាស្ត្រដើម្បីដាក់ចូលក្នុងកម្មវិធីសិក្សាជាផ្លូវការសម្រាប់ផ្តល់នូវចំណេះដឹងទូទៅគឺជួបការលំបាកច្រើនណាស់ ។ ទោះបីជាប្រទេសជប៉ុនដែលធ្លាប់មានបទពិសោធន៍ខាងសរសេរសៀវភៅប្រវត្តិសាស្ត្រក៏នៅតែមានជួបបញ្ហាជាច្រើននៅក្នុងការសរសេរប្រវត្តិសាស្ត្រវាងកូរ៉េនិងចិនដែរ ។ សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះគឺគ្រាន់តែអាចប្រើប្រាស់ធ្វើជាឧបករណ៍ជំនួយបន្ថែមក្នុងការសរសេរសៀវភៅមេរៀនប្រវត្តិ-សាស្ត្រសម្រាប់ចំណេះដឹងទូទៅតែប៉ុណ្ណោះ ។

នៅចុងបញ្ចប់ សមាជិកនៃគណៈកម្មាធិការរៀបចំកែលម្អឯកសារ «ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» បានយល់ស្របទាំងអស់គ្នាថា សៀវភៅអត្ថបទនេះនឹងត្រូវបានប្រើប្រាស់ជាឧបករណ៍ពិភាក្សាបន្ថែមដ៏ចម្បងនិងជាមូលដ្ឋានគ្រឹះក្នុងការសរសេរមេរៀនប្រវត្តិសាស្ត្រសម្រាប់សិស្សក្នុងការអប់រំទូទៅ ។ បន្ទាប់មក នៅឆ្នាំ២០០៨ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបន្តផ្ញើសំបុត្រទៅក្រសួងអប់រំដើម្បីជំរុញឲ្យក្រសួងទទួលយកសំណើរបស់មជ្ឈមណ្ឌល ក្នុងគោលបំណងពង្រីកនូវការអប់រំពីអំពើប្រល័យពូជសាសន៍ ក៏ដូចជាដើម្បីលើកតម្កើនសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះឲ្យមានសារសំខាន់លើសពីអ្វីដែលត្រូវបានក្រសួងចាត់ទុកថាជាឧបករណ៍សម្រាប់ជំនួយ ។ នៅក្នុងដំណាក់កាលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាស្នើសុំថាមជ្ឈមណ្ឌលនឹងអនុវត្តនូវសកម្មភាពសំខាន់ៗបួនក្នុងការសហការជាមួយក្រសួង ។

- ការរៀបចំសម្ភារៈណែនាំសម្រាប់គ្រូបង្រៀន
- សិក្ខាសាលាស្តីពីកម្មវិធីគរុកោសល្យសម្រាប់គ្រូបង្រៀន
- ការរៀបចំកូនសិស្សដើម្បីឲ្យក្លាយជាគ្រូបង្រៀន
- ការបកប្រែសៀវភៅមេរៀនជាភាសា៥ ក្រៅពីខ្មែរ និងអង់គ្លេសមានដូចជា ៖ ថៃ វៀតណាម ម៉ង់ដារិន ជប៉ុន និងភាសាបារាំង ។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ ក្រសួងអប់រំបានផ្ញើលិខិតជាផ្លូវការមួយដល់មជ្ឈមណ្ឌលឯកសារកម្ពុជាថាយល់ព្រមទៅលើចំណុចទាំងបួននេះ ។ រដ្ឋាភិបាលអនុញ្ញាតឲ្យប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រដែលមានស្រាប់ និងកែលម្អកម្មវិធីគរុកោសល្យតាមរយៈគំនិតរបស់ឯកជន ។ នេះគឺជាលើកទីមួយហើយដែលរដ្ឋាភិបាលបានធ្វើការសម្រេចចិត្តក្នុងការប្រើប្រាស់អ្វីទាំងអស់ជាជាងសៀវភៅមេរៀនប្រវត្តិសាស្ត្រ និងការរចនាកម្មវិធីសិក្សាដែលគាំទ្រដោយរដ្ឋ ។ នៅក្នុងលិខិតនោះបានអះអាងថា មជ្ឈមណ្ឌលឯកសារកម្ពុជាអាចធ្វើការចូលរួមយ៉ាងជិតស្និទ្ធជាមួយនឹងនាយកដ្ឋានស្រាវជ្រាវគរុកោសល្យនិងនាយកដ្ឋានហ្វឹក

ហ៊ឹនគ្រូបង្រៀននៃក្រសួងអប់រំ (ក៏ដូចជាអ្នកជំនាញការអន្តរជាតិលើការអប់រំពីអំពើប្រល័យពូជសាសន៍) ដើម្បីអនុវត្តគម្រោងនេះ ។ រដ្ឋាភិបាលក៏បានធ្វើការអះអាងអំពីសារសំខាន់នៃការបង្រៀនប្រវត្តិសាស្ត្រពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាដែរ ។ នៅពាក់កណ្តាលឆ្នាំ២០០៨ ប្រទេសកម្ពុជាកំពុងតែស្ថិតនៅផ្លូវមួយក្នុងការកែប្រែប្រវត្តិសាស្ត្រពីអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហម ពីប្រធានបទដែលហាមឃាត់ឲ្យទៅជាប្រធានបទមួយដែលចាំបាច់នៅក្នុងកម្មវិធីសិក្សាថ្នាក់វិទ្យាល័យ ។

យ៉ាងណាមិញ ទោះបីជារបបខ្មែរក្រហមបានដួលរំលំអស់រយៈពេល៣០ឆ្នាំហើយក៏ដោយ ក៏ប្រវត្តិសាស្ត្រនៃរបបប្រល័យពូជសាសន៍របស់កម្ពុជា នៅតែជាព្រឹត្តិការណ៍មួយដែលងាយនឹងទទួលប្រតិកម្មផ្នែកនយោបាយជាទីបំផុត ដោយសារតែវាទាក់ទងទៅនឹងរបបមុន ។ និយាយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺមិនអាចគេចផុតពីការពិភាក្សាពីព្រឹត្តិការណ៍នៅក្នុងអំឡុងសម័យអាណានិគមបារាំង ការគ្រប់គ្រងរបស់ សម្តេច សីហនុ របបសាធារណរដ្ឋខ្មែរ និងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅកម្ពុជានោះទេ ។ ម្យ៉ាងទៀត ក៏មិនអាចឃ្លាតឆ្ងាយពីការពិភាក្សាពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជា អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជានិងរាជាណាចក្រទីពីររបស់កម្ពុជានោះទេ ។ ទំហំនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហមនឹងមិនអាចយល់បាននោះទេ ប្រសិនបើគ្មានការនិយាយណែនាំពីទម្រង់នៃចលនាកុម្មុយនីស្តដែលកើតមានឡើងនៅប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៤០ រហូតដល់ការដួលរលំទាំងស្រុងនៅក្នុងឆ្នាំ១៩៩៩ ។ ទម្រង់នេះនឹងអនុញ្ញាតឲ្យសិស្សធ្វើការតាមដាននូវការរីកចម្រើនរបស់ចលនាខ្មែរក្រហម និងចេះភ្ជាប់ចលនាទាំងនេះទៅនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសម្រាប់ការស្រាវជ្រាវទៅថ្ងៃអនាគត និងការយល់ដឹងទូលំទូលាយជាងមុន ។ ជាងនេះទៅទៀតនឹងអាចជួយថែរក្សាការចងចាំអំពីអតីតកាលដើម្បីការពារទៅថ្ងៃក្រោយ ដូចលោក យ៉ែរ អូរុន និយាយថា «ការបំភ្លេចគឺតែងតែមានការចងចាំដើរតាមជានិច្ច» ។

## ការវិភាគសៀវភៅមេរៀន

តាំងពីដើមរៀងមក សៀវភៅមេរៀនទាំងទៅលើអំពើប្រល័យពូជសាសន៍កម្ពុជាក្នុងឆ្នាំ១៩៨០ និងលើរបបហ្វូឡូខសត៍ក្នុងឆ្នាំ១៩៦០ គឺសុទ្ធតែត្រូវបានបង្កើតឡើងដោយក្រសួងអប់រំ ។ ទាំងនេះមិនអាចជៀសផុតបានទេកាលដែលថា ប្រទេសនីមួយៗមិនថាតែក្នុងពេលមានសន្តិភាពឬក្រោយពេលដែលទើបតែកើតមានអំពើប្រល័យពូជសាសន៍ ឬក៏ជម្លោះយ៉ាងព្រៃផ្សៃរួចហើយ គឺសុទ្ធតែនឹងរៀបចំអត្ថបទទាំងនោះដោយយោងទៅតាមទស្សនៈសង្គមនិងគោលបំណងរបស់រដ្ឋាភិបាល ។ ដូចលោក ដាញ៉ែល បារតាល់ សរសេរថា សៀវភៅមេរៀនគឺបានបង្ហាញពីតថភាពនៃសង្គមទៅដល់សិស្ស ។ សៀវភៅទាំងនេះពង្រឹងនូវតម្លៃនៃទស្សនៈផ្ទាល់ខ្លួនរបស់សង្គម ឬនិយាយឲ្យចំទៅគឺការគ្រប់គ្រងរបស់ពួកវរជន ហើយវាត្រូវការបទដ្ឋានគោលដៅសង្គម ធម្មជាតិនៃទំនាក់ទំនងជាមួយក្រុមមនុស្សផ្សេងៗ និងការយល់ឃើញរបស់ក្រុមផ្សេងៗ ។ សិស្សតែងតែអាចទទួលការយល់ដឹងដំបូងបំផុតអំពីប្រវត្តិសាស្ត្ររបស់ពួកគេនិងព្រឹត្តិការណ៍សង្គមផ្សេងៗតាមរយៈសៀវភៅមេរៀនទាំងនេះ ។ ក្នុងការរៀបចំសៀវភៅមេរៀនគ្រប់ប្រភេទទាំងអស់ ជាពិសេសប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍គឺទាមទារឲ្យអ្នកនិពន្ធប្រើប្រាស់នូវភាពពិតមិនលម្អៀង និងស្មើភាពគ្នាក្នុងន័យនយោបាយ ។

សៀវភៅប្រវត្តិសាស្ត្រ ភូមិសាស្ត្រ អក្សរសាស្ត្រ និងសៀវភៅហែព្រូនៅក្នុងប្រទេសអ៊ីស្រាអែលក្នុងឆ្នាំ១៩៦០ គឺត្រូវបានតាក់តែងឡើងដើម្បីបង្រៀនក្មេងៗជ្វីហ្វក្នុងប្រទេសអ៊ីស្រាអែលសព្វថ្ងៃដែលពីដើមជារបស់ជនជាតិជ្វីហ្វដែលជាអ្នកបង្កើតជនជាតិអ៊ីស្រាអែលនេះឡើង ហើយរបស់នៅទីនេះអស់កាលជាងរាប់សតវត្សរ៍មកហើយ ។ ពួកគេក៏បាននិយាយសង្កត់ធ្ងន់ទៅលើប្រជាជនអារ៉ាប់ ជាពិសេសពួកប៉ាឡេស្ទីនថាមិនមានបញ្ហាក់ទៅលើទឹកដីនេះទេ ។ បន្ថែមពីលើការសរសើរអំពីកិច្ចខំប្រឹងប្រែងរបស់ដូនតាជនជាតិជ្វីហ្វរបស់ពួកគេក្នុងការថែរក្សាទឹកដី សៀវភៅនេះក៏បាននិយាយរៀបរាប់អំពីភាពល្ងង់ខ្លៅរបស់ជនជាតិអារ៉ាប់ដែលមិនដឹងអី ថោកទាប ជឿទៅលើតែវាសនា ធ្វើអ្វីមិនចេះបានផល មិនយកចិត្តទុកដាក់ កខ្វល់ និងរញ៉េរញ៉ៃដែរ ។ ភាពអវិជ្ជមាននៃជនជាតិអារ៉ាប់ដែលត្រូវបានសរសេរឡើងក្នុងសៀវភៅនេះធ្វើឲ្យមានជម្លោះមួយដែលមិនអាចជា

ព្យាបាលបានរវាងជនជាតិទាំងពីរ ។

ដូចដែលបានពិភាក្សាតាំងពីដំបូងក្នុងឆ្នាំ១៩៥០ និង ឆ្នាំ១៩៦០ សហគមន៍ជនជាតិជ្វីហ្វដែលមាននៅគ្រប់ទីកន្លែងទាំងអស់ទូទាំងពិភពលោក បានផ្ដោតការយកចិត្តទុកដាក់តែបន្តិចបន្តួចប៉ុណ្ណោះទៅលើការអប់រំកូនរបស់ពួកគេទាក់ទងទៅនឹងការឈឺចាប់របស់ជនជាតិជ្វីហ្វក្នុងរបបហ្វូឡូខសត៍ ។ ប៉ុន្តែ សៀវភៅមេរៀនរបស់ពួកគេបែរជាផ្ដោតសំខាន់ទៅលើធាតុដើមនៃជនជាតិអ៊ីស្រាអែល និងទំនាស់រវាងអារ៉ាប់និងអ៊ីស្រាអែលដើម្បីប្រមូលនូវការយល់ឃើញរបស់សង្គមដែលថាជនជាតិអារ៉ាប់ជាសត្រូវនិងមនុស្សអាក្រក់ដែលមានបំណងចង់សម្លាប់ជនជាតិជ្វីហ្វបំផុតពូជដូចពួកណាហ្ស៊ីអ៊ីចឹងដែរ ។ អាស្រ័យហេតុនេះហើយ ពួកអារ៉ាប់ត្រូវបានដាក់ឈ្មោះថាជាចោរប្លន់ ឧក្រិដ្ឋជនដែលស្រេកឃ្លាន ឃាតករ ក្រុមចោរ ឬក្រុមបង្កចលាចល ។ គំនិតដូចគ្នានេះក៏អាចរកឃើញនៅក្នុងសៀវភៅមេរៀនរបស់កម្ពុជាផងដែរក្នុងឆ្នាំ១៩៨០ ដែលពិពណ៌នាអំពីការឈឺចាប់របស់ប្រជាជនក្រោមរបបខ្មែរក្រហម ហើយបានដាក់ឈ្មោះឲ្យខ្មែរក្រហមថាជាបិសាច ឬអសុរកាយ ។

យ៉ាងណាមិញ នៅក្នុងឆ្នាំ១៩៨០ និង១៩៩០ អ្នកបង្កើតកម្មវិធីសិក្សានៅក្នុងប្រទេសអ៊ីស្រាអែលបានបន្ថយចំនួនអត្ថបទក្នុងសៀវភៅរបស់ពួកគេដែលនិយាយពីទស្សនៈអវិជ្ជមាននៃជនជាតិអារ៉ាប់ ។ ដូចដែលកំណត់សម្គាល់របស់បារតាល់ថា ក្នុងអំឡុងពេលនេះពុំសូវមានការសង្កត់ធ្ងន់ទៅលើការបណ្ដុះគំនិតស្នេហាជាតិទាំងផ្ទាល់និងជាតិពន្ធនិយមនោះទេ ។ តែផ្ទុយមកវិញ កម្មវិធីសិក្សាត្រូវបានរចនាឡើងក្នុងគោលបំណងដើម្បីបង្កើតការរួបរួមគ្នារវាងជនជាតិជ្វីហ្វនិងអារ៉ាប់ ហើយដើម្បីកាត់បន្ថយការរើសអើងពួកអារ៉ាប់ ។ ពេលបច្ចុប្បន្ននេះ សៀវភៅមេរៀនដែលនិយាយអំពីរបបហ្វូឡូខសត៍នៅទូទាំងពិភពលោកគឺសុទ្ធតែមានលក្ខណៈខុសគ្នាទាំងអស់ ។ សៀវភៅទាំងអស់នេះលែងត្រូវបានបង្កើតឡើងដោយក្រសួងអប់រំតែម្នាក់ឯងទៀតហើយ ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើននិងសារមន្ទីរនៃរបបហ្វូឡូខសត៍ជាអ្នករចនាទាំងសៀវភៅនិងកម្មវិធីសិក្សាដែលត្រូវប្រើប្រាស់ទាំងក្នុងសាលារដ្ឋនិងឯកជន ។

ដូចគ្នានេះដែរ សៀវភៅមេរៀនក្នុងអំឡុងឆ្នាំ១៩៨០ បានក្លាយជាផ្នែកមួយនៃជម្លោះក្នុងស្រុករវាងបក្សនយោបាយកម្ពុជាក៏ដូចជាទំនាស់អន្តរជាតិរវាងប្រទេសមានអំណាចដែលទាក់ទងនឹងសង្គ្រាមត្រជាក់ ។ ដោយសារជំនួយរបស់វៀតណាមសាធារណរដ្ឋប្រជាមានិតកម្ពុជាមានបំណងចង់នាំយករបបកុម្មុយនីស្តមកកាន់ប្រទេសកម្ពុជា ដោយសង្ឃឹមថានឹងប្រែក្លាយប្រទេសសង្គមនិយមឲ្យដូចជាប្រទេសវៀតណាម ។ ម្យ៉ាងទៀតគឺក្នុងគោលបំណងការពារការវិលត្រឡប់មកវិញរបស់ខ្មែរក្រហមនិងបក្សកម្ពុជាដទៃទៀតដែលកំពុងបង្កើតកងកម្លាំងនៅតាមព្រំដែនខ្មែរ-ថៃ ។ ជាទូទៅ គោលបំណងសំខាន់បំផុតគឺលុបបំបាត់ទាំងស្រុងនូវអ្វីដែលពួកគេហៅថា «បនប្រល័យពូជសាសន៍ប៉ុលពត» ។ ជាមួយនឹងគោលបំណងទាំងអស់នេះ សៀវភៅមេរៀននេះត្រូវបានប្រើប្រាស់ដើម្បីបង្ហាញថ្នាក់រៀនតាំងពីបឋមសិក្សាអំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ សៀវភៅមេរៀននេះក៏បានសរសើរអំពីសកម្មភាពល្អរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ក្រុមខ្មែរក្រហមដែលរត់ចោលជួរចូលក្នុងប្រទេសវៀតណាមបានបង្កើតកងកម្លាំងនៅតាមបណ្ដោយព្រំដែនវៀតណាម ហើយបានរួបរួមជាមួយនឹងកងទ័ពវៀតណាមដើម្បីគ្រប់គ្រងប្រទេសកម្ពុជា ហើយបានបណ្ដេញខ្មែរក្រហមចេញពីអំណាចនៅក្នុងខែមករា ឆ្នាំ១៩៧៩ ។

ជាងនេះទៅទៀត សៀវភៅនេះបានបញ្ចូលសកម្មភាពរបស់វៀតណាមក្នុងការរំដោះប្រទេសកម្ពុជា និងជួយប្រជាជនកម្ពុជានៅគ្រប់តំបន់ ។ ពួកគេអំពាវនាវជាប្រចាំអំពីមិត្តភាពកម្ពុជា-វៀតណាម ហើយស្នើសុំឲ្យប្រជាជនក្មេងៗកម្ពុជាជ្រើសយកចលនាប្រឆាំងរបស់កម្ពុជា វៀតណាម និងឡាវជាគំរូក្នុងការប្រយុទ្ធជាមួយនឹងសត្រូវបនប្រតិកិរិយា ។ អត្ថបទដកស្រង់មួយចេញពីសៀវភៅមេរៀនដែលបោះពុម្ពនៅក្នុងឆ្នាំ១៩៨០ បានសរសេរថា ៖

ប្រជាជនយើងបានធ្វើការសម្រេចចិត្តដើម្បីជម្នះឧបសគ្គដែលនឹងមកដល់គ្រប់ប្រភេទទាំងអស់ ហើយរីករាយនឹងប្រយុទ្ធតទល់ដើម្បីការពារនិងបង្កើតប្រទេសសាជាថ្មី ។ ពួកគេជឿថាសង្គមនិយមដែលបរិសុទ្ធនិងត្រឹមត្រូវនឹងអាចពាំនាំមកនូវសន្តិភាព

និងលក្ខខណ្ឌរស់នៅដ៏ល្អ... ក្រោយពីថ្ងៃរំដោះ៧មករា ១៩៧៩ ប្រជាជនវៀតណាមជួយយើងដើម្បីស្តារប្រទេសឡើងវិញក្នុងគ្រប់ផ្នែកទាំងអស់។ ពួកយើងកំពុងតែព្យាយាមដើម្បីពង្រឹងនិងពង្រីកមិត្តភាពកម្ពុជា-វៀតណាម-ឡាវ ឲ្យកាន់តែរឹងមាំឡើងនិងជានិរន្តរ៍។ មិត្តវៀតណាមបានជួយគាំទ្រគ្រប់មធ្យោបាយទាំងអស់។ ប្រជាជនកម្ពុជា ជាពិសេសកសិករភាគច្រើននៅខេត្តស្វាយរៀងខ្វះខាតគោ ក្របី នង្គ័ល រនាស់ ។ល។ មិត្តវៀតណាមរបស់យើងបាននាំយកម៉ាស៊ីនភ្ជួរដើម្បីភ្ជួរស្រែឲ្យកសិករយើងអស់រយៈពេលបួនថ្ងៃ។ ពួកយើងទាំងសិស្សប្រុស សិស្សស្រីពិតជាស្រឡាញ់បងប្អូនវៀតណាមយើងណាស់ ដោយសារតែពួកគេបានជួយកម្ចាត់សត្រូវរបស់កម្ពុជា។

ពួកយើងយល់យ៉ាងច្បាស់ថា ក្រៅពីសង្គមនិយមវៀតណាមនៅមានប្រទេសសង្គមនិយមជាផ្សេងទៀតដូចជា ឡាវ និងសហភាពសូវៀតដែលបានគាំទ្រពួកយើងក្នុងគ្រប់ផ្នែកទាំងអស់។

សៀវភៅមេរៀននៅតាមសាលាក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺទទួលឥទ្ធិពលយ៉ាងខ្លាំងពីទស្សនៈរបស់វៀតណាម ដោយសារពួកគេត្រូវយកចិត្តទីប្រឹក្សាជនជាតិវៀតណាមដែលនឹងមិនទទួលយកពាក្យជៀមដាមទៅលើតួនាទីរបស់វៀតណាមនោះទេ។ ដូច្នេះហើយ អ្នកប្រវត្តិសាស្ត្ររបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវតែអនុវត្តក្នុងគម្រោងកំណត់។ សៀវភៅមេរៀនកម្ពុជានៅក្នុងឆ្នាំ១៩៨០ ក៏បានបង្ហាញពីការស្អប់ខ្ពើមចំពោះសត្រូវរបស់វៀតណាមដែលរួមមានទាំងសហរដ្ឋអាមេរិក ចិន និងបណ្តាប្រទេសជាមិត្តដទៃទៀតរបស់ពួកគេ។ ពួកគេបានដាក់ងារឲ្យសហរដ្ឋអាមេរិកថាជាពួកចក្រពត្តិនិយម ហើយប្រទេសចិនជាពួកវាគទីនិយមនិងពួកអនុត្តរភាពនិយមដែលជាអ្នកគាំទ្រខ្មែរក្រហមតាំងពីសម័យមុនបដិវត្តន៍រហូតដល់កិច្ចព្រមព្រៀងសន្តិភាពក្នុងឆ្នាំ១៩៩១។ តាមរយៈសៀវភៅមេរៀនសាធារណរដ្ឋប្រជាមានិតកម្ពុជាបានព្រមានប្រទេសចិនចំពោះការស្លាប់របស់ប្រជាជនកម្ពុជារាប់លាននាក់ និងការវិនាសហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេសស្ទើរតែទាំងស្រុង។

ថ្មីៗនេះ ប្រជាជនពួកយើងបានលុបបំបាត់ចោលរបបប្រល័យពូជសាសន៍ប៉ុល ពត, អៀង សារី និងមេដឹកនាំរបស់ពួកគេហើយ គឺពួកវាគទីនិយមប៉េកាំង។

នៅក្រោមទស្សនៈរបស់ពួកអនុត្តរភាពនិយមដ៏ធំធេងរបស់ប៉េកាំង កម្ពុជាប្រជាធិបតេយ្យបានក្លាយជាមូលដ្ឋានឈ្លានពាននិងជាជើងទ្រសម្រាប់ពួកវាធ្វើការវាយប្រហារប្រទេសជិតខាងនៅក្នុងអាស៊ីអាគ្នេយ៍។ អ្នកកាន់អំណាចនៅប៉េកាំងបានបញ្ជាប៉ុល ពត និងអៀង សារី ឲ្យធ្វើការឈ្លានពាននិងវាយប្រហារប្រឆាំងនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម។

ប្រជាជនទាំងអស់នៅក្នុងឥណ្ឌូចិនបានប្រឈមមុខនឹងការប្រយុទ្ធជាមួយពួកសត្រូវទាំងអស់គ្នា។ ពួកអាណានិគមបារាំង ចក្រពត្តិនិយមអាមេរិក និងពួកអ្នកវាគទីនិយមប៉េកាំង និងបាវបម្រើ ប៉ុល ពត និង អៀង សារី ដែលជាមេដឹកនាំអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។

នៅក្រោមរបបដឹកនាំរបស់ ប៉ុល ពត-អៀងសារី ប្រជាជនជាង៣លាននាក់ត្រូវបានស្លាប់ ហើយទ្រព្យសម្បត្តិទាំងអស់ត្រូវបានបំផ្លិចបំផ្លាញ។



សិស្សានុសិស្សធ្វើទស្សនកិច្ចនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

សន្តិសុខជាតិជាមូលដ្ឋានយ៉ាងសំខាន់ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ចាប់តាំងពីខ្មែរក្រហមនិងបក្សមិនមែនកុម្មុយនីស្តពីរក្រុមកំពុងតែប្រយុទ្ធគ្នាដើម្បីបណ្តេញកងទ័ពវៀតណាមចេញពីទឹកដីកម្ពុជា ។ យោងទៅតាមទស្សនៈដែលបានបង្ហាញនៅក្នុងអត្ថបទ សាធារណរដ្ឋប្រជាមានិតកម្ពុជាជឿជាក់យ៉ាងខ្លាំងក្លាថា សហរដ្ឋអាមេរិក ចិន និងបារាំងកំពុងតែមានបំណងចង់កាន់កាប់ប្រទេសកម្ពុជា ដោយប្រើប្រាស់ ប៉ុល ពត និងអតីតប្រធានាធិបតី លន់ នល់ ធ្វើជាកូនអុក ។ សៀវភៅមេរៀនថ្នាក់ទី៣បានបង្ហាញទស្សនៈអវិជ្ជមានដូចខាងក្រោម ៖

ពួកវាតទីនិយមនិងរាជាធិរាជនិយមប៉េកាំងបានអនុវត្តនូវគោលការណ៍អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ដោយបានជ្រើសរើសទាសករផ្តាច់ការរបស់ពួកគេគឺ ប៉ុល ពត-អៀង សារី ដើម្បីធ្វើជាឃាតករ ។ ពួកគេជឿជាក់ថាគេនឹងអាចបញ្ជូនទាហាននិងប្រជាជនចិនរាប់លាននាក់មករស់នៅក្នុងប្រទេសកម្ពុជាដើម្បីប្រែក្លាយកម្ពុជាទៅជាមូលដ្ឋានទ័ពមុខបម្រើប្រយោជន៍ឲ្យពួកវាតទីនិយមនៅអាស៊ីអាគ្នេយ៍ ។ នៅចុងឆ្នាំ ១៩៧៩ ប៉េកាំងបានធ្វើកិច្ចព្រមព្រៀងមួយជាមួយវ៉ាស៊ីនតោនក្នុងគោលបំណងបង្កើតចលនាផ្សេងមួយដើម្បីប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ពួកវាតទីនិយមប៉េកាំងនិងចក្រពត្តិនិយមអាមេរិកមានគម្រោងមួយដ៏ធំដើម្បីបញ្ជូនលន់ នល់ ដែលជាអាយ៉ងរបស់អាមេរិក ហើយនឹងកងទ័ពដែលស្មោះស្ម័គ្រនឹងលន់ នល់ ដើម្បីដឹកនាំចលនាបំផ្លាញសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ គោលនយោបាយរបស់ប៉េកាំងក្នុងការស្តារនូវរបបស្រេកឃ្លានផ្តាច់ការ ប៉ុល ពត-អៀង សារី និងមិនអាចសម្រេចឡើយ ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលទទួលបានការគាំទ្រពីបណ្តាប្រទេសសង្គមនិយមនឹងមិនធ្លាក់ចូលក្នុងអន្ទាក់របបរបស់ពួកបនប្រតិកិរិយា ពួកចក្រពត្តិនិយម និងពួកវាតទីនិយមឡើយ ។

ការអប់រំទៅលើរបបប្រល័យពូជសាសន៍កម្ពុជាមិនមានវត្តមានក្នុងអំឡុងឆ្នាំ១៩៩០នោះទេ ។ ដូចដែលបានពិពណ៌នាខាងលើថា នៅក្នុងឆ្នាំ២០០១ រដ្ឋាភិបាលកម្ពុជាបានបោះពុម្ព



សៀវភៅសិក្សាសង្គមថ្មីមួយដែលមាតិការបស់សៀវភៅល្អប្រសើរជាងសៀវភៅដែលបោះពុម្ពឡើងនៅឆ្នាំ១៩៨០ ។ អត្ថបទទាំងនេះមានបំណងចង់ធ្វើការផ្លាស់ប្តូររបៀបវារៈនៃការអប់រំថ្មីមួយនិងជំនឿរបស់សង្គម ។ យ៉ាងណាមិញ នៅមានកន្លែងជាច្រើនទៀតដែលមិនពុំមានព័ត៌មានគ្រប់គ្រាន់ ។ ចំពោះរបបខ្មែរក្រហមគឺពុំមានការលើកយកមកនិយាយពិភាក្សាច្រើននោះទេ ។

**ការពិពណ៌នា**

អំពីខ្មែរក្រហមនៅក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី៩ បានសរសេរថា ៖

ចាប់តាំងពីថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមបានបើកមហាសន្និបាតពិសេសមួយដើម្បីបង្កើតរដ្ឋធម្មនុញ្ញថ្មីនិងការកែប្រែឈ្មោះប្រទេសទៅជា «កម្ពុជាប្រជាធិបតេយ្យ» ។ រដ្ឋាភិបាលថ្មីមួយរបស់កម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយ ប៉ុល ពត បានកើតមានជារូបរាង ដែលក្រោយមកការសម្លាប់រង្គាលជនជាតិក៏ចាប់ផ្តើមកើតមានឡើងដែរ ។

មាតិកានេះមានអត្ថប្រយោជន៍ឬលទ្ធផលបន្តិចបន្តួចណាស់ក្នុងការបង្កើតនូវការយល់ដឹង ម្យ៉ាងទៀតធ្វើឲ្យពិបាកនឹងធ្វើការស្វែងយល់និងបង្កើតនូវគំនិតអំពីស្ថានភាពកាលពីអតីតសម្រាប់ពេលបច្ចុប្បន្ននិងអនាគត ។ ទោះបីជាមានតែបន្តិចក៏ដោយ អត្ថបទទាំងនេះបានបង្ហាញពីប្រវត្តិសាស្ត្រដែលមានលក្ខណៈត្រឹមត្រូវនិងមិនសូវមានភាពប្រទូសរាយជាជាងអត្ថបទដែលបង្ហាញពីមនោគមន៍វិជ្ជាក្នុងឆ្នាំ១៩៨០ទេ ។ ម្យ៉ាងវិញទៀត ទោះបីជាទាំងអស់នេះជាការកែប្រែតែបន្តិចក៏ពិតមែន តែវាមានសារសំខាន់ណាស់ ដោយសារតែនេះជាសញ្ញាមួយដែលរដ្ឋាភិបាលកម្ពុជាបានជ្រើសយកការបង្រៀនផ្សេងមួយទៀតដើម្បីអប់រំកូនចៅខ្មែរពីទុក្ខសោកកាលអតីតរបស់ប្រទេសខ្លួន ។

សៀវភៅមេរៀនទាំងក្នុងប្រទេសអ៊ីស្រាអែលនិងកម្ពុជាបានបង្ហាញថា មេដឹកនាំនៃប្រទេសទាំងពីរមានបំណងចង់បណ្តុះគំនិតនៃជំនឿសង្គមទៅដល់ប្រជាជនក្មេងៗតាមរយៈការបញ្ចុះបញ្ចូល ការឃោសនានយោបាយ និងកំហឹងចំពោះប្រទេសជាសត្រូវរបស់ខ្លួន ។ សៀវភៅមេរៀននៅក្នុងប្រទេសកម្ពុជាបានបង្ហាញពីរូបភាពវិជ្ជមាននៃអ្នកឈ្នះសង្គ្រាម ហើយបន្ទុចកិត្តិយសអ្នកដែលចាញ់ ។ រដ្ឋក៏បានប្រើប្រាស់ប្រវត្តិសាស្ត្រទំនើបរបស់ប្រទេសដើម្បីបង្ហាញទស្សនវិស័យរបស់រដ្ឋាភិបាលដែរ ។ ក្នុងរូបភាពអាកប្បកិរិយានិងជំនឿទាំងនេះបានដឹកបុសនៅក្នុងសង្គមកម្ពុជា ហើយនាពេលបច្ចុប្បន្ននេះក្លាយជាមជ្ឈដ្ឋានដ៏សាហាវមួយនៃទំនាស់អំពើហិង្សានិងការគាបសង្កត់ពីផ្នែកនយោបាយ ។ អាស្រ័យហេតុនេះហើយ ក្នុងការរៀបចំសៀវភៅមេរៀនអំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ និងទំនាស់ហិង្សា វាមានសារសំខាន់ណាស់ក្នុងការធានាថា សៀវភៅមេរៀនដែលប្រើប្រាស់នៅក្នុងសាលាមានតែការពិតប្រវត្តិសាស្ត្រនិងមិនមានជាប់ពាក់ព័ន្ធនឹងការឃោសនានយោបាយនោះទេ ។

ភាពត្រឹមត្រូវនិងមិនលម្អៀងនៃសៀវភៅមេរៀនតែម្យ៉ាងមិនអាចផ្តល់តម្លៃច្រើននោះទេបើគ្មានគុរកោសល្យនិងវិធីសាស្ត្រក្នុងការបង្រៀនដ៏មានប្រសិទ្ធភាព ដែលវាមានសារសំខាន់ណាស់ក្នុងការបញ្ជាក់អំពីតួនាទីដ៏សំខាន់នៃសៀវភៅណែនាំរបស់សិស្សនិងគ្រូ និងការហ្វឹកហ្វឺនគ្រូ ដូច្នេះគ្រូនឹងអាចបង្រៀនប្រវត្តិសាស្ត្រអំពើប្រល័យពូជសាសន៍តាមទិសដៅច្បាស់លាស់ ។ ក្នុងការបង្កើតសៀវភៅណែនាំរបស់គ្រូនិងសិស្ស ការសង្កត់ធ្ងន់ទៅលើទំនាក់ទំនងរវាងការអប់រំអំពើប្រល័យពូជសាសន៍និងជីវិត ការអប់រំអំពើប្រល័យពូជសាសន៍និងយុត្តិធម៌សង្គម ការអប់រំអំពើប្រល័យពូជសាសន៍និងការកែប្រែជំនឿសង្គមដែលអវិជ្ជមានព្រមទាំងតួនាទីរបស់ការអប់រំអំពើប្រល័យពូជសាសន៍ក្នុងការបង្រួបបង្រួមជាតិ គឺមានសារសំខាន់ណាស់ ។ ក្នុងការដាក់អំណះអំណាងនេះជាទម្រង់សំណួរមួយ គឺយើងអាចសួរបានថា ៖ តើអ្វីខ្លះដែលការអប់រំអំពើប្រល័យពូជសាសន៍អាចចូលជាបច្ច័យក្នុងការទាមទាររកយុត្តិធម៌ ការចងចាំ ការផ្លាស់ប្តូរសង្គម ការផ្សះផ្សាជាតិនិងការការពារមិនឲ្យមានអំពើប្រល័យពូជសាសន៍កើតឡើងបាន? សំណួរនេះនឹងធ្វើការពិភាក្សាយ៉ាងលម្អិតនៅខាងក្រោមនេះ ។ នៅទីនេះ ខ្ញុំនឹងដាក់ឈ្មោះឲ្យការចូលរួមនេះជា «ការអប់រំអំពើប្រល័យពូជសាសន៍សកម្មនិយម» ដោយសារតែវាបានផ្តល់នូវឱកាសដល់ប្រជាជនបច្ចុប្បន្នចូលរួមយ៉ាងសកម្មក្នុងដំណើរការនៃការបោះជំហានទៅមុខឆ្ពោះទៅរកសង្គមយុត្តិធម៌មួយ ។ ម្យ៉ាងវិញទៀត ជាមួយនឹងការបង្កើតថ្មីនៃវិធីសាស្ត្រ ការអប់រំអំពើ

ប្រល័យពូជសាសន៍អាចផ្តល់ឱកាសដើម្បីបង្កើនការអត់ធ្មត់ ការរួមបញ្ចូលនិងសមត្ថភាពក្នុងការដោះស្រាយជាមួយនឹងទំនាស់ដោយប្រើអហិង្សា និងសមត្ថភាពក្នុងការគិតឲ្យបានកាន់តែជិតដល់ និងចោទសួរទៅលើការសន្មត់ទាំងឡាយណាដែលអាចត្រូវបានរៀបចំឡើងម្តងទៀតដើម្បីបង្កជម្លោះឲ្យកើតឡើង ។

កម្មវិធីសិក្សាលើការអប់រំអំពើប្រល័យពូជសាសន៍គួរតែរចនាឡើងក្នុងមធ្យោបាយមួយដែលផ្តល់ឱកាសឲ្យកូនសិស្សក្នុងការតាមដានពីព្រឹត្តិការណ៍សំខាន់ដែលនាំទៅរកអំពើប្រល័យពូជសាសន៍ក្នុងទម្រង់កាលប្បវត្តិ ។ ទាំងនេះធ្វើឲ្យសិស្សចេះកត់សម្គាល់ វិភាគ វាយតម្លៃ និងអង្កេតពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងអធិប្បាយ ។ អត្ថបទដែលសរសេរបានល្អនឹងអាចធ្វើឲ្យសិស្សចេះគិតបានល្អិតល្អន់ ចេះជជែក ពិភាក្សាអំពីគំនិតក្នុងថ្នាក់រៀន និងបង្កើតនូវសុភនិច្ឆ័យផ្ទាល់ខ្លួនដោយឯករាជ្យ ។ម្យ៉ាងវិញទៀត នៅក្នុងប្រទេសកម្ពុជា ជាមួយនឹងយុទ្ធសាស្ត្រគរុកោសល្យប្រកបដោយគុណភាពធ្វើឲ្យសិស្សអាចប្រែក្លាយខ្លួនឯងពីអ្នករៀនដែលអសកម្មឲ្យទៅជាសកម្ម ។ ដើម្បីសម្រេចបាននូវគោលដៅនេះ សិស្សត្រូវការកម្មវិធីសិក្សាដែលទាក់ទងនឹងស្ថានភាពនិងជីវិតរស់នៅពេលបច្ចុប្បន្ន ដែលអាចដឹកនាំពួកគេទៅរកបទពិសោធន៍របស់ពិតពិតៗ និងធ្វើឲ្យពួកគេអាចចូលរួមជាក្នុងការស្តារសង្គមជាតិឡើងវិញ ។ ដូចការអះអាងរបស់លោក អាលីសាន់ គីតសុន ដែលថាជោគជ័យដ៏សំខាន់ប្រហែលជាត្រូវពឹងផ្អែកលើសមត្ថភាពរបស់គ្រូដើម្បីបង្រៀនមេរៀនដែលជាក់លាក់មួយពីអតីតកាលក្នុងគោលបំណងដើម្បីបំភ្លឺពីបច្ចុប្បន្នកាល ហើយថែមទាំងបង្ហាញយ៉ាងល្អិតល្អន់អំពីអាកប្បកិរិយានាពេលបច្ចុប្បន្នគ្រប់បែបយ៉ាងដែលរារាំងជម្លោះ ។

## ការវិភាគប្រៀបធៀប

ក្នុងប្រវត្តិសាស្ត្ររបបហ្វូឡូខសត៍និងអំពើប្រល័យពូជសាសន៍កម្ពុជាគឺមានលក្ខណៈស្រដៀងគ្នា ដោយសារតែមានការសម្លាប់ជីវិតមនុស្ស ។ ប៉ុន្តែ ក្នុងដំណើរការនៃប្រវត្តិសាស្ត្ររបស់ពួកគេទាំងនោះគឺខុសគ្នាដាច់ស្រឡះ ។ ការសិក្សាអំពីរបបហ្វូឡូខសត៍ គឺបានបង្កើតឡើងដំបូងដោយមិនមានបំណងចង់ពង្រីកឲ្យទៅជាសំណេរដ៏ច្រើនអណែកឬអាហារូបករណ៍លើប្រធានបទនេះ ឬការផ្សព្វផ្សាយតាមវិទ្យុ ខ្សែភាពយន្ត និងការសិក្សាតាមអ៊ីនធឺណេតនោះទេ ។ តាមការពិត មានអ្នកសិក្សាខ្លះបានអះអាងថា របបហ្វូឡូខសត៍ទទួលបានការចាប់អារម្មណ៍មិនស្មើគ្នានោះទេបើប្រៀបធៀបទៅនឹងអំពើប្រល័យពូជសាសន៍ដទៃទៀតក្នុងពេលបច្ចុប្បន្ននេះ ។ សហគមន៍ជ្វីហ្វខ្លួនឯងនោះក៏បានធ្វើការយ៉ាងសកម្មដើម្បីផ្សព្វផ្សាយ និងជំនួយជាថវិកាទៅលើសកម្មភាពផ្សេងៗដែលបង្កើតឡើងដើម្បីបណ្តុះការយល់ដឹងអំពីផ្នែកផ្សេងៗនៃរបបហ្វូឡូខសត៍នេះ មានដូចជា ការឧបត្ថម្ភគាំទ្ររបស់អង្គការ និងស្ថានប័នដើម្បីរៀបចំសិក្ខាសាលាផ្សេងៗ ។

ផ្ទុយពីការបង្កើតឡើងនៃការបង្រៀនពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា កាលពីដំបូងប្រព័ន្ធសិក្សាអប់រំនៅកម្ពុជាគឺផ្តោតការចាប់អារម្មណ៍ទៅលើអំពើប្រល័យពូជសាសន៍ជាច្រើនជំពូកជាប់គ្នាដែលមានលក្ខណៈនយោបាយខ្លាំងនិងជាការឃោសនាសុទ្ធសាធ ។ បន្ទាប់មកទៀត ការពណ៌នាពីកម្ពុជាប្រជាធិបតេយ្យត្រូវបានកាត់បន្ថយត្រឹមតែ៩បន្ទាត់តែប៉ុណ្ណោះ ។ ចុងបញ្ចប់អត្ថបទដែលនិយាយពីអំពើប្រល័យពូជសាសន៍ត្រូវលុបចេញពីសៀវភៅមេរៀននិងកម្មវិធីសិក្សាទាំងស្រុង ។

ក្នុងរយៈពេលជាង៣ទសវត្សរ៍ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម ប្រជាជនកម្ពុជាភាគច្រើនបានធ្វើការពុះពារដើម្បីរស់នៅក្នុងប្រទេសដែលត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមស៊ីវិល ជម្លោះផ្ទៃក្នុង អស្ថិរភាពផ្នែកនយោបាយ និងអសន្តិសុខជាតិ ។ ប្រជាជនពុំសូវយកចិត្តទុកដាក់ទៅលើការឈឺចាប់របស់ពួកគេពីមុននោះទេ ។ ដោយសារតែការកកើតឡើងនៃតុលាការខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងការបោះពុម្ព ក៏ដូចជាការរួមចំណែកទូទាំងប្រទេសនៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទើបធ្វើឲ្យប្រជាជនចាប់ផ្តើមធ្វើការពិភាក្សាជាមួយអ្នកជិតខាងនិងគ្រួសាររបស់ពួកគេអំពីអតីតកាល ។

លោក ដីអូប្រេយ ហ្សូត បានលើកឡើងពីបញ្ហាសំខាន់ៗជាច្រើនក្នុងការបង្រៀនអំពីរបបហ្វូឡូខសត៍ ។ ការវិវឌ្ឍដ៏អន់ថយរបស់សៀវភៅមេរៀន កម្មវិធីសិក្សានិងប្រភពបន្ទាប់បន្សំផ្សេងៗសម្រាប់ការបង្រៀនគឺអាចដឹកនាំសិស្សឲ្យចេះពិនិត្យមើលការអប់រំ

ពីអំពើប្រល័យពូជសាសន៍ក្នុងមធ្យោបាយមួយដែលមានលក្ខណៈខុសពីវត្ថុបំណងដំបូងរបស់អ្នកអប់រំ ។ ក្នុងន័យនេះ ការសិក្សាឲ្យបានល្អិតល្អន់អំពីគុណភាពនៃការអប់រំពីអំពើប្រល័យពូជសាសន៍ដែលផ្តល់ជូនសិស្សវិទ្យាល័យនិងសកលវិទ្យាល័យគឺមានសារសំខាន់ខ្លាំងណាស់ ។ ការសិក្សាស្រាវជ្រាវមួយនៃការវិវឌ្ឍរបស់អត្ថបទអំពីរបបហ្វូឡូខសត៍ដែលផ្តល់ជូនដល់សិស្សវិទ្យាល័យក្នុងប្រទេសអង់គ្លេសនៅពាក់កណ្តាលឆ្នាំ១៩៩០ បានបង្ហាញថា គ្រូបង្រៀនភាគច្រើនមិនបានបង្ហាត់បង្ហាញប្រវត្តិរបបហ្វូឡូខសត៍នៅក្នុងថ្នាក់រៀនតាមគោលដៅនោះទេ ។

នៅពេលដែលទស្សនៈតែម្ខាងត្រូវបានបង្រៀនដល់សិស្ស ឬក៏គ្រូមិនបាននិយាយរៀបរាប់ព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយ នោះសិស្សនឹងអាចមានទស្សនៈលម្អៀងអំពីជនរងគ្រោះពីរបបប្រល័យពូជសាសន៍ ។ ចំពោះអំណះអំណាងដែលបញ្ឈរក់ពីទស្សនៈលម្អៀងតែម្ខាងអំពីប្រវត្តិសាស្ត្រជីហ្វ ។ ជាងនេះទៅទៀតសិស្សខ្លះអាចធ្វើការសន្និដ្ឋានថា បើគ្មានភ្លើងគឺគ្មានផ្សែងនោះទេ ហើយមួយចំនួនទៀត អាចនឹងធ្វើការសន្មតថាជនជាតិជីហ្វគឺជាអ្នកនិពន្ធនៃប្រវត្តិអភ័ព្វរបស់ខ្លួនឯង ។

ចំពោះទស្សនៈដែលលោក ហ្សេត បានធ្វើការអង្កេតមើល នោះជាបញ្ហាសំខាន់មួយដែលកើតមាននៅក្នុងប្រទេសកម្ពុជាតាំងពីការដួលរលំនៃរបបខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៩ ។ ចំពោះរដ្ឋាភិបាលរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើការស្តីបន្ទោសដល់របបអំពើប្រល័យពូជសាសន៍កម្ពុជារបស់ពួកខ្មែរក្រហម សម្ព័ន្ធមិត្តរបស់ពួកវា និងពួកអ្នកមានអំណាចធំៗដូចជាសហរដ្ឋអាមេរិក និងចិន ។ ផ្ទុយមកវិញ ខ្មែរក្រហមជឿជាក់ថាឃាតករដែលលេចមុខឡើងនៅអំឡុងឆ្នាំ១៩៧៥-១៩៧៩ គឺជាជនជាតិវៀតណាមច្បាស់ណាស់ ព្រោះពួកគេមានបំណងកម្ទេចចោលប្រជាជន ដើម្បីកាន់កាប់ទឹកដីកម្ពុជាទាំងមូល ។ សូម្បីតែសព្វថ្ងៃនេះ សមាជិកជាច្រើននៃសហគមន៍កម្ពុជាក្រៅប្រទេស និងប្រជាជនដែលរស់នៅក្នុងប្រទេសគឺនៅតែមានការជឿជាក់ថារបបប្រល័យពូជសាសន៍កម្ពុជាអាចនិយាយបានថា មកពីជនជាតិវៀតណាមតែម្តង ។

ដោយសារភ័ស្តុតាងនៃការយល់ឃើញខុសឆ្គងនេះហើយ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ មានជនជាតិកម្ពុជាមួយក្រុមនៅក្នុងប្រទេសបារាំងបានធ្វើការប្រកាសថា ពួកគេកំពុងតែធ្វើការស្តារឡើងវិញនូវរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក្នុងគោលបំណងជួយសង្គ្រោះប្រជាជនកម្ពុជា ក៏ដូចជាប្រទេសកម្ពុជាចេញពីប្រទេសវៀតណាម ។ សេចក្តីថ្លែងការណ៍នៃអត្ថបទបកប្រែមិនលក្ខណៈផ្លូវការមួយដែលពួកគេបានចុះផ្សាយនោះមានដូចខាងក្រោមៈ

ខ្ញុំចង់ប្រកាសប្រាប់ជូនប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈទាំងអស់ឲ្យបានជ្រួតជ្រាបថា ខ្ញុំមានបំណងចង់ធ្វើការស្តារនូវរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឡើងវិញ ដែលទស្សនទូទៅបានយល់ច្រឡំថាដោយសារតែរដ្ឋាភិបាលនេះហើយដែលបានអនុវត្តនូវរបបប្រល័យពូជសាសន៍ ហើយជនជាតិវៀតណាមជាអ្នកកម្ចាត់ចោលនូវរបបនេះនៅក្នុងថ្ងៃទី៧ មករា ១៩៧៩ ។ មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យគឺសុទ្ធតែជាមនុស្សស្អាតស្អំ ។ ពួកគេជាជនស្នេហាជាតិពិតប្រាកដ ហើយបានរំដោះប្រជាជនខ្មែរចេញពីការគ្រប់គ្រងរបស់វៀតណាម ។ ប៉ុន្តែ ពួកបរទេសបានលេងល្បិចដោយចង់បង្កើតជាតុលាការអន្តរជាតិដើម្បីធ្វើការកាត់ទោសមេដឹកនាំទាំងអស់នេះ ។ កម្ពុជាប្រជាធិបតេយ្យត្រូវតែឈ្នះអង្គការសហប្រជាជាតិ ត្រូវតែស្វែងរកការពិត ទោះបីជាទស្សនៈជាសកលនៅតែមានការយល់ច្រឡំយ៉ាងណាក្តី ។ ពួកយើងមិនគួរទុកឲ្យអ្នកដែលមិនដឹងការពិតបន្តបម្រើជាទាសកររបស់វៀតណាម និងបន្តសម្លាប់ខ្មែរទៀតនោះទេ ។ អង្គការសហប្រជាជាតិត្រូវតែរកយុត្តិធម៌ឲ្យកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវតែស្វែងរកឲ្យឃើញថា ក្រុមណាមួយដែលសម្លាប់ប្រជាជនកម្ពុជាជាង២លាននាក់ ច្បាស់ណាស់កាលនោះគឺអង្គការធំដែលរៀបចំឡើងដោយវៀតណាមបានកាន់កាប់ភ្នំពេញនិងគ្រប់ខេត្តទាំងអស់ ។ កម្ពុជាប្រជាធិបតេយ្យមិនមែនជាមនុស្សតែម្នាក់ដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ ។

ជាង៤០ឆ្នាំមកហើយ ប្រជាជនកម្ពុជាពុំអាចមានលទ្ធភាពធ្វើការសម្រេចចិត្តឲ្យបានច្បាស់លាស់ថាតើមានអ្វីកើតឡើងខ្លះក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ សំណួរដដែលៗនៅតែដិតជាប់ក្នុងអារម្មណ៍របស់ពួកគាត់ជាច្រើនឆ្នាំហើយ ។ សំណួរទាំងអស់នោះរួមមានៈ ហេតុអ្វីបានជាប្រជាជនកម្ពុជាសម្លាប់ប្រជាជនខ្លួនឯង?

តើប្រទេសវៀតណាម និងចិនមានបំណងចង់លេបយកប្រទេសកម្ពុជា ដោយធ្វើការកម្ចាត់ចោលប្រជាជនកម្ពុជាទាំងអស់ឬយ៉ាងណា?

រឿងរ៉ាវប្រវត្តិសាស្ត្រនៃរបបហ្វូឡូខសត៍ក៏មានការបំភ្លេចចោលដែរ ។ ដូចដែលលោក ជីអូហ្វ្រេយ ហ្សុត បានធ្វើការអង្កេតថា អត្ថបទនិយាយអំពីរបបហ្វូឡូខសត៍ដែលត្រូវបានប្រើសម្រាប់បង្រៀនសិស្សនៅប្រទេសអង់គ្លេស កាណាដា និងសហរដ្ឋអាមេរិក គឺមិនបាននិយាយអំពីតួនាទីរបស់ព្រះវិហារនៅក្នុងការរើសអើងជនជាតិជីហ្វនោះទេ ។ យោងទៅតាមការសិក្សាស្រាវជ្រាវនៃគ្រូប្រវត្តិសាស្ត្រជាង២៣នាក់នៅក្នុងទីក្រុង តូរ៉ុនតូ នៅក្នុងខែឧសភា ឆ្នាំ១៩៩៨ គ្រូជាងពាក់កណ្តាលនិយាយតែបន្តិចបន្តួចប៉ុណ្ណោះអំពីតួនាទីនៃការរើសអើងជនជាតិជីហ្វ ហើយអ្នកដែលនៅសល់គឺមិនបាននិយាយអ្វីទាំងអស់នៅក្នុងថ្នាក់រៀនរបស់ពួកគេ ។ ចំពោះគ្រូខ្លះនៅអាមេរិកខាងជើងនិងអឺរ៉ុបគឺហាក់ដូចជាពុំសូវមានការចាប់អារម្មណ៍នឹងជនជាតិជីហ្វនៅពេលបង្រៀនពីគ្រូរបស់ពួកគេ ។ ដូចអ្វីដែលលោក ហ្សុត បាននិយាយថា ពួកគេជាធម្មតាតែងតែចំណាយពេលច្រើននិយាយពីភាពអាក្រក់យង់ឃ្នងរបស់អំណាចពួកអឺរ៉ុប ទង្វើដែលធ្វើមកលើជនរងគ្រោះមិនមែនជីហ្វ និងភាពដូចគ្នានិងខុសគ្នារវាងរបបហ្វូឡូខសត៍និងអំពើប្រល័យពូជសាសន៍ថ្មីៗដទៃទៀត ។ ចំណែកឯអ្នកដែលបង្កើតកម្មវិធីសិក្សាទាំងអស់នោះវិញមិនចង់ធ្វើការលាតត្រដាងពីដើមកំណើតគ្រីស្ទាននៃការរើសអើងជនជាតិជីហ្វ ដែលមាននិន្នាការធ្វើការបញ្ជាក់ថាការរើសអើងជនជាតិជីហ្វមិនមានមុនសម័យហ៊ីតឡឺនោះទេ ។

ដូចគ្នានេះដែរ ដោយសារតែការរងទុក្ខពីការធ្វើទុក្ខបុកម្នេញក្នុងរបបខ្មែរក្រហម និងកម្មវិធីសិក្សា និងការហ៊ឹកហ៊ឺនដោយមិនមានលក្ខណៈជាគរុកោសល្យច្បាស់លាស់ នោះបានធ្វើឲ្យគ្រូមួយចំនួនធ្វើការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមដល់កូនសិស្សទៅតាមតែអារម្មណ៍របស់ពួកគាត់ ។ ទាំងនេះដែលជំនួសឲ្យការបង្កើតការត្រិះរិះពិចារណានិងការយល់ដឹងអំពីការអាណិតអាសូរនិងការរួបរួមជាតិ តែបែរជាអាចបណ្តុះនូវអារម្មណ៍ស្អប់ខ្ពើមនិងសងសឹកចំពោះសិស្សទៅវិញ ។ ដោយសារតែការគាបសង្កត់ផ្នែកនយោបាយធ្វើឲ្យគ្រូមួយចំនួនមិនហ៊ានធ្វើការពិភាក្សាពីទំនាក់ទំនងរវាងមន្ត្រីរដ្ឋាភិបាលបច្ចុប្បន្ននិងខ្មែរក្រហមនោះទេ ។ ទាំងនេះអាចធ្វើឲ្យមានចន្លោះប្រហោងក្នុងប្រវត្តិសាស្ត្រ ។ នៅពេលដែលធ្វើការបង្កើតកម្មវិធីសិក្សាពីការអប់រំអំពើប្រល័យពូជសាសន៍គឺមានសារសំខាន់ណាស់ក្នុងការត្រួតពិនិត្យមិនឲ្យមានអារម្មណ៍ផ្ទាល់ខ្លួនជ្រៀតចូល ជាពិសេសត្រូវរក្សានូវអព្យាក្រឹត្យភាពផ្នែកនយោបាយទៀតផង ។ បើមិនអ៊ីចឹងទេ គ្រូនឹងធ្វើការបង្រៀនទៅតាមរបៀបរបស់គាត់ ដែលនឹងអាចផ្តល់នូវការបកស្រាយអំពីប្រវត្តិនៃអំពើប្រល័យពូជសាសន៍ដោយលម្អៀងទៅខាងណាមួយជាក់ជាមិនខាន ។

នៅសហរដ្ឋអាមេរិក ការបង្កើតកម្មវិធីសិក្សាពីរបបហ្វូឡូខសត៍គឺបានក្លាយទៅជារឿងមួយដែលគួរព្រួយបារម្ភ ដោយសារតែការយល់ខុសមួយដែលស្ថិតនៅយូរមកហើយ ។ ការសិក្សាមួយដែលធ្វើឡើងនៅក្នុងឆ្នាំ១៩៩០ បានបង្ហាញថា កម្មវិធីសិក្សានៅកាលីហ្វញ៉ាបានផ្តល់នូវការចាប់អារម្មណ៍ថា «ទិសដៅដំបូងបំផុតរបស់ហ៊ីតឡឺ គឺពួកស្បែកខ្មៅជាជាងពួកជីហ្វ» ។ រីឯកម្មវិធីសិក្សានៅក្នុងរដ្ឋមួយទៀតវិញក៏បានយល់ខុសដែរអំពីតួនាទីរបស់សហរដ្ឋអាមេរិកក្នុងដំណើរការជួយសង្គ្រោះជនជាតិជីហ្វ ។ ចំពោះស្ថានភាពដដែលនេះក៏មានស្ថិតនៅក្នុងកម្មវិធីសិក្សានៅប្រទេសកម្ពុជាផងដែរ ក្នុងសម័យរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមានបំណងធ្វើការបណ្តុះឲ្យកូនសិស្សមានគំនិតសង្គមនិយមនិងប្រឆាំងខ្មែរក្រហម ។ ការយល់ខុសនេះត្រូវបានរៀបចំដាក់បញ្ចូលក្នុងកម្មវិធីសិក្សាដោយចេតនាក្នុងគោលបំណងធ្វើការបណ្តុះផ្នត់គំនិតរបស់សិស្សចំពោះខ្មែរក្រហមនិងកងកម្លាំងវៀតណាមនៅក្នុងប្រទេសកម្ពុជា ។ ម្យ៉ាងវិញទៀតគឺក្នុងគោលបំណងដើម្បីបង្កើនការគាំទ្រចំពោះរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងជាពិសេសដើម្បីបង្កើននូវការបកស្រាយជាលក្ខណៈប្រវត្តិសាស្ត្រដែលបម្រើឲ្យអត្ថប្រយោជន៍នយោបាយរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ ។

នាពេលបច្ចុប្បន្ននេះ ការសិក្សាអំពីរបបហ្វូឡូខសត៍គឺជាមុខវិជ្ជាមួយដែលតម្រូវឲ្យមានការសិក្សាជាចាំបាច់នៅក្នុងថ្នាក់វិទ្យាល័យនិងមហាវិទ្យាល័យជាច្រើននៅសហរដ្ឋអាមេរិក ។ ទំហំនិងចំនួននៃអត្ថបទដែលត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីនោះក៏ជា

ការលំបាកមួយទៀតដែរ ។ នៅក្នុងករណីខ្លះទៀត គ្រូប្រវត្តិសាស្ត្រនៅវិទ្យាល័យសហរដ្ឋអាមេរិកមិនអាចចៀសផុតក្នុងការមិនលើកយកប្រធានបទមួយចំនួនមកធ្វើការពិភាក្សា ។ ប្រទេសកម្ពុជាក៏ជួបការលំបាកក្នុងការកំណត់ពីចំនួនដែលត្រូវដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់ខ្លួនដែរ ។ គណៈកម្មាធិការរៀបចំកែលម្អឯកសារនៃរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានបង្កើតឡើងក្រោមក្រឹត្យច្បាប់របស់រដ្ឋាភិបាល ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញនូវសំណៅដើមនៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យក៏បានត្អូញត្អែរអំពីប្រវែងនៃអត្ថបទដែលគិតជាភាសាអង់គ្លេសជិតមួយរយទំព័រ ។ លោក ស៊ិន សំណាង បានឲ្យយោបល់ថា ក្រសួងអប់រំរបស់ប្រទេសកម្ពុជាគួរតែធ្វើការពិចារណាអំពីតុល្យភាពមួយដ៏សមរម្យរវាងម៉ោងសិក្សា ចំនួនទំព័រ ចំនួនជំពូក និងចំនួនមេរៀនប្រវត្តិសាស្ត្របើប្រៀបធៀបទៅនឹងមុខវិជ្ជានិងមេរៀនដទៃទៀត ។

យ៉ាងណាមិញ ដូចដែលបានបញ្ជាក់កាលពីដើមអីចឹងថា នៅក្នុងប្រទេសកម្ពុជា ក្រសួងអប់រំទើបតែធ្វើការយល់ព្រមលើសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យធ្វើជាផ្នែកមួយនៃកម្មវិធីសិក្សារបស់ខ្លួនក្នុងថ្នាក់អនុវិទ្យាល័យទូទាំងប្រទេស ហើយសៀវភៅនេះគឺជាប្រភពតែមួយគត់នៃការអប់រំពីអំពើប្រល័យពូជសាសន៍សម្រាប់ថ្នាក់វិទ្យាល័យ ។ សង្ឃឹមថាទៅថ្ងៃអនាគតអ្នកអប់រំនឹងអាចមានសម្ភារៈគ្រប់គ្រាន់ផ្សេងៗគ្នាស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលធ្វើឲ្យពួកគេអាចចាប់ផ្តើមអភិវឌ្ឍវិធីសាស្ត្រគរុកោសល្យដ៏មានប្រសិទ្ធភាពសម្រាប់ធ្វើការណែនាំ ដល់កូនសិស្ស ។ ដូចដែល ហ្គលឡេន និង ហាតម៉ែន បានអះអាងថា ការប្រៀបធៀបដ៏ប្រយ័ត្នប្រយែងនៃយុទ្ធសាស្ត្រផ្សេងៗគ្នាអាចជួយឲ្យអ្នកអប់រំមានជម្រើសផ្សេងៗជាច្រើនសម្រាប់កម្មវិធីផ្ទាល់ខ្លួនរបស់ពួកគេនិងស្ថានភាពបង្រៀន ដូច្នេះគឺអាចធានាបាននូវការប្រើប្រាស់ធនធានដែលប្រកបដោយប្រសិទ្ធភាពសម្រាប់សមិទ្ធិផលនៃគោលដៅដ៏សមរម្យនិងមានសារសំខាន់ ។

សារមន្ទីរក៏មានតួនាទីមួយដ៏សំខាន់ក្នុងការបំពេញបន្ថែមនូវការអនុវត្តការអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងសាលា ។ អ្នកសិក្សាពីរបបហ្វូឡូខសត៍និងអ្នកអប់រំបានរួមបញ្ចូលសារមន្ទីរទៅក្នុងកម្មវិធីសិក្សារបស់ពួកគេដោយមានប្រសិទ្ធភាព ។ ការទស្សនាសារមន្ទីរមិនត្រឹមតែអាចសន្សំពេលវេលាទេ ហើយថែមទាំងធ្វើឲ្យអ្នកទស្សនាទទួលបាននូវបទពិសោធន៍ដែលប្រកបដោយអត្ថន័យនិងផ្ទាល់ភ្នែកទៀតផងចំពោះរបបហ្វូឡូខសត៍ ។ ក្រៅពីអប់រំកូនសិស្ស សារមន្ទីរក៏មានតួនាទីជាមជ្ឈមណ្ឌលមួយសម្រាប់អប់រំសាធារណជនអំពីរបបហ្វូឡូខសត៍ ។ គ្រប់សារមន្ទីរនៃរបបហ្វូឡូខសត៍ទាំងអស់នៅអាមេរិកខាងជើង អ៊ីស្រាអែល និងអឺរ៉ុបគឺមានដាក់តាំងពិព័រណ៍រូបថត កុននិងវត្ថុបុរាណផ្សេងៗ ។ អាស្រ័យហេតុនេះហើយសារមន្ទីរអាចផ្តល់នូវព័ត៌មានលម្អិតបានយ៉ាងរហ័សជាជាងអ្វីដែលមាននៅក្នុងកម្មវិធីសិក្សា ។ ប្រធានបទដែលពួកគេបានលើកឡើងគឺតាំងពីជីវិត និងភាពស៊ីវិល័យរបស់ជនជាតិជ្វីហ្វនៅអឺរ៉ុបមុនសម័យហ្វូឡូខសត៍រហូតដល់ប្រវត្តិនៃការរើសអើងជនជាតិជ្វីហ្វ ការកកើតមានឡើងនូវគណបក្សណាហ្ស៊ីនៅប្រទេសអាល្លឺម៉ង់ ការអនុវត្តនូវរបបហ្វូឡូខសត៍ និងការប្រឆាំងតបតរបស់ជនជាតិជ្វីហ្វ ។ សារមន្ទីរហ្វូឡូខសត៍ក៏មានធ្វើការតាំងពិព័រណ៍ពីជោគវាសនារបស់ជនរងគ្រោះមិនមែនជ្វីហ្វ ការបង្កើតឡើងនៃរដ្ឋអ៊ីស្រាអែល និងបទពិសោធន៍របស់ជនជាតិជ្វីហ្វក្រោយសង្គ្រាមនៅសហរដ្ឋអាមេរិកដែរ ។

មេរៀនដដែលនេះក៏បានអនុវត្តនៅក្នុងករណីនៃការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាផងដែរ ពីព្រោះថា សៀវភៅមេរៀនតែម្យ៉ាងមិនអាចផ្តល់នូវការយល់ដឹងពីរបបខ្មែរក្រហមឲ្យបានពេញលេញគ្រប់គ្រាន់នោះទេ ។ ការបញ្ជូនសិស្សទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ វាលពិឃាដ អតីតមន្ទីរសន្តិបាលនិងរណ្តៅសាកសពធំៗ គឺអាចធ្វើឲ្យសិស្សយល់ដឹងកាន់តែច្រើនពីជីវិតពិតៗរបស់ប្រជាជននាសម័យខ្មែរក្រហមដែលកត្តាជំរុញឲ្យខ្មែរក្រហមឡើងកាន់អំណាចបាននិងលទ្ធផលនៃអំពើប្រល័យពូជសាសន៍ ។ ក្រោយពីបានទៅទស្សនាសារមន្ទីរ ទួលស្លែង សិស្សអាចមានមតិច្រើនក្នុងការពិភាក្សានៅក្នុងថ្នាក់នូវអ្វីដែលពួកគេបានឃើញបន្ថែមទៅលើអ្វីគេបានរៀន ។ ក្នុងន័យនេះផងដែរ សារមន្ទីរទួលស្លែងនឹងដើរតួយ៉ាងសំខាន់ដែលដូចគ្នាទៅនឹងបូជនីយដ្ឋាននៃរបបហ្វូឡូខសត៍នៅសហរដ្ឋអាមេរិក ។ ដោយសារតែសារមន្ទីរទួលស្លែងដែលដំណើរការឡើងដោយរដ្ឋាភិបាល

មិនសូវបានសង្កត់ធ្ងន់ទៅលើគរុកោសល្យ ដូច្នេះ គឺចាំបាច់ត្រូវការជំនួយក្នុងការអភិវឌ្ឍខ្លួនឯងឲ្យទៅជាវិទ្យាស្ថានអប់រំមួយដែលមានសមត្ថភាពបង្រៀនសាធារណជនពីអំពើប្រល័យពូជសាសន៍ និងបន្ថែមកម្មវិធីសិក្សានៅក្នុងសាលា ។ សារមន្ទីរគឺមានសក្តានុពលក្នុងការក្លាយជាផ្នែកទាំងមូលនៃការអប់រំពីអំពើប្រល័យពូជសាសន៍ទាំងផ្លូវការនិងមិនផ្លូវការទូទាំងប្រទេសកម្ពុជាសម្រាប់ប្រជាជនគ្រប់វ័យនិងការអប់រំ ។

បទពិសោធន៍របស់អ្នកអប់រំដែលបានបង្រៀនពីរបបហ្វូឡូខសត៍បានបង្ហាញថា កូនសិស្សខ្លះបានបង្កើតនូវអារម្មណ៍ស្អប់និងរើសអើងជនជាតិអាល្លឺម៉ង់ ។ ដូចគ្នាដែរ ការបង្រៀនពីអំពើប្រល័យពូជសាសន៍កម្ពុជាអាចធ្វើឲ្យមានការប្រឆាំងនិងរើសអើងជនជាតិវៀតណាម ជនជាតិចិន និងអតីតកម្មាភិបាលខ្មែរក្រហម ។ អាស្រ័យហេតុនេះ អ្នកបង្កើតសៀវភៅមេរៀន និងអ្នកអភិរក្សសារមន្ទីរត្រូវតែមានការប្រុងប្រយត្ន័នៅពេលដែលពួកគេគ្រោងធ្វើការងាររបស់ពួកគេនិងណែនាំការពិភាក្សារវាងអត្តសញ្ញាណជាតិនិងមនោគមន៍វិជ្ជា ។ សិស្សត្រូវតែយល់ដឹងឲ្យបានច្បាស់ថា មិនមែនជនជាតិអាល្លឺម៉ង់ទាំងអស់នោះទេដែលប្តេជ្ញាចិត្តចូលក្នុងបក្សណាហ្ស៊ី ដូចគ្នាអ៊ីចឹងដែរ សិស្សគួរដឹងថាមិនមែនប្រជាជនខ្មែរគ្រប់រូបសុទ្ធតែប្តេជ្ញាចិត្តចូលក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយមិនមែនជនជាតិវៀតណាម ឬចិនទាំងអស់សុទ្ធតែត្រូវពាក់ពន្ធ័ជាមួយនឹងអំពើប្រល័យពូជសាសន៍ខ្មែរក្រហមនោះទេ ។

ជាងនេះទៅទៀត ទស្សនៈប្រឆាំងនឹងជនជាតិអាល្លឺម៉ង់គឺអាចនាំឲ្យមានការផ្លាស់ប្តូរគ្នាបាននូវការប្រើប្រាស់ពាក្យថា «ណាហ្ស៊ី» ទៅជា «អាល្លឺម៉ង់» ដែលមិនត្រឹមតែពណ៌នានៅក្នុងការបោះពុម្ពជាច្រើនទេ ថែមទាំងនៅក្នុងអត្ថបទរបស់អ្នកសិក្សាមួយចំនួនទៀតផង ។ បើធ្វើការប្រៀបធៀបក្នុងប្រទេសកម្ពុជាវិញ គឺប្រាកដជាមានការយល់ច្រឡំក្នុងការផ្លាស់ប្តូរពាក្យពី «ខ្មែរក្រហម» ទៅជា «កម្ពុជា» ឬក៏ពី «វៀតណាម» ទៅជា «ប្រល័យពូជសាសន៍» ។ ប្រសិនបើភាពខុសគ្នាមិនបានធ្វើបែងចែកឲ្យច្បាស់ គឺអាចនាំទៅរកភាពខុសឆ្គងនៃការពិតប្រវត្តិសាស្ត្រនិងជម្លោះនយោបាយផ្សេងទៀតរវាងប្រជាជាតិទូទាំងអាស៊ីអាគ្នេយ៍ និងក្រុមជាតិសាសន៍ដទៃទៀតក្នុងប្រទេសកម្ពុជា ។

តើការសិក្សាប្រៀបធៀបពីការអប់រំអំពើប្រល័យពូជសាសន៍អាចជួយដោះស្រាយបញ្ហាសង្គមដោយរបៀបណា?

ការសិក្សាប្រៀបធៀបពីការអប់រំអំពើប្រល័យពូជសាសន៍នឹងអនុញ្ញាតឲ្យសិស្សានុសិស្សកម្ពុជាមើលឃើញហួសពីអំពើប្រល័យពូជសាសន៍កម្ពុជា និងស្វែងយល់ពីភាពដូចគ្នានៃអំពើជីសាហាវយង់ឃ្នង និងទង្វើអមនុស្សធម៌ក៏មានកើតឡើងនៅបណ្តាប្រទេសផ្សេងៗទៀតទូទាំងសកលលោកក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ។

ម្យ៉ាងវិញទៀត ការសិក្សាប្រៀបធៀបពីការអប់រំអំពើប្រល័យពូជសាសន៍ជួយជំរុញលើកទឹកចិត្តកូនសិស្សឲ្យចេះបង្កើតនូវការត្រិះរិះពិចារណា ដែលពួកគេត្រូវការដើម្បីឆ្លុះបញ្ចាំងទៅលើស្ថានភាពសង្គមនិងនយោបាយនាពេលបច្ចុប្បន្ននៅក្នុងប្រទេសរបស់ខ្លួន ជាពិសេសគឺបានចូលរួមវិភាគទាននៅក្នុងបេសកកម្មពិភពលោកដើម្បីប្រយុទ្ធប្រឆាំងទប់ស្កាត់មិនឲ្យរបបប្រល័យពូជសាសន៍កើតឡើងមានម្តងទៀត ។ លើសពីការស្វែងយល់ពីអតីតកាលនិងបង្កើតជំនាញនៃការគិតពិចារណា ការសិក្សាប្រៀបធៀបពីការអប់រំអំពើប្រល័យពូជសាសន៍អនុញ្ញាតឲ្យក្មេងៗចេះបង្កើតតម្លៃសីលធម៌ និងជាតិសាសន៍ដែលរួមទាំងការអាណិតអាសូរ និងការអត់ឱនឲ្យអ្នកដទៃ ។ ការសិក្សាប្រៀបធៀបពីការអប់រំអំពើប្រល័យពូជសាសន៍គឺអាចផ្តល់នូវឱកាសដល់ក្មេងជំនាន់ក្រោយមានគំនិតខ្លះអំពីរបបប្រល័យពូជសាសន៍ និងចេះប្រៀបធៀបនូវទស្សនៈរបស់មេដឹកនាំនៃរបបនោះទៅនឹងច្បាប់សង្គមផ្សេងៗដែលនឹងអាចផ្តល់នូវគំនិតសម្រាប់ដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងការរើសអើងនៅក្នុងសង្គម ។

ជាពិសេសទៅទៀត ការសិក្សាប្រៀបធៀបពីការអប់រំអំពើប្រល័យពូជសាសន៍ក៏អាចជួយបង្វែរប្រទេសក្រោយអំពើប្រល័យពូជសាសន៍ចេញពីការរើសអើងប្រទេសរបស់ខ្លួនឯងដែរ ។ ឧទាហរណ៍ដូចថា ដោយសារតែកម្ពុជាក៏ដូចជាប្រជាជនរបស់ពួកគេធ្លាប់បានទទួលរងការលំបាកគ្រប់បែបយ៉ាងអស់ជាងរាប់ទសវត្សរ៍មកហើយ ទើបធ្វើឲ្យប្រជាជនជាទូទៅតែងតែជឿជាក់ថាកម្ពុជាគឺមានន័យដូចគ្នាទៅនឹងការសម្លាប់ ជម្លោះ សង្គ្រាមការតស៊ូ

ទាមទារយកអំណាច ការលំបាក និងភាពក្រីក្រ ។ ប្រជាជនកម្ពុជាដែលភាគច្រើនសុទ្ធតែកាន់សាសនាព្រះពុទ្ធតែងតែទទួលយកនូវជោគវាសនារបស់ពួកគេ ហើយមិនសូវជាខិតខំតស៊ូដើម្បីធ្វើការផ្លាស់ប្តូរនូវវាសនាទាំងអស់នោះទេ ។ ទស្សនៈសង្គមទាំងអស់នេះនៅតែបន្តស្ថិតស្ថេរជារូបរាងនៅក្នុងសង្គមខ្មែរបច្ចុប្បន្នយ៉ាងខ្លាំងក្លា ។ ការខិតទៅជិតការប្រៀបធៀបពីការអប់រំអំពើប្រល័យពូជសាសន៍នឹងអាចឲ្យប្រជាជនកម្ពុជា ជាពិសេសក្មេងជំនាន់ក្រោយបានយល់ដឹងថា អំពើប្រល័យពូជសាសន៍មានមែនជារឿងចម្លែកក្នុងប្រទេសកម្ពុជា ក៏ដូចជាក្នុងប្រវត្តិសាស្ត្រនោះដែរ ។ ជាមួយនឹងអត្ថប្រយោជន៍នៃការអប់រំអំពើប្រល័យពូជសាសន៍គឺធ្វើឲ្យប្រជាជនកម្ពុជាអាចមើលឃើញពីរបៀបដែលជនរងគ្រោះដោយរបបហ្វូឡូខសត៍និងអំពើប្រល័យពូជសាសន៍ដទៃទៀតអាចរស់រានមានជីវិតបាន និងគេចផុតរាល់ឧបសគ្គទាំងអស់ ។

ជាងនេះទៅទៀត ការសិក្សាប្រៀបធៀបពីការអប់រំអំពើប្រល័យពូជសាសន៍អាចធ្វើឲ្យសិស្សមានការយល់ដឹងវែងឆ្ងាយជាងអ្វីដែលបានពិពណ៌នាជាប្រវត្តិសាស្ត្រ ដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងសង្គ្រាមនិងអំពើប្រល័យពូជសាសន៍ ។ ដូចការអង្កេតរបស់លោក គ្រីស្តូបភើ ហ្វេតវេស ថា អំពើប្រល័យពូជសាសន៍តែងតែកើតឡើង ឬក៏គ្រាន់តែក្រោយសង្គ្រាមបន្តិចតែប៉ុណ្ណោះ ។ ដូចជាការសម្លាប់ជនជាតិអាម៉េនៀនដោយជនជាតិទួគី គឺកើតឡើងក្នុងអំឡុងសង្គ្រាមលោកលើកទី១ ចំណែកឯរបបហ្វូឡូខសត៍កើតឡើងក្នុងអំឡុងសង្គ្រាមលោកលើកទី២ ។ បើក្រឡេកមើលពីទំនាក់ទំនងរវាងរបបហ្វូឡូខសត៍និងសង្គ្រាមលោកលើកទី២ ទោះបីជាលោក ហ្វេតវេស បដិសេធពីភាពភាពចម្លែកតែមួយគត់នៃទំនាក់ទំនងរវាងសង្គ្រាមលោកលើកទី២និងរបបហ្វូឡូខសត៍ក៏ពិតមែន តែលោកបានបញ្ជាក់ថា យ៉ាងហោចណាស់ សង្គ្រាមបានធ្វើឲ្យរបបហ្វូឡូខសត៍អាចមានភាពងាយស្រួលដល់ណាហ្ស៊ីក្នុងការសម្រេចជោគជ័យ ដោយសារតែវាដូចជាជួយដាក់ប្រេងលើហ្គានៃម៉ាស៊ីនអំពើប្រល័យពូជសាសន៍ ដោយបង្កើតនូវបរិយាកាសមួយដែលធ្វើឲ្យគំនិតដែលពេលមានសន្តិភាពមិនត្រូវបានយកមកគិតបានប្រែក្លាយទៅជាសមហេតុសមផល ហើយអាចទទួលយកបានទៅវិញ ។

ដូចគ្នាអ៊ីចឹងដែរ ប៉ុល ពត និងអ្នកចូលរួមផ្សេងៗបានបង្កើតឡើងនូវវាលពិឃាតនៅក្នុងទឹកដីកម្ពុជាក្នុងអំឡុងសង្គ្រាមស៊ីវិលនិងសង្គ្រាមឥណ្ឌូចិនលើកទីពីរឆ្នាំ១៩៧០ ។ ឯបូស្នៀនស៊ែបបានអនុវត្តនូវការកម្ទេចចោលជនជាតិមូស្លីមក្នុងអំឡុងសង្គ្រាមផ្ទៃក្នុងនៅអតីតយូហ្គោស្លាវី ។ ចំណែកការសម្លាប់រង្គាលរបស់ហាតើសមកលើជនជាតិតាតស៊ីសនៅក្នុងប្រទេសរ៉្វាន់ដា ក៏កើតចេញពីសង្គ្រាមស៊ីវិលក្នុងប្រទេសផងដែរ ។ ចំពោះការប្រៀបធៀបបែបនេះអាចផ្តល់នូវទស្សនៈមួយដល់សិស្សថា កន្លែងណាក៏ដោយឲ្យតែមានសង្គ្រាមកើតឡើង កន្លែងនោះប្រាកដជាអាចមានអំពើប្រល័យពូជសាសន៍កើតឡើង ។ ឬក៏យ៉ាងហោចណាស់នៅពេលដែលសង្គ្រាមកើតឡើង នោះនឹងបង្កើតឲ្យមានលក្ខខណ្ឌមួយដែលអាចដឹកនាំទៅរកការសម្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់និងអំពើប្រល័យពូជសាសន៍ផងដែរ ។ នៅក្នុងប្រទេសកម្ពុជាគឺវាច្បាស់ខ្លាំងណាស់កាលដែលថា សង្គ្រាមបានពាំនាំមកនូវគំនុំគុំគួនក្នុងចិត្តយ៉ាងជ្រៅនៅក្នុងចំណោមពួកជាតិជ្រុលនិយមមកលើសត្រូវរបស់ពួកគេ ។ ប៉ុន្តែភ្លាមនោះ ដោយសារតែពួកគេពុំអាចធ្វើការបែងចែកនរណាជាសត្រូវនិងនរណាមិនមែនសត្រូវទើបធ្វើឲ្យមានការសម្លាប់យ៉ាងខ្លាំងក្លាបែបនេះនៅក្នុងប្រទេស ។

អ្នកដំណើរបរទេសជាច្រើនដែលបានចំណាយពេលវេលារបស់ពួកគេនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៦០ បានធ្វើការពិពណ៌នាថាកម្ពុជាគឺជាកោះសន្តិភាព ។ ពួកគេបានហៅទីក្រុងភ្នំពេញថាជាទីក្រុងដ៏ស្រស់ស្អាតជាទីបំផុតនៅភូមិភាគអាស៊ីអាគ្នេយ៍ ។ កម្ពុជាពិតជាអ្នកកាន់ព្រះពុទ្ធសាសនា និងជាប្រទេសស៊ីវិល័យពិតប្រាកដមែន ។ ប៉ុន្តែដោយសារតែសង្គ្រាមស៊ីវិលនិងការតស៊ូទាមទារយកអំណាចផ្ទៃក្នុង ព្រមទាំងការហិនហោចដែលបង្កឡើងដោយសង្គ្រាមបរទេស បានជំរុញឲ្យប្រទេសកម្ពុជាទៅកាន់ស្ថានភាពដ៏អាក្រក់ជូរជាតិ ។ កាលៈទេសៈទាំងនេះហើយដែលធ្វើឲ្យខ្មែរក្រហមគិតថា ប្រពន្ធ័ប្រជាធិបតេយ្យនិងការតស៊ូផ្នែកនយោបាយដោយសន្តិភាពគឺមិនអាចយកមកអនុវត្តនៅប្រទេសកម្ពុជាបាននោះទេ គឺមានតែរបបផ្តាច់ការ មនោគមន៍វិជ្ជាកុម្មុយនីស្ត និងចម្បាំងទេដែលជាមធ្យោបាយតែមួយគត់ក្នុងការដោះស្រាយជម្លោះដ៏យូរអង្វែងរបស់កម្ពុជាបាន ហើយថែមទាំងដូចរបបណាហ្ស៊ីអ៊ីចឹង

គឺអ្វីដែលមិនអាចធ្វើបាន និងមិនគួរគិតក្លាយទៅជាអាចធ្វើទៅបាន ហើយគួរពិចារណាទាំងអស់ ។ ខ្មែរក្រហមបានធ្វើសេចក្តីសន្និដ្ឋានថា ប្រជាជនសុទ្ធតែដូចពួកគេទាំងអស់ហើយចេញពីជាតិសាសន៍តែមួយក្លាយទៅជាសត្រូវរបស់ពួកគេ ។ អាស្រ័យហេតុនេះហើយវាមានសារៈសំខាន់ណាស់ក្នុងការសិក្សាពីសារជាតិនៃសង្រ្គាមរបបហូឡូខសត៍ ក៏ដូចជាសារជាតិរបស់អំពើប្រល័យពូជសាសន៍ និងការសិក្សាប្រៀបធៀបពីជម្លោះប្រសិនបើចង់ធ្វើការទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យកើតមានឡើងទៀត ។

ការសិក្សាប្រៀបធៀបក៏អាចអនុញ្ញាតឲ្យសិស្សស្វែងយល់ថា អំពើប្រល័យពូជសាសន៍មិនមែនជាបញ្ហាដែលកើតមកពីនរកដូចមាននៅក្នុងសៀវភៅ *Samantha Power* សាម៉ាន់ថា ផៅវឺ (អំណាចនៃសាម៉ាន់ថា) ដែលនាងបានដាក់ចំណងនោះទេ ។ វាគឺច្បាស់ខ្លាំងណាស់កាលដែលថាអ្វីៗទាំងនេះកើតឡើងដោយសារបុព្វហេតុមនុស្សដែលអាចធ្វើការទប់ស្កាត់បាន នៅពេលដែលមនុស្សត្រូវបានផ្តល់ឱកាសឲ្យមើលឃើញឲ្យបានស៊ីជម្រៅពីស្ថានភាពដែលដឹកនាំទៅរកអំពើប្រល័យពូជសាសន៍ ។ ព្រឹត្តការណ៍ដែលដូចគ្នាទៅនឹងអំពើប្រល័យពូជសាសន៍អាចកើតឡើងបាននៅពេលដែលកាលៈទេសៈអំណោយផល ។ ការស្វែងយល់ពីមូលដ្ឋានគ្រឹះនៃអំពើប្រល័យពូជសាសន៍នេះនឹងអាចជួយប្រឆាំងនឹងទស្សនៈចាស់ៗដែលថាអំពើសាហាវឃោរឃៅគឺជារឿងដែលនឹងអាចកើតឡើងដោយមិនអាចជៀសផុតបាន ។

បើក្រឡេកមើលទាំងរបបហូឡូខសត៍និងអំពើប្រល័យពូជសាសន៍កម្ពុជា វាច្បាស់ខ្លាំងណាស់កាលដែលថា ការសិក្សាអំពីរបបហូឡូខសត៍គឺមានសារសំខាន់សម្រាប់ប្រជាជនជ្វីហ្វ និងប្រជាជនដទៃទៀតទូទាំងសកលលោក ដែលទៅថ្ងៃក្រោយគឺជាអ្នកដែលត្រូវបានគេផ្តល់អំណាចឲ្យធ្វើការផ្សព្វផ្សាយពីការការពារមិនឲ្យមានអំពើប្រល័យពូជសាសន៍ ការគោរពសិទ្ធិមនុស្ស លិទ្ធិប្រជាធិបតេយ្យ សន្តិភាព និងការរួបរួមជាតិ ។ ទាក់ទងទៅនឹងរឿងនេះ ប្រជាជនកម្ពុជាត្រូវការស្វែងយល់ឲ្យបានច្បាស់ពីប្រវត្តិសាស្ត្រអំពើប្រល័យពូជសាសន៍នៃប្រទេសរបស់ខ្លួនដើម្បីដឹកនាំប្រទេសឆ្ពោះទៅនីតិរដ្ឋ ប្រជាធិបតេយ្យដ៏ពេញលេញ សន្តិភាព និងសាមគ្គីភាព ។ ដុយគ្នាទៅនឹងការរីកចម្រើននៃការសិក្សាមេរៀនរបបហូឡូខសត៍ច្រើនជាង៥០ឆ្នាំមកនេះនៅក្នុងពាក្យសម្តីរបស់ យូរីល ជ្រ័រ ដែលថា «គឺនៅតែមានការលុបចោលចំណុចសំខាន់ខ្លះៗចេញពីកម្មវិធីសិក្សាថ្នាក់អនុវិទ្យាល័យទាំងផ្លូវការនិងមិនផ្លូវការ ។ ហើយកន្លែងជាច្រើនសម្រាប់ការអភិវឌ្ឍន៍ និងភាពប្រសើរឡើងដើម្បីឆ្លុះបញ្ចាំងពីការព្រួយបារម្ភរបស់សង្គម-បច្ចុប្បន្ន» ។

ការណែនាំអំពើប្រល័យពូជសាសន៍ខ្មែរក្រហមនិងការសិក្សាប្រៀបធៀបពីអំពើប្រល័យពូជសាសន៍ដទៃទៀតនៅក្នុងប្រទេសកម្ពុជា គឺជាជំហានសំខាន់មួយក្នុងការឆ្ពោះទៅរកការកែប្រែឡើងនូវជំនឿសង្គម និងធ្វើឲ្យមានការផ្លាស់ប្តូរទាំងក្នុងសង្គមនិងនយោបាយនៅក្នុងសង្គមដែលត្រូវបំផ្លាញយ៉ាងខ្ទេចខ្ទាំនេះ ។ ជាងប៉ុន្មានទសវត្សរ៍មកហើយអ្នកដឹកនាំនយោបាយបានជះឥទ្ធិពលមកលើជំនឿសង្គមយ៉ាងខ្លាំង ដែលបែងចែកប្រទេសឲ្យទៅជាក្រុមនយោបាយ និងក្រុមសង្គម ហើយចុងបញ្ចប់ប្រែក្លាយទៅជាមហន្តរាយចុងក្រោយនៃសម័យខ្មែរក្រហម ។ ពួកជាតិជ្រុលនិយមនិងអ្នកស្នេហាជាតិជ្រុលនិយមបានបង្កើតឲ្យមានភាពស្មោះត្រង់សេចក្តីស្រលាញ់ ការថែរក្សា និងការបូជាលះបង់ដើម្បីជាប្រយោជន៍ដល់ជាតិតែម្ខាងតែប៉ុណ្ណោះ ។ ជំនួសឲ្យការរួបរួមគ្នានិងសាមគ្គីភាពនៅក្នុងសង្គម ជំនឿជ្រុលនិយមទាំងនេះបានបញ្ចុះបញ្ចូលប្រជាជនឲ្យឈានដល់ចំណុចមួយដែលធ្វើឲ្យពួកគេអាចសម្លាប់ញាត្តិសន្តាន និងបំផ្លាញសាសនាដ៏យូរអង្វែងរាប់ពាន់ឆ្នាំនិងបេតិកភណ្ឌវប្បធម៌របស់ពួកគេ ។

នាពេលបច្ចុប្បន្ននេះ អាកប្បកិរិយាចំពោះបញ្ហាសង្គមដូចជាអំពើពុករលួយ ភាពគ្មានទោសពៃរ៍ សង្គមកេងប្រវ័ញ្ចមកលើអ្នកក្រ ការតស៊ូទាមទារអំណាច ការប្រើប្រាស់អាវុធយ៉ាងព្រៃផ្សៃ ការជួញដូរគ្រឿងញៀន ការរំលោភបំពានសិទ្ធមនុស្ស ការជួញដូរមនុស្សជាដើម បានធ្វើឲ្យប្រជាជនមានគំនិតមួយថា ចំពោះរឿងដ៏អាក្រក់ទាំងនេះគឺជាផ្នែកមួយនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ ហើយសំខាន់នោះគឺវាមិនអាចត្រូវបានដោះស្រាយបានឡើយ ។ ចុងបញ្ចប់ ពួកវាក៏ប្រែក្លាយទៅជាផ្នែកមួយនៃភាសា សញ្ញា គំនិតខុសឆ្គង វប្បធម៌ និងការចងចាំជាសមូហភាព ។ ជំនឿសង្គមទាំងនេះបានបណ្តាលឲ្យមានជម្លោះ សង្រ្គាមស៊ីវិល អំពើហិង្សា និង

ការបន្តឲ្យមានបញ្ហាសង្គមទាំងនេះបានផ្ទុះឡើង ដែលនៅតែបន្តមាននៅក្នុងសង្គមបច្ចុប្បន្ន ហើយនឹងអាចបន្តមានទៅថ្ងៃអនាគត ប្រសិនបើការអប់រំពីអំពើប្រល័យពូជសាសន៍នៅតែអវត្តមានពីសាលា ។ កម្ពុជាត្រូវតែផ្តល់ឱកាសមួយដល់ប្រជាជនដើម្បីសិក្សាពីកំហុសឆ្គងរបស់ខ្លួន ដូចអ្វីដែលប្រទេសអាល្លឺម៉ង់បានធ្វើ ។

នាពេលបច្ចុប្បន្ននេះ ប្រទេសអាល្លឺម៉ង់គឺជាជើងឯកពិភពលោកផ្នែកសិទ្ធិមនុស្ស ។ ប្រសិនបើពួកយើងចង់ជះឥទ្ធិពលដល់អាកប្បកិរិយាក្មេងកម្ពុជាជំនាន់ក្រោយ នៅពេលនេះ ពួកយើងត្រូវតែផ្តល់អំណាចឲ្យពួកគេរៀនពីអតីតនិងជះឥទ្ធិពលដល់អនាគតរបស់ពួកគេតាមមធ្យោបាយផ្សេងៗគ្នា ។

ការត្រួតពិនិត្យទៅលើការសិក្សាប្រៀបធៀបពីអំពើប្រល័យពូជសាសន៍បានបង្ហាញឲ្យឃើញថា ការសិក្សាអប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងអំឡុងពេលក្រោយសម័យអំពើប្រល័យពូជសាសន៍គឺតែងតែធ្វើឲ្យមានលក្ខណៈនយោបាយដើម្បីបំពេញគោលបំណងឲ្យរដ្ឋ ។ វាត្រូវការពេលជាងរាប់ទសវត្សរ៍ ដើម្បីរៀបចំឲ្យមានការបង្រៀនត្រឹមត្រូវពីការអប់រំអំពើប្រល័យពូជសាសន៍នៅក្នុងសាលា ។ ដូចករណីប្រទេសអ៊ីស្រាអែលត្រូវការពេលបួនទសវត្សរ៍ ដើម្បីកែប្រែសៀវភៅមេរៀនរបស់ពួកគេចាប់ពីសៀវភៅមេរៀនដែលមានលក្ខណៈបែបរើសអើងឲ្យទៅជាសៀវភៅមួយដែលពុំសូវរើសអើង ម្យ៉ាងទៀតចាប់ពីសៀវភៅដែលមានលក្ខណៈបំបែកសហគមន៍ជ្វីហ្វចេញពីពិភពរបស់ពួកអារ៉ាប់ឲ្យទៅជាមានការប្រែប្រួលមួយកម្រិតទៀត ដោយពង្រឹងការរួមរស់ជាមួយគ្នាវិញនៃជនជាតិជ្វីហ្វ-អារ៉ាប់ ។

ដូចគ្នានឹងចិនដែរ ប្រទេសកម្ពុជាត្រូវការពេលជិត៣០ឆ្នាំ ដើម្បីផ្លាស់ប្តូរសៀវភៅមេរៀនរបស់ខ្លួន ហើយក៏ដើម្បីវិវត្តពីសៀវភៅដែលមានលក្ខណៈឃោសនាបែបនយោបាយ ការលួងលោម ការស្អប់ខ្ពើម និងការសងសឹកឲ្យទៅជាសៀវភៅដែលមានលក្ខណៈត្រឹមត្រូវតាមប្រវត្តិសាស្ត្រ និងមិនលម្អៀងខាងនយោបាយ ។ ប្រហែលជាពេលវេលាអាចឆ្លើយតបបានដោយសារតែវាបានផ្តល់នូវទស្សនវិស័យដល់ប្រទេសនិងប្រជាជន ។ ក្រសួងអប់រំយុវជននិងកីឡានៃប្រទេសកម្ពុជាមានបំណងចង់ណែនាំការអប់រំពីអំពើប្រល័យពូជសាសន៍ជាផ្លូវការចូលក្នុងកម្មវិធីសិក្សាថ្នាក់វិទ្យាល័យនៅឆ្នាំ២០០៩ ។

វាពិតជាមានសារសំខាន់ខ្លាំងណាស់ដើម្បីធ្វើការកែប្រែជំនឿសង្គមឡើងវិញ ដោយបង្កើតចំណេះដឹងតាមរយៈការសិក្សាអប់រំប្រៀបធៀបពីអំពើប្រល័យពូជសាសន៍ ។ ទាំងនេះគឺតម្រូវឲ្យមានការគាំទ្រយ៉ាងខ្លាំងខាងផ្នែកនយោបាយ នៅក្នុងប្រទេសក្រោយអំពើប្រល័យពូជសាសន៍ ដែលត្រូវតែព្យាយាមធ្វើការបែងចែកឲ្យបានច្បាស់នូវការអប់រំពីអំពើប្រល័យពូជសាសន៍ចេញពីនយោបាយ ។ រដ្ឋាភិបាលក្រោយអំពើប្រល័យពូជសាសន៍ ឬរដ្ឋាភិបាលក្រោយជម្លោះមិនត្រឹមតែមិនលូកដៃចូលក្នុងការរៀបចំសៀវភៅមេរៀន និងកម្មវិធីសិក្សានោះទេ គឺមិនអនុញ្ញាតឲ្យអ្នកអប់រំជំនាញៗធ្វើការដោយឯករាជ្យក្នុងការនិពន្ធសៀវភៅមេរៀន និងរចនាឲ្យមានលក្ខណៈគរុកោសល្យនិងកម្មវិធីផ្សេងៗទៀត ។ ទាំងនេះអាចបង្កើននូវឱកាសឲ្យមេរៀនប្រវត្តិសាស្ត្រមានគុណភាព ហើយនឹងរួមបញ្ចូលទាំងផ្នែកអាក្រក់និងផ្នែកល្អនៃប្រវត្តិសាស្ត្រ ដែលអាស្រ័យហេតុនេះហើយអាចធ្វើឲ្យសិស្សចេះគិតបានគ្រប់ជ្រុងជ្រោយ ។ នៅពេលដែលចែកចាយសៀវភៅជូនដល់សិស្ស អ្នកនិពន្ធសៀវភៅនិងអ្នករចនាកម្មវិធីត្រូវតែចងចាំទុកក្នុងចិត្តថា វត្ថុបំណងចុងក្រោយបំផុតនៃការអប់ពីអំពើប្រល័យពូជសាសន៍គឺមិនត្រឹមតែដើម្បីការពារមិនឲ្យមានអំពើប្រល័យពូជសាសន៍នោះទេ ហើយថែមទាំងដើម្បីលើកតម្កើងឲ្យមានការទទួលខុសត្រូវផ្នែកស៊ីវិលក្នុងគោលបំណងដើម្បីសម្រេចបាននូវសន្តិភាពយូរអង្វែងនិងស្ថិតស្ថេរ ជាពិសេសការរួបរួមជាតិ ។ ដូច ដាន អេដូវ៉ែត បានបង្ហាញថា អ្នកអប់រំ «ត្រូវតែសាកសួរមិនត្រឹមតែពីភាពត្រឹមត្រូវនៃការពិពណ៌នានោះទេ ថែមទាំងពីរបៀបក្នុងការបង្រៀនពីព្រឹត្តិការណ៍ដែលឆ្លុះបញ្ចាំងក្នុងបរិបទសង្គមនិងនយោបាយក្នុងការដែលការពិពណ៌នាត្រូវបានបង្កើតនិងពីរបៀបដែលព័ត៌មានទាំងនោះត្រូវបានគេរំពឹងទុកថានឹងជះឥទ្ធិពលដល់ស្ថានភាពនយោបាយនិងសង្គម» ។

## សេចក្តីបញ្ចប់

នៅឆ្នាំបន្ទាប់ពីសង្គ្រាមលោកលើកទី២ ប្រជាជាតិមិនផ្តល់ការយកចិត្តទុកដាក់ចំពោះការអប់រំពីអំពើប្រល័យពូជសាសន៍ (ការសិក្សាប្រៀបធៀបពីអំពើប្រល័យពូជសាសន៍) ដើម្បីរក

មធ្យោបាយមួយក្នុងការប្រឈមមុខនឹងការកើតមានឡើងវិញនៃអំពើសាហាវឃោរឃៅកាលពីអតីតកាល ។ ជាងនេះ អ្វីដែលត្រូវបានផ្តោតសំខាន់នោះគឺការប្រកួតប្រជែងយកអំណាចនយោបាយ និងសេដ្ឋកិច្ច ហើយនិងការប្រកួតប្រជែងចំពោះការដេះឥទ្ធិពលខាងមនោគមន៍វិជ្ជានៅក្នុងផ្នែកផ្សេងៗទៀតនៃសកលលោក ។ ទាំងនេះបានបន្សល់ទុកនូវ «ចន្លោះប្រហោង» ដែលអាចនាំឲ្យមានការសម្លាប់ច្រើនជាងនេះនិងការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនៅកន្លែងជាច្រើននៃសកលលោក ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៥-១៩៧៩ ប្រទេសរ៉្វាន់ដានៅក្នុងឆ្នាំ១៩៩៤ និងការកម្ទេចចោលជាតិសាសន៍នៅប្រទេសបូស្នៀនៅក្នុងឆ្នាំ១៩៩៥ ។ នៅដើមសតវត្សរ៍ទី២១ ពិភពលោកគឺត្រូវបានដាស់តឿនរំឭកជាញឹកញាប់ចំពោះសកម្មភាពបន្តបន្ទាប់នៃអំពើប្រល័យពូជសាសន៍ និងការរំលោភបំពានសិទ្ធិមនុស្សនៅប្រទេសស៊ូដង់ និងភូមា ។ អ្នកសិក្សា អ្នកស្រាវជ្រាវ និងអ្នកអប់រំបានចាប់ផ្តើមមើលឃើញពីសារសំខាន់នៃតួនាទីរបស់ការសិក្សាអប់រំពីអំពើប្រល័យពូជសាសន៍ក្នុងការដោះស្រាយបញ្ហា ។

យ៉ាងណាមិញ ការអប់រំពីអំពើប្រល័យពូជសាសន៍ទូទាំងសកលលោកកំពុងបន្តការផ្តោតអារម្មណ៍ទៅលើព្រឹត្តិការណ៍ដែលទាក់ទងទៅនឹងរបបហ្វូឡូខសត៍ តែមិនសូវជាផ្តល់ការយកចិត្តទុកដាក់ចំពោះអំពើប្រល័យពូជសាសន៍ដែលកើតមាននៅបណ្តាប្រទេសកំពុងអភិវឌ្ឍនោះទេ ។ អ្នកសិក្សានិងអ្នកអប់រំពីអំពើប្រល័យពូជសាសន៍គួរតែបង្វែរការចាប់អារម្មណ៍ចំពោះបញ្ហាដែលកើតមានឡើងនៅប្រទេសលោកទី៣ ។ ចំពោះករណីដូចមាននៅក្នុងប្រទេសកម្ពុជាអាចជាឧទាហរណ៍មួយដ៏ល្អចំពោះការសិក្សានេះ ដោយសារតែប្រទេសនេះអាចយកឈ្នះទៅលើឧបសគ្គជាច្រើនជាងពាទសវត្សរ៍ ដើម្បីផ្តល់នូវការអប់រំអំពីអំពើប្រល័យពូជសាសន៍ ។

ការអប់រំពីអតីតកាលដ៏ព្រៃផ្សៃបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសនីមួយៗនិងជាពិសេសចំពោះប្រទេសក្រោយអំពើប្រល័យពូជសាសន៍ ។ ក្រៅពីនេះ សង្គមដែលមិនសូវរឹងមាំដូចប្រទេសកម្ពុជានេះគឺជួបការលំបាកច្រើនណាស់ ។ ភាពមិនរឹងមាំនេះមិនត្រឹមតែចាក់ឫសគល់ក្នុងអាកប្បកិរិយារបស់ប្រជាជននីមួយៗនោះទេ ថែមទាំងក្នុងហេដ្ឋារចនាសម្ព័ន្ធ សង្គម និងស្ថាប័ននយោបាយទៀត ។ ចាប់តាំងពីប្រជាជនកម្ពុជាទទួលរងនូវអំពើព្រៃផ្សៃជាច្រើន ពួកគេបានបាត់បង់ជំនឿជឿជាក់ទៅលើសង្គម និងប្រព័ន្ធនយោបាយនៅក្នុងប្រទេសរបស់ពួកគេ ។ ការដេះឥទ្ធិពលផ្នែកប្រវត្តិសាស្ត្រ ជាពិសេសគឺប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈពួកនយោបាយដោយដាក់ឲ្យមានការប្រកួតប្រជែងកាន់តែខ្លាំងឡើងដើម្បីធ្វើការស្តារបនាប្រទេសឡើងវិញ ក៏ដូចជាដើម្បីទទួលបានការជឿជាក់ពីសំណាក់ប្រជាជនម្តងទៀត ។

ក្នុងន័យនេះ ការសិក្សាប្រៀបធៀបពីអំពើប្រល័យពូជសាសន៍ដើរតួយ៉ាងសំខាន់ក្នុងការស្តារបនាសង្គម ការរួបរួមសង្គម និងការកសាងការជឿជាក់របស់ប្រជាជនឡើងវិញ ។ តែជាអកុសល្យ ប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ត្រូវបានធ្វើឲ្យមានលក្ខណៈជានយោបាយជាយូរណាស់មកហើយ នៅក្នុងប្រទេសកម្ពុជាជាផ្នែកមួយក្នុងការស្តារបនាជាតិឡើងវិញ និងធ្លាប់ត្រូវបានប្រើប្រាស់ដើម្បីសម្រេចគោលបំណងនយោបាយ ជាពិសេសនៅអំឡុងឆ្នាំ១៩៨០ និងដើមឆ្នាំ១៩៩០ ។ យ៉ាងណាមិញ ដូចការអប់រំពីរបបហ្វូឡូខសត៍ ការបង្រៀនពីរបបប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា គឺមានប្រយោជន៍ណាស់សម្រាប់ស្ថានភាពបច្ចុប្បន្ននេះដោយសារតែប្រតិកម្មវិជ្ជមាននិងការផ្លាស់ប្តូរគោលនយោបាយរដ្ឋាភិបាលចំពោះការបង្រៀនពីប្រវត្តិសាស្ត្ររបស់ប្រទេស ។ អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជានឹងអាចក្លាយទៅជាប្រធានបទមួយដ៏មានប្រយោជន៍សម្រាប់ការសិក្សាពីប្រវត្តិសាស្ត្រ ប្រសិនបើរដ្ឋាភិបាលបញ្ឈាក់ពីចំណាប់អារម្មណ៍របស់ខ្លួនក្នុងការកែប្រែសៀវភៅមេរៀន និងកម្មវិធីសិក្សាជាងនេះទៅទៀតគឺបន្តរបន្ថយការគ្រប់គ្រងទៅលើការនិពន្ធសៀវភៅមេរៀន ។ សង្ឃឹមថាជាមួយនឹងការមកដល់នៃការអប់រំពីអំពើប្រល័យពូជសាសន៍ និងជាពិសេសការសិក្សាប្រៀបធៀបពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា សិស្សានុសិស្សកម្ពុជានឹងអាចចាប់ផ្តើមទទួលបានការលើកទឹកចិត្តការគាំទ្រនិងជំនាញដទៃទៀតដែលពួកគេត្រូវការដើម្បីក្លាយទៅជាពលរដ្ឋក្នុងស្រុកនិងក្នុងសកលម្នាក់ដែលមានស្មារតីទទួលខុសត្រូវ ។

**ឌី ខាំបូលី**

# សហគមន៍ចាមមូស្លីម ៖ ទំនោរផ្លាស់ប្តូរមិនអាចចៀសផុត

សហគមន៍ចាមតូចមួយនៅប្រទេសកម្ពុជាមានឈ្មោះថា សហគមន៍អ៊ីម៉ាំសាន់ប្រណិបត្តិជំនឿសាសនារបស់ចម្បារដោយមានជំនឿសាសនារបៀបប្រពៃណីបុរាណនិងអភិរក្ស ។ ជំនឿនោះមានប្រភពមកពីនិកាយស៊ុសហ្វីសដែលការប្រណិបត្តិនោះមានភាពស្រដៀងគ្នាទៅនឹងប្រទេសផ្សេងទៀតនៅអាហ្វ្រិក និងប្រទេសអាស៊ីមួយចំនួនដែរ ។ និកាយស៊ុសហ្វីសដែលជាជំនឿយ៉ាងមុតមាំរបស់សាសនាឥស្លាមត្រូវគេមើលឃើញថា បានចាក់ឫសយ៉ាងជ្រៅទៅក្នុងជនជាតិមូស្លីមនៅទ្វីបអាហ្វ្រិកភាគខាងជើងដែលគោរពប្រណិបត្តិសាសនាអ៊ីស្លាមស៊ុននី ហើយការប្រណិបត្តិនេះដែរក៏ឃើញមាននៅក្នុងបណ្តាជនជាតិឥណ្ឌូណេស៊ី ប៉ុន្តែឥទ្ធិពលនោះមានការសាបរលាបទៅវិញក្នុងបណ្តាប្រទេសនៅមជ្ឈិមបូព៌ានិងកន្លែងផ្សេងទៀតក្នុងពិភពលោកយើងនេះ ។ អទិទេពសំខាន់របស់និកាយស៊ុសហ្វីសមានដូចជា សាកាត (ព្រះនៃការបរិច្ចាកទាន) តារីហ្គា (ផ្លូវទៅជួបព្រះអល់ឡោះ) អ៊ីសាន អាលកាមីល (សម្រេចបាននូវភាពឥតខ្ចោះ) សីក្ស (មនុស្សចាស់) ហើយនឹងអ្នកដឹកនាំ ។ សហគមន៍ចាមភាគច្រើននៅកម្ពុជាមិនប្រណិបត្តិនិកាយស៊ុសហ្វីសទេ ដោយសារតែសហគមន៍ទាំងនោះបានទទួលយកនូវប្រណិបត្តិបែបឥស្លាមពីបណ្តាប្រទេសអារ៉ាប់និងប្រទេសនៅអាស៊ីអាគ្នេយ៍មួយចំនួនកាលពីប៉ុន្មានទសវត្សរ៍កន្លងទៅ ។ សហគមន៍ចាមទោះតូចក្តី ធំក្តី សុទ្ធតែទទួលនូវការប៉ះពាល់ដោយឥទ្ធិពលសាកលភាវូនីយកម្ម និងទោះបីជាទំហំនៃការប៉ះពាល់នោះមិនមានលក្ខណៈស្មើគ្នាក៏ដោយ ។ ឥទ្ធិពលនេះត្រូវបានមើលឃើញដោយសារកត្តាពីរយ៉ាងគឺ ឥរិយាបទនៃការប្រណិបត្តិសាសនានិងការគ្រប់ដណ្តប់នៃទស្សនៈពីខាងក្រៅ ។

ក្រោយពេលខ្មែរក្រហមឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥ រាល់ការប្រណិបត្តិជំនឿសាសនាទាំងអស់ត្រូវបានលុបបំបាត់ ក្នុងនោះក៏មានសាសនាឥស្លាមផងដែរ ។ បញ្ញវន្តនិងអ្នកមានចំណេះដឹងជ្រៅជ្រះខាងសាសនាឥស្លាមជាច្រើនដែលបានទៅសិក្សានៅមជ្ឈិមបូព៌ាអំឡុងរបបសង្គមរាស្ត្រនិយមត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហម ។ ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ ជនជាតិឥស្លាមបានរៀបចំប្រណិបត្តិសាសនា ដើម្បីស្តាបនាសង្គមវប្បធម៌អត្តសញ្ញាណរបស់ខ្លួនឡើងវិញ ហើយនឹងស្រោចស្រង់សាសនារបស់ខ្លួនដែលបានកប់បាត់កាលពីរបបខ្មែរក្រហម ។ ទោះបីពេលនេះជាពេលដែលត្រូវធ្វើឲ្យរស់ឡើងវិញនៃជំនឿសាសនានិងសហគមន៍ចាមក៏ដោយ ក៏សាសនាឥស្លាមនៅតែមានការរីកចម្រើនតិចតួចនៅឡើយ ។ យុវជនជនជាតិឥស្លាមបានទទួលបានអាហារូបករណ៍ទៅស្រុកសិក្សានៅមជ្ឈិមបូព៌ាឬក្នុងបណ្តាប្រទេសដែលកាន់ជំនឿសាសនាឥស្លាមដទៃទៀតនៅអាស៊ីអាគ្នេយ៍ ។

ចាប់តាំងពីឆ្នាំ១៩៩២មក អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាដែលហៅកាត់ថា អ៊ុនតាក់ និងគោលនយោបាយទីផ្សារសេរីបាននាំចូលមកប្រទេសកម្ពុជានូវសាកលភាវូបនីយកម្មនិងភាពឆ្លងកាត់ប្រទេសនិយម ។ អ៊ុនតាក់បានបញ្ជូនកងរក្សាសន្តិភាពនិងមន្ត្រីរបស់ខ្លួនដែលមួយចំនួនជាជនជាតិឥស្លាម ហើយការរស់ឡើងវិញនៃសេដ្ឋកិច្ចកម្ពុជានេះបាន



តំណាងសហគមន៍ឥស្លាមធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជ

បង្កើននូវទំនាក់ទំនងយ៉ាងជិតថែមទៀតរវាងជនជាតិឥស្លាមនៅប្រទេសរបស់ខ្លួននិងនៅបរទេស ។ ហេតុការណ៍នេះបាននាំមកនូវការផ្លាស់ប្តូរខាងជំនឿសាសនានៃសហគមន៍ធំរបស់ចាម ។ ក្រោយឆ្នាំ១៩៩២ ទម្រង់នៃការប្រណិបត្តិសាសនាឥស្លាមត្រូវបានជះឥទ្ធិពលដល់ដំណាក់កាលនៃការស្តាបនាឡើងវិញនៃជនជាតិចាមមូស្លីម ។ ការផ្លាស់ប្តូរនោះមានដូចជា ការស្លៀកពាក់តាមបែបហ៊ីចាប់ (មានដូចជាការបិទបាំងគ្រប់ផ្នែកទាំងអស់នៃរាងកាយ លើកលែងតែភ្នែក ដែលជាទូទៅស្ត្រីជនជាតិចាមមិនបានអនុវត្តទេមុនពេលនៃការមកដល់នៃសាកលភាវូបនីយកម្មនេះ) ការបង្កើតនូវក្រុមដាក់វ៉ានិងការបែងចែកជាក្រុមតូចៗទៀតនៅក្នុងសហគមន៍ដូចជា វ៉ាហាប៊ីស, តាប់ប្លីហ្គី, ចេម៉ាត និង សាឡាហ៊ីស ។ ភ័ស្តុតាងបានបង្ហាញថា ការលំហូរនៃរូបិយប័ណ្ណតាមរយៈជំនួយនិងអាហាររូបករណ៍ពីប្រទេសនៅមជ្ឈិមបូព៌ានិងអាស៊ីអាគ្នេយ៍ សូឌីអារ៉ាប៊ី គូវ៉ែត ឥណ្ឌូណេស៊ី និងម៉ាឡេស៊ីបានបង្កើតឲ្យមានការផ្លាស់ប្តូរក្នុងជំនឿសាសនានៃសហគមន៍ចាម ។ គម្រោងសាងសង់វិហារឥស្លាមត្រូវបានផ្តល់ថវិកាដោយប្រទេសនិងអង្គការឥស្លាមផ្សេងៗដែលបានប្រណិបត្តិជំនឿនិកាយផ្សេងៗពីគ្នានៃសាសនាឥស្លាម មានដូចជា និកាយសាឡាហ៊ីស និកាយវ៉ាហាប៊ីស និង និកាយវ៉ាហាប៊ីស ។ ដើម្បីពង្រឹងសាសនាឥស្លាមប្រទេសមជ្ឈិមបូព៌ានិងប្រទេសម៉ាឡេស៊ីបានផ្តល់នូវការអប់រំក្នុងសហគមន៍ចាមមូស្លីម និងបានផ្តល់អាហាររូបករណ៍ដល់យុវជនចាមមូស្លីមដើម្បីទៅសិក្សាក្នុងប្រទេសរបស់ខ្លួន ។ យុវជនចាមមូស្លីមភាគច្រើនដែលបានទៅបន្តការសិក្សានៅក្នុងប្រទេសមជ្ឈិមបូព៌ាបានចាប់យកជំនាញផ្នែកការសិក្សាទៅលើឥស្លាម ចំណែកនៅប្រទេសម៉ាឡេស៊ី អ្នកទាំងនោះចាប់យកជំនាញខាងការសិក្សាពីឥស្លាមឬសិក្សាពីប្រធានបទផ្សេងក្រៅពីឥស្លាម ។ ជនជាតិចាមមូស្លីមដែលទទួលបាននូវអាហាររូបករណ៍និងថវិកានេះបានសម្លឹងមើលឃើញថា នេះមិនគ្រាន់តែជាឱកាសក្នុងការធ្វើឲ្យរីកចម្រើនឡើងវិញនូវសាសនាឥស្លាមប៉ុណ្ណោះទេ តែជាឱកាសមួយដែលពួកគេរំពឹងថានឹងទទួលបាននូវរង្វាន់ពីព្រះ ។

ទម្រង់ស្រដៀងគ្នានៃការផ្លាស់ប្តូរជំនឿត្រូវបានគេមើលឃើញផងដែរនៅក្នុងប្រទេសដែលធ្លាប់កើតមានជម្លោះកាលពីទសវត្សរ៍កន្លងទៅ មួយចំនួននៅអាស៊ីនិងមួយចំនួនទៀតនៅអាហ្វ្រិក ។ បន្ទាប់ពីបដិវត្តន៍នៅអ៊ីរ៉ង់កាលពីឆ្នាំ១៩៧៩ ប្រទេសឥណ្ឌូណេស៊ី ប្រទេសសូឌីអារ៉ាប៊ីបានផ្តល់ថវិកាដើម្បីសិក្សាពីឥស្លាម ។ លោកសាស្ត្រាចារ្យ ខូលីន ដែលបានបង្រៀនខាងផ្នែកសាសនាពិភពលោកនិងបុរាណនៃសាកលវិទ្យាល័យអូហាយ៉ូ បានរៀបរាប់នៅក្នុងសៀវភៅមួយដែលមានចំណងជើងថា ឥស្លាមជាដំណោះស្រាយ : ដាក់វ៉ានិងប្រជាធិបតេយ្យនៅឥណ្ឌូណេស៊ីថា ការផ្តល់ថវិកាដល់និកាយសាលាហ៊ីសនៅឥណ្ឌូណេស៊ីគឺដោយសារ



តែក្តីបារម្ភរបស់ប្រទេសសូឌីអារ៉ាបៀដោយសារតែឥស្លាមនិកាយស៊ុអ៊ីតរបស់អ៊ីរ៉ង់កំពុងតែរីករាលដាលដល់អាស៊ីអាគ្នេយ៍ ។

ឥទ្ធិពលរបស់ឥស្លាមក្នុងសហគមន៍ចាមអ៊ីមាំសាន់ដែលជាសហគមន៍តូចរបស់ចាមមូស្លីមនៅកម្ពុជាមិនមានទំហំធំទេបើប្រៀបធៀបទៅនឹងសហគមន៍ចាមមូស្លីមដែលមានទំហំធំជាងនេះ ដោយសារហេតុផលបីយ៉ាង ។ ទីមួយ ជំនឿនៅក្នុងវប្បធម៌ប្រពៃណីឥស្លាម (ស៊ុសហ្វីស) បានចាក់ឫសយ៉ាងជ្រៅនិងត្រូវបានសហគមន៍តូចនេះថែរក្សាយ៉ាងខ្ជាប់ខ្ជួន ។ ទីពីរ មានគម្លាតខាងផ្លូវចិត្តពីសហគមន៍ចាមធំ (តាមទំនៀមទម្លាប់មេដឹកនាំរបស់សហគមន៍អ៊ីមាំសាន់ត្រូវបានតែងតាំងដោយព្រះមហាក្សត្រខ្មែរ ចំណែកឯសហគមន៍ធំមានឈ្មោះថាមូហ្វទី ត្រូវបានតែងតាំងឡើងដោយនាយករដ្ឋមន្ត្រី) ។ លើសពីនេះទៅទៀត សហគមន៍តូចត្រូវបានឧបត្ថម្ភនិងអភិរក្សមិនមែនដោយប្រទេសឥស្លាមទេ តែដោយសារបុគ្គលមិនមែនឥស្លាមមានដូចជា អ្នកស្រាវជ្រាវ និងអ្នកប្រាជ្ញជាន់ខ្ពស់មួយចំនួននិងអ្នកមួយចំនួនទៀតដែលធ្វើការងារនៅអង្គការក្រៅរដ្ឋាភិបាល ។ ជនជាតិចាមមូស្លីមតិចតួចប៉ុណ្ណោះមកពីសហគមន៍តូចនេះដែលបានទទួលអាហាររូបករណ៍ដើម្បីទៅសិក្សានៅមជ្ឈិមបូព៌ា ។ ទោះជាយ៉ាងណា ការផ្លាស់ប្តូរនៃសមាជិកមួយចំនួននៃសហគមន៍ធំដើម្បីធ្វើខ្លួនទៅជាមនុស្សទាន់សម័យបានកើតឡើងថ្មីៗនេះ ដូចការសិក្សាស្រាវជ្រាវបានផ្តល់ភ័ស្តុតាងស្រាប់ ។

ការសិក្សាអំពីការផ្លាស់ប្តូរនៃសាសនាឥស្លាមក្នុងប្រទេសកម្ពុជាពាក់ព័ន្ធអ្នកស្រាវជ្រាវនិងអ្នកប្រាជ្ញជាន់ខ្ពស់ខ្លួនឯងដែលត្រូវបានដាក់ឈ្មោះដោយមនុស្សមួយចំនួនថា «អ្នកស្រាវជ្រាវលោកតឆត្រ» ដោយសារតែទង្វើរបស់អ្នកទាំងនោះក្នុងការមិនគោរពនិងយល់ពីការប្រណិបត្តិរបស់ប្រជាជន ។ អ្នកស្រាវជ្រាវលោកឆត្រដែលជាទូទៅមកពីប្រទេសលោកខាងលិចបានដាក់សហគមន៍ចាមមូស្លីមក្នុងលក្ខណៈមិនច្បាស់លាស់ទៅលើអ្វីដែលថាវប្បធម៌របស់ខ្លួនតែងតែប្រសើរជាងវប្បធម៌អ្នកដទៃ ។ កិច្ចការរបស់អ្នកទាំងនោះបានបង្កើតឲ្យមានភាពតានតឹងចិត្តក្នុងចំណោមមូស្លីមចាម ។ ដោយចំនួននៃអ្នករិះគន់នោះមានចំនួនច្រើនជាងធ្វើឲ្យមានការបង្ហាញពីអតុល្យភាពនៃទស្សនៈរបស់ប្រជាជនក្នុងតំបន់ ។ ឧទាហរណ៍ជាក់ស្តែងដូចជាក្នុងរយៈពេល៣០ឆ្នាំ ការសាងសង់វិហារថ្មីៗមានចំនួនមិនដល់២០០កន្លែងផងដែលចំនួននេះតិចជាងវិហារសាសនាគ្រិស្តនៅក្នុងប្រទេសកម្ពុជាទៅទៀត ។ ការស្រាវជ្រាវអំពីការរីកដុះដាលនៃសាសនាឥស្លាមមិនបានយកចិត្តទុកដាក់នៃការពង្រីកខ្លួនរបស់អ្នកកាន់សាសនាគ្រិស្ត ហើយមិនបានបំពេញតម្រូវការខាងការកសាងអត្តសញ្ញាណនៃប្រជាជនក្នុងប្រទេសដែលទើបតែមានជម្លោះ ។ អ្នកស្រាវជ្រាវក៏មិនបានយកចិត្តទុកដាក់ឲ្យបានគ្រប់គ្រាន់ថាតើស្ត្រីមូស្លីមនិងស្ត្រីទូទៅក្នុងប្រទេសកម្ពុជាបានតស៊ូដើម្បីធ្វើឲ្យមានតុល្យភាពនូវវប្បធម៌ប្រពៃណីរបស់ខ្លួនក្រោមឥទ្ធិពលនៃសាកលភាវូបនីយកម្មឬទេ ។

ឥទ្ធិពលមកពីក្រៅ (ពីពិភពអារ៉ាប់ អាស៊ី និងបស្ចិមប្រទេស) បានធ្វើឲ្យមានការផ្លាស់ប្តូរដល់ជីវិតរស់នៅរបស់ជនជាតិចាមមូស្លីមតាមរយៈដំណាក់កាលនៃការប៉ះពាល់ដោយភាពឆ្លងកាត់ប្រទេសនិយម ។ ការប៉ះពាល់នេះត្រូវបានសម្រួចដោយទស្សនៈរបស់ពួកបស្ចិមប្រទេសដែលមិនបានយកចិត្តទុកដាក់ដល់ដំណាក់កាលនៃការស្តាបនាអត្តសញ្ញាណនិងការរស់ឡើងវិញនៃសាសនា ហើយបានផ្តល់ផលវិបាកដល់ជនជាតិចាមមូស្លីមនៅប្រទេសកម្ពុជាដោយសារតែពួកគេកំពុងតែប្រឈមមុខនឹងអតីតកាលដ៏ជូរចត់ ហើយត្រូវទទួលរងនូវការលំបាកផ្នែកសេដ្ឋកិច្ចសង្គមនាសម័យទំនើបទៀត ។ ដំណាក់កាលនេះបានកើតឡើងជាច្រើនក្នុងលោកនេះ ក្នុងប្រទេសដែលរងគ្រោះដោយសារសង្គ្រាមនិងជម្លោះដូចជាប្រទេសឥណ្ឌូណេស៊ីក្រោមការដឹកនាំរបស់ស៊ូហារតូ ។ ភាពឆ្លងកាត់ប្រទេសនិយមនៃសាសនាឥស្លាមនៅប្រទេសកម្ពុជាអាចធ្វើការផ្លាស់ប្តូរទៅជាការអភិវឌ្ឍដល់សាសនា ។ ដើម្បីធ្វើកិច្ចការនេះបាន សហគមន៍ជាពិសេសមនុស្សជំនាន់ក្រោយត្រូវវាយតម្លៃដោយយកចិត្តទុកដាក់នូវភាពសមហេតុសមផលនៃការបង្កើតនូវការប្រណិបត្តិសាសនាឥស្លាមនិងជំនឿនៅក្នុងវប្បធម៌របស់ខ្លួននិងបែបផែនជីវិតរបស់ពួកគេ ។ មានអនុសាសន៍មួយថាសហគមន៍ចាមមូស្លីមត្រូវតែបង្រួបបង្រួមឡើងវិញនិងផ្តោតទៅលើការសិក្សាលើវិជ្ជាផ្សេងផ្សេងដើម្បីជំរុញនូវការអភិវឌ្ឍ ហើយលាតត្រដាងនូវរូបភាពដែលមិនមានការពេញចិត្តទៅលើសហគមន៍ ។

**សូ ហ្វារីណា**

# ការចងចាំ

*ការចងចាំជាអំពើនៃសកម្មភាពចូលរួមចំណែកមួយដែលជាប់ទាក់ទង ធ្វើឲ្យយើងនឹកគិតទៅដល់អ្វីដែលយើងធ្លាប់ឆ្លងកាត់ពីមុនមក ពីជីវិតរស់នៅ និងសេចក្តីស្លាប់ ។ តើយើងរៀនចងចាំដោយរបៀបណានិងនៅទីកន្លែងណា?*

*សារមន្ទីរជាអាគារមួយដែលសាងសង់ឡើងដោយអ្នកដែលនៅរស់សម្រាប់អ្នកនៅរស់សិក្សាពីអ្នកស្លាប់ និងកន្លែងសម្រាប់សង្កេតមើលពីអតីតកាល ហើយសារមន្ទីរនេះសាងសង់នៅក្នុងពេលបច្ចុប្បន្នសម្រាប់ឆ្ពោះបញ្ចាំងពីពេលអនាគត ។ គោលបំណងរបស់សារមន្ទីរគឺបម្រើឲ្យសង្គមនិងលើកទឹកចិត្តឲ្យមានការអភិវឌ្ឍតាមរយៈការទទួល ការរក្សាទុក ការស្រាវជ្រាវ ការធ្វើទំនាក់ទំនងនិងការតាំងពិព័រណ៍កេរដំណែលនៃរូបរាងកាយនិងផ្លូវមេឃរបស់មនុស្សនិងបរិស្ថានទាំងអស់នេះបម្រើឲ្យការអប់រំដោយផ្តល់នូវចំណេះដឹងដល់អ្នកទាំងអស់ដែលបានចូលរួម ។ សារមន្ទីរអាចធ្វើសកម្មភាពបាននិងជួយឲ្យប្រជាពលរដ្ឋស្វែងរកការប្រមូលផ្តុំនិងស្រាវជ្រាវលើមាតិការឿងសម្រាប់ឲ្យយើងនឹកឃើញ បណ្តុះគំនិតច្នៃប្រឌិតលើចំណេះដឹងផ្នែកផលិត និងការសប្បាយរីករាយ ។ សារមន្ទីរជាកន្លែងនៃការចងចាំ ដែលទាំងនោះត្រូវបានការពារ ហើយក៏អាចចូលបាន និងបន្ទាប់មក រួមចំណែកស្វែងរកការពិតសម្រាប់សង្គមតាមរយៈសង្គម ។*

*ពេលនៅក្មេង ខ្ញុំមានសំណាងណាស់ដែលបានទទួលការលើកទឹកចិត្តពីឪពុកម្តាយឲ្យទៅមើលសារមន្ទីរជាញឹកញាប់ ។ ខ្ញុំចូលចិត្តសារមន្ទីរណាស់ ពីព្រោះវាសម្បូរទៅដោយព័ត៌មាននិងតម្រូវឲ្យខ្ញុំបញ្ចូលជាមួយវត្ថុទាំងនោះ ។ ខ្ញុំធ្វើដូច្នេះបានដោយសារខ្ញុំប្រើការស្រមៃដែលខ្ញុំបានមើលឃើញពីវប្បធម៌និងអរិយធម៌ប្លែកៗពីគ្នា ។ ខ្ញុំមានបំណងដាក់ខ្លួនឯងឲ្យចូលទៅក្នុងប្រវត្តិសាស្ត្រជាទាហានរ៉ូម៉ែន ជាគ្លីអូ ផេតត្រា ជាអ្នកបដិវត្តន៍នៅក្នុងទីក្រុងប៉ារីស និងជាអ្នកកុម្មុយនីស្តម្នាក់នៅក្នុងសហភាពសូវៀត ។*

*ក្រោយមកនៅក្នុងឆ្នាំ១៩៧៩ មានអ្វីមួយកើតឡើងចំពោះរូបខ្ញុំនៅពេលដែលខ្ញុំបានមើលឃើញប្រជាជនកម្ពុជាផ្លាស់ប្តូរទីកន្លែងនិងដកហូតសិទ្ធិតាមរយៈព័ត៌មានរបស់ទូរទស្សន៍BBC ។ ប្រទេសកម្ពុជាបានចូលមកក្នុងគំនិតស្មារតីរបស់ខ្ញុំ នៅពេលដែលខ្ញុំមានវ័យ១៣ឆ្នាំ ។ ឥឡូវខ្ញុំបានដឹងពីទំនួលខុសត្រូវនិងកិច្ចការ ។ សារមន្ទីរបានផ្តល់អាជ្ញាបញ្ញាមួយនៅក្នុងការយល់ដឹងពីសង្គ្រាម ។ ខ្ញុំបានចាប់អារម្មណ៍ពីប្រវត្តិសាស្ត្រនិងវប្បធម៌ញ៉ូវរន្ធត់ដោយសារការបំផ្លាញនៃសង្គ្រាម ការបោះបង់ប្រជាជនឲ្យចូលទៅក្នុងសង្គ្រាម និងភ័យខ្លាចដោយសារតែអំពើប្រល័យពូជសាសន៍ ព្រោះវាជាលើកដំបូងនៅក្នុងជីវិតរបស់ខ្ញុំដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ដឹងពីអំពើឃោរឃៅ ។*

*៣០ឆ្នាំក្រោយមក បន្ទាប់ពីការចូលរួមនៅក្នុងគម្រោងសិល្បៈមួយចំនួននៅក្នុងប្រទេសកម្ពុជានិងការផ្លាស់ប្តូរវប្បធម៌ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានបង្កើតឡើងនូវរឿងកុនមួយផ្ទាំងនិងពិធីរំឭកមួយចំពោះប្រតិកម្មលើកដំបូងរបស់ខ្ញុំចំពោះខ្សែភាពយន្តរបស់ទូរទស្សន៍ BBC បច្ចុប្បន្នដែលខ្ញុំបានឃើញនៅក្នុងឆ្នាំ១៩៧៩ និងបានធ្វើសេចក្តីរាយការណ៍លើអំពើប្រល័យពូជសាសន៍កម្ពុជា ។*

*«កុនមួយចំនួនដែលបញ្ចាំងនៅឯពិធីបុណ្យអេដីនបឺក ហ្វ្រីង នៅក្នុងឆ្នាំ២០០៨ បានផ្លាស់ប្តូរអារម្មណ៍របស់អ្នកមើលឲ្យចូលទៅក្នុងទឹកដីមួយដ៏ខ្មៅងងឹត ។ ខ្សែភាពយន្តដ៏មណាស់ជាខ្សែភាពយន្តមួយដែលមានការសហការរវាងអ្នកដែលមានគំនិតផ្នែកកុនរបាំដែលរួមមាន ៖ និកដែល ចាណុក និង សិល្បករសម្តែងឈ្មោះ បេន អានហៀ ដែលនេះជាកុនមួយមិនបានរួមបញ្ចូលរឿងនយោបាយនិងរឿងផ្ទាល់ខ្លួនទេ ។ ជីវប្រវត្តិរបស់ អានហៀ ដែលទាក់ទងទៅនឹងគំនិតរបស់គាត់ជាមួយប្រជាជនកម្ពុជានិងការវាយប្រហារមិនត្រឹមត្រូវរបស់ខ្មែរក្រហមគឺជាការលាយបញ្ចូលគ្នាជាមួយការធ្វើអត្ថាធិប្បាយផ្នែកសង្គមនិងប្រវត្តិសាស្ត្រវប្បធម៌ដែលធ្វើមកលើយើងពីទសវត្សរ៍៦០រហូតមកដល់ពេលបច្ចុប្បន្ន ។ ដំណើររឿងនេះប្រើអត្ថបទនិយាយនៅក្នុងគំរូផ្សេងៗគ្នានិងសំឡេងផ្សេងៗគ្នា គុបតែងដោយប្រុងប្រយ័ត្ន សកម្មភាពនិងចលនានៃ*

ការសម្តែងមានសភាពស្រស់ស្អាតលាន់ឮរណ្តំ និងការរៀបចំឆាកដ៏ស្រស់ស្អាតនេះមានលក្ខណៈធំបញ្ចាំងពីទូរទស្សន៍អាវពណ៌ផ្កាឈូក ដែលអាចវិលនិងបើកបិតគុបានដើម្បីបំពេញនូវសេចក្តីសប្បាយរីករាយរបស់គេ ដែលឆាកនេះបានក្លាយទៅជាកន្លែងសម្រាប់ការសប្បាយនិងការគិត ។

នៅពេលដែលយើងមិនអាចចាំបាន នោះយើងមិនអាចទាក់ទងបានដែរ ។ នៅពេលដែលយើងមិនទាក់ទង នោះយើងមិនអាចស្រមៃបានទេ ។ បើសិនជាយើងមិនអាចស្រមៃបាន នោះយើងមិនអាចការពារខ្លួនឯងនៅពេលអនាគតបានទេ ។ ការចងចាំនៅក្នុងផ្នែកមួយនៃការចងចាំអាចផ្តល់ដល់មនុស្សនូវឱកាសសម្រាប់យល់ដឹង ។ ការយល់ដឹងលើកទឹកចិត្តឲ្យមានការពិភាក្សា ។ នៅពេលដែលយើងមិនអាចចងចាំបាន នោះក៏គ្មានអ្វីអាចពន្យល់បាន ដូច្នេះការកែប្រែមិនអាចកើតមានបានទេ ។

ហ្គូរីង ៖ ប្រាកដណាស់ ហេតុអ្វីបានជាមនុស្សមិនចង់ឲ្យមានសង្គ្រាម? ហេតុអ្វីបានជាអ្នកក្រមួយចំនួនខិលខំធ្វើការនៅក្នុងកសិដ្ឋាន ចង់ប្តូរជីវិតរបស់គេនៅក្នុងសង្គ្រាមនៅពេលដែលអ្វីល្អបំផុតសម្រាប់គាត់ចេញឆ្ងាយពីសង្គ្រាមនិងត្រឡប់មកកសិដ្ឋានរបស់គាត់វិញ ។ ជាទូទៅ មនុស្សធម្មតាមិនចង់ឲ្យមានសង្គ្រាមទេ មិនថាជនជាតិរុស្សីឬជនជាតិអង់គ្លេសទេ ឬនៅក្នុងសហរដ្ឋអាមេរិក ឬក៏នៅក្នុងប្រទេសអាល្លឺម៉ង់ទេ ។ វាត្រូវបានគេយល់ឃើញ ប៉ុន្តែបន្ទាប់មកអ្នកដឹកនាំប្រទេសដែលជាអ្នកកំណត់គោលការណ៍ ហើយវាជាបញ្ហាធម្មតាទេក្នុងការអូសទាញមនុស្ស មិនថាវាជាលទ្ធិប្រជាធិបតេយ្យ ឬអំណាចផ្តាច់ការហ្វាស៊ីសនិយម ឬសភានិយម ឬអំណាចផ្តាច់ការកុម្មុយនីស្តនិយមទេ ។

ហ្គីបឺត ៖ មានភាពខុសប្លែកគ្នាមួយនៅក្នុងប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ ប្រជាជនអាចនិយាយពីបញ្ហានេះតាមរយៈការបោះឆ្នោតជ្រើសរើសតំណាង ហើយនៅក្នុងសហរដ្ឋអាមេរិកវិញមានតែសមាជទេដែលអាចនិយាយពីសង្គ្រាមបាន ។

ហ្គូរីង ៖ មានសំឡេងឬក៏គ្មានសំឡេងប្រជាជនត្រូវនៅក្រោមការបញ្ជារបស់ថ្នាក់ដឹកនាំ ។ វាជារឿងងាយស្រួល អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ គឺប្រាប់គេថា គេកំពុងត្រូវបានវាយប្រហារ ហើយប្រកាសមិនយល់ព្រមប្រាប់អ្នកសន្តិភាពនិយមសម្រាប់ការខ្វះសេចក្តីស្នេហាជាតិនិងដឹកនាំប្រទេសទៅរកគ្រោះថ្នាក់ ។ វាកើតឡើងដូចៗគ្នានៅក្នុងប្រទេសដទៃទៀតដែរ ។

ការថតសំឡេងនិងការធ្វើជាសាក្សី និងការចងចាំសម្រែកនៃសង្គ្រាមមិនមែនត្រឹមតែជាកិច្ចការសម្រាប់តែអ្នកសិក្សាបញ្ញវន្ត និងអ្នករក្សាឯកសារប៉ុណ្ណោះទេ ប៉ុន្តែជាការទទួលខុសត្រូវមួយសម្រាប់អ្នកដែលចូលរួមផងដែរ ។ សកម្មភាពទាំងឡាយដែលកើតឡើងដោយអ្នកនៅរស់ទាំងអស់ សម្រាប់អ្នកដែលស្លាប់មិនដូច្នេះទេ តើយើងអាចចងចាំអ្នកដែលស្លាប់និងកាន់ទុក្ខអ្នកដែលស្លាប់ដោយរបៀបណា? នៅពេលដែលសាក្សី ជនរងគ្រោះ និងជនដៃដល់បានស្លាប់ ក្រោយមក អារម្មណ៍របស់យើងចំពោះសង្គ្រាមនិងប្រវត្តិសាស្ត្រនឹងក្លាយទៅជាអ្វីមួយផ្សេងទៀតខ្សែនៃការធ្វើទំនាក់ទំនងផ្ទាល់ដែលចេញពីមាត់ទៅដល់ត្រចៀកនៃអ្នកស្តាប់នឹងចេញទៅបាត់ ។ សារមន្ទីរជាការចេញដំណើរដ៏ល្អិតល្អន់មួយដែលចេញពីសំឡេងផ្ទាល់ទៅកាន់សំឡេងមិនផ្ទាល់នៃការចងចាំរបស់គេ ។ សារមន្ទីរជាកន្លែងមួយដែលមានព័ត៌មានច្រើនអនុញ្ញាតឲ្យភ្ញៀវទេសចរតាមដាននៅក្នុងសំឡេងជាសាក្សីជនរងគ្រោះ និងជនដៃដល់នៅក្នុងតំបន់មួយដែលស្ងាត់កំបាំង ការឆ្លុះបញ្ចាំងនិងការជាប់ទាក់ទង ។ កេរតំណែលរបស់សារមន្ទីរធ្វើឲ្យប្រាកដថាគ្មានអ្វីមួយអាចបំភ្លេចបាន ឬក៏ធ្វើឲ្យវាស្មើបានទេ ទោះបីជាវាស្ថិតនៅក្នុងចិត្តនិងផ្ទាល់ខ្លួន ។

«ខ្ញុំសូមទោសក្នុងការនិយាយប្រាប់អ្នកថា កូនប្រុសរបស់អ្នកត្រូវបានគេសម្លាប់នៅថ្ងៃទី១១ ខែតុលា ឆ្នាំ១៩១៨ ។ យើងបានឡើងទៅលើកំពូលនៅថ្ងៃបរិច្ឆេទនោះ ហើយខណៈពេលដែលយើងកំពុងលូននៅក្រោមម៉ាស៊ីនបាញ់គ្រាប់កាំភ្លើងដ៏ធ្ងន់ កូនប្រុសរបស់អ្នកត្រូវគេបាញ់ចំក្បាល ។ គាត់មានអារម្មណ៍ថា ប្រង់ការមួយបានឆ្លងកាត់ចំពោះមុខគាត់ គ្រាន់តែរកឃើញ គាត់បានស្លាប់បាត់ទៅហើយ ។ សេចក្តីស្លាប់បានកើតឡើងភ្លាមៗ ហើយកូនប្រុសរបស់អ្នកមិនបានទទួលការឈឺចាប់អ្វីទាល់តែសោះ ។ គាត់ត្រូវបានបញ្ចុះនៅលើដីមួយកន្លែងក្នុងបន្ទាយយោធានៅខាងមុខខេមប្រូ ហើយក្រោយមកគណៈកម្មការផ្នូរសាកសពនៅការិយាល័យសង្គ្រាមនឹងផ្ញើរូបថតផ្នូរសាកសពទៅឲ្យអ្នក ។

**វ៉េន វ៉ាអនហ្សៀល**

# យោបល់ចំពោះសេចក្តីស្នើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលចង់ឱ្យមានគម្រោងដាក់ឱ្យមានការស៊ើបអង្កេតបន្ត ដើម្បីអាចបើកផ្លូវឈានដល់ការចាប់ខ្លួនសមាជិកខ្មែរក្រហមបន្ថែមទៀតយកមកជំនុំជម្រះ

ក្នុងនាមខ្ញុំជាជនរងគ្រោះម្នាក់ ហើយប្រហែលជាតំណាងឲ្យជនរងគ្រោះទាំងអស់និងប្រជាពលរដ្ឋខ្មែរទាំងអស់ដែរ សូមស្វាគមន៍យ៉ាងខ្លាំងក្លាចំពោះសេចក្តីផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញាអន្តរជាតិលោក រ៉ូបឺត ពេទីត ។ យ៉ាងណាក៏ដោយ នេះជាការខ្វែងគំនិតគ្នារួចទៅហើយរវាងសហព្រះរាជអាជ្ញាអន្តរជាតិលោក រ៉ូបឺត ពេទីត និងសហព្រះរាជអាជ្ញាជាតិលោកស្រី ជា លាង ដែលជំទាស់មិនឲ្យមានសម្អាងលើហេតុផលពេលវេលាថវិកា និងការរក្សាសន្តិភាពក្នុងប្រទេសកម្ពុជា ។ ដំណើរការក្តីដែលកំពុងប្រព្រឹត្តទៅបច្ចុប្បន្ននេះចំពោះការកាត់ក្តីជនត្រូវចោទ ៥ នាក់អាចនិយាយបានថាជាដំណើរការកាត់ក្តីក្នុងវគ្គទី១ ។ រីឯសំណើផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យមានការស៊ើបអង្កេតបន្ត ដើម្បីអាចបើកផ្លូវឈានដល់ការចាប់ខ្លួនសមាជិកខ្មែរក្រហម៦នាក់បន្ថែមទៀតនោះ ប្រសិនបើមានលទ្ធភាព (មានថវិកាគ្រប់គ្រាន់ដែលត្រូវបានផ្តល់ឲ្យដោយភាគីអន្តរជាតិនិងសហប្រជាជាតិ និងស្របតាមកិច្ចព្រមព្រៀងក្នុងការបង្កើតសាលាក្តីនេះ) អាចនិយាយបានថា ជាដំណើរការកាត់ក្តីក្នុងវគ្គទី២ បន្ទាប់ពីវគ្គទី១ បានបញ្ចប់រួច ។

ដូច្នេះតើអ្វីទៅដែលជាគុណតម្លៃរបស់សាលាក្តីខ្មែរក្រហមដែលមានលក្ខណៈជាសាលាក្តីអន្តរជាតិនោះ? ការអូសបន្លាយពេលវេលាកាត់ក្តីលើជនត្រូវចោទទាំង៥ នាក់ដែលកំពុងឃុំខ្លួនរង់ចាំតែការកាត់ក្តីនោះនឹងនាំទៅរកការកាត់ទោសជនត្រូវចោទកំបាំងមុខទៅវិញ ដោយហេតុថា ជនត្រូវចោទទាំងអស់កំពុងស្ថិតក្នុងវ័យជរានិងមានរោគាពាធទៀត ដូច្នេះអាចនឹងត្រូវបាត់បង់ជីវិតមុនការកាត់ក្តីត្រូវបានដំណើរការ ។ រីឯជនរងគ្រោះខ្លះទៀតដែលលោកកំពុងរង់ចាំរកយុត្តិធម៌ឲ្យពួកគាត់ដែលផ្តល់ឲ្យដោយសាលាក្តីនេះអាចបានធ្វើមរណភាពមុនដំណើរការកាត់ក្តីនេះប្រព្រឹត្តទៅ



សហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិនៅក្នុងសវនាការ កាំង ហ្គេចអ៊ាវ (ឌុច) អតីតប្រធានមន្ទីរស-២១

ទៀត ។ តើការកាត់ក្ដីកំបាំងមុខជនត្រូវចោទជាគុណតម្លៃនៃសាលាក្ដីនេះចំពោះជនរងគ្រោះឬទេ? បើដូច្នោះមែន យើងមិនគួរឲ្យមានសាលាក្ដីនេះទេ ព្រោះវាបានចំណាយថវិកាជាច្រើនចោលឥតប្រយោជន៍ ហើយយើងគួរតែយកថវិកានេះបង្វែរទៅជាសំណងដល់ជនរងគ្រោះតាមរយៈការផ្ដល់សេវានានាជួយដល់ជនរងគ្រោះទៅវិញទើបវាប្រសើរជាង ។ ហេតុផលដែលបានលើកឡើងខាងលើនេះគឺបាននិយាយយោងទៅដល់សាលាក្ដីមួយដែលបានដំណើរការកាត់ក្ដីកំបាំងមុខរួចហើយចំពោះបនប្រល័យពូជសាសន៍ ប៉ុល ពត, អៀង សារី ដែលបានដឹកនាំធ្វើឡើងដោយតុលាការនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៩ នៅសាលសន្និសីទចតុមុខទីក្រុងភ្នំពេញ ។

បើនិយាយអំពីឆន្ទៈរបស់ជនត្រូវចោទវិញ លោក ខៀវ សំផន ពិតជាចង់ឲ្យមានតុលាការកាត់ក្ដីនៅចំពោះមុខជនត្រូវចោទឧទាហរណ៍ដូចជារូបលោកយ៉ាងដូច្នេះ ព្រោះលោកចង់មានឱកាសនឹងបកស្រាយនូវបុព្វហេតុពិតនៃការឈានមកដល់ការកាន់អំណាចរបស់របបខ្មែរក្រហម ពីព្រោះថាសាក្សីរស់នៃរបបនោះមានតែអស់លោកទេដែលអាចបំភ្លឺការពិតបានដល់ជនរងគ្រោះក៏ដូចជាពិភពលោក ។

បើនិយាយអំពីឆន្ទៈរបស់រាជរដ្ឋាភិបាល លោកប្រហែលជាចង់ឲ្យដំណើរការកាត់ក្ដីនេះប្រព្រឹត្តទៅតាមពេលវេលាដែលបានគ្រោងទុកដែរ ។ ប៉ុន្តែបើផ្ទុយទៅវិញ យើងក៏អាចដឹងអំពីមូលហេតុនៃការពន្យារពេលវេលាកាត់ក្ដីនោះដែរ ។

ដូច្នេះ ការពន្យារពេលវេលាកាត់ក្ដីតទៅទៀតមិនគួរឲ្យមានដោយហេតុផលផ្សេងៗឡើយ ។ ជាការប្រសើរដែលសាលាក្ដីនេះខិតខំរិះរកវិធីយ៉ាងណាដើម្បីធ្វើឲ្យដំណើរការកាត់ក្ដីនេះប្រព្រឹត្តទៅតាមពេលវេលាដែលបានគ្រោងទុក ។ មានតែលទ្ធផលនៃការកាត់ក្ដីនេះទេដែលអាចជាគុណតម្លៃនៃសាលាក្ដីនេះ ហើយក៏ជាយុត្តិធម៌ពិតប្រាកដដែលជនរងគ្រោះទាមទារចង់បាន ។

ជាទីបញ្ចប់ ខ្ញុំសូមអំពាវនាវដល់អ្នកចូលរួមនិងអ្នកពាក់ព័ន្ធទាំងអស់ សូមជួយជំរុញឲ្យសាលាក្ដីនេះបានដំណើរការកាត់ក្ដីជនត្រូវចោទទាំង៥នាក់នេះប្រព្រឹត្តធ្វើឡើងតាមពេលវេលាដែលបានកំណត់ និងសូមចៀសវាងកុំឲ្យមានការពន្យារពេលវេលាកាត់ក្ដីនេះតទៅទៀត ។ ពិភពលោកនិងជនរួមជាតិយើងកំពុងតែចង់ដឹងនូវបុព្វហេតុរបស់របបខ្មែរក្រហមដែលបានឈានឆ្ពោះទៅរកការកើតឡើងនូវអំពើប្រល័យពូជសាសន៍នេះ ។ ដោយក្ដីរាប់អានពីអតីតជនរងគ្រោះក្នុងរបបខ្មែរក្រហមម្នាក់ ។ **ភី ខ៉ាន់ដែន**



*ហ៊ឹម ហ៊ុយ និង យុទ្ធជនខ្មែរក្រហម*

# សេចក្តីប្រកាសរកប្តី និងបងថ្លៃជូនមួយ

នាងខ្ញុំឈ្មោះ មី សយ អាយុ៥៧ សព្វថ្ងៃរស់នៅភូមិគគី ឃុំគគី ស្រុករមាសហែក ខេត្តស្វាយរៀង។ ខ្ញុំមានកូនប្រុស៥នាក់ ស្លាប់អស់៤នាក់។ ខ្ញុំសូមប្រកាសស្វែររកប្តីឈ្មោះ គឹម ពុធ (សព្វថ្ងៃគាត់មានអាយុ៦៣ឆ្នាំ) និង បងប្អូនជីដូនមួយឈ្មោះ ឌួង ថន (សព្វថ្ងៃមានអាយុ៤០ឆ្នាំ) មានស្រុកកំណើតនៅភូមិគគី ឃុំគគី ស្រុករមាសហែក ខេត្តស្វាយរៀង។ នៅឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅរស់នៅខេត្តពោធិ៍សាត់។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាត់តាំងប្តីរបស់ខ្ញុំឲ្យធ្វើការនៅកន្លែងមួយឆ្ងាយពីភូមិ។ ក្រោយមក ប្រជាជននៅក្នុងភូមិបានមកប្រាប់ខ្ញុំថា គាត់ត្រូវអង្គការចាប់ដាក់រថយន្ត រួចបញ្ជូនទៅក្រុងភ្នំពេញ។ ចាប់តាំងពីពេលនោះ ខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ឡើយ។ ចំណែក ថន ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅខេត្តបាត់ដំបង រួចក៏បាត់ខ្លួនរហូតដែរ។

ប្រសិនបើបងប្អូនណាបានស្គាល់ ឬបានឮដំណឹងពីឈ្មោះទាំងពីរខាងលើនេះ សូមមេត្តាទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ខណ្ឌចំការមន ក្រុងភ្នំពេញ។ សូមអរគុណ។

# សេចក្តីប្រកាសរកគ្រួសារបងស្រី

នាងខ្ញុំឈ្មោះ ត្រាន់ ហ៊ុយឆេង ហៅ ឡា សព្វថ្ងៃរស់នៅអាមេរិក មានឪពុកឈ្មោះ ត្រាន់ ម៉ុងឈាង និង ម្តាយឈ្មោះ ឈួ ហ្កេចអេង មានស្រុកកំណើតនៅភូមិផ្សារកំពត ឃុំកំពត ស្រុកកំពត ខេត្តកំពត។ ខ្ញុំជាកូនទី៣ក្នុងចំណោមបងប្អូន១៤នាក់ (ស្រី៧ និងប្រុស៧)។ សូមប្រកាសស្វែររកក្រុមគ្រួសារបងស្រីឈ្មោះ ត្រាន់ ហ៊ុយគីម ហៅ ត្រាន់ ហ៊ុយឡាន និងប្តីឈ្មោះ ប៉ូ តាន់ មានមុខរបរធ្វើចម្ការម្រេចនៅព្រៃទប់ ខេត្តកំពត។ នៅក្នុងរបបខ្មែរក្រហម គ្រួសាររបស់ ហ៊ុយគីម មានកូនស្រីពីរនាក់ និងប្រុសពីរនាក់ ១) តាន់ ស៊ីឈី (ប្រុស) នៅក្នុងរបបខ្មែរក្រហមអាយុប្រហែល១០ឆ្នាំ, ២) តាន់ ស៊ីងី (ប្រុស) អាយុប្រហែល៨-៩ឆ្នាំ, ៣) តាន់ ស៊ុនឡេង (ស្រី) អាយុ៥ឆ្នាំ និង ៤) តាន់ ស៊ុនអ័ង (ស្រី) អាយុ៤ឆ្នាំ។ មួយសប្តាហ៍មុនពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ គ្រួសាររបស់ ហ៊ុយគីម រស់នៅផ្សារកំពង់សោម ខេត្តកំពង់សោម។ ក្រោយមក ខ្ញុំបានទទួលដំណឹងថា គ្រួសាររបស់ ហ៊ុយគីម បានចុះឈ្មោះទៅរស់នៅប្រទេសវៀតណាម។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលទទួលបានដំណឹងពីគ្រួសារ របស់ ហ៊ុយគីម ទេ។

ប្រសិនបើបងស្រីបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាបានស្គាល់ ឬបានឃើញឈ្មោះខាងលើនេះ សូមទាក់ទងមកនាងខ្ញុំ តាមអាសយដ្ឋានៈ ៣១៧០ Serena Avenue CLOVIS, CA 93619 US, Phone: (559) 322-5175/ Cel (559) 301-1888, and Email: www.sovannkuoch@yahoo.com ។

# ដំណឹងស្វែររកម្តាយ និងប្អូនប្រុសឈ្មោះ មិន លី

នាងខ្ញុំឈ្មោះ មិន គឹមអាង ភេទស្រី អាយុ៥២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិត្រពាំងឈូក ឃុំមានរិទ្ធ ស្រុកដងទង់ ខេត្តកំពត។ ម្តាយឈ្មោះ ពៅ សួន ឪពុកឈ្មោះ មិន ម៉ាង ស្លាប់ក្នុងឆ្នាំ១៩៧៩ នៅខេត្តពោធិ៍សាត់។ មានបងប្អូនចំនួន ៥នាក់ ប្រុស ៣នាក់ និង ស្រី ២នាក់។ ១) មិន គឹមអាង ភេទស្រី ២) មិន លី ភេទប្រុស (បាត់ខ្លួន) ៣) មិន ផាន ភេទប្រុស (ស្លាប់) ៤) មិន ផល ភេទប្រុស (ស្លាប់) និង ៥) មិន អេង ភេទស្រី (ស្លាប់)។

សូមប្រកាសស្វែររកម្តាយឈ្មោះ ពៅ សួន និងប្អូនប្រុសទី២ឈ្មោះ មិន លី ដែលបានបែកគ្នាក្នុងពេលរត់ទៅខេត្តពោធិ៍សាត់ មួយខែ មុនពេលកងទ័ពវៀតណាមរំដោះប្រទេសក្នុងឆ្នាំ១៩៧៩។

ប្រសិនបើបងប្អូនញាតិមិត្តណាបានទទួលដំណឹងអ្នកទាំងពីរ សូមមេត្តាជួយផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥។ សូមអរគុណ។





ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 110, February 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.